ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- តម្លៃនៃឯកសារនៅក្នុងសាលាក្តីខ្មែរក្រហមនិងការប្រើប្រាស់ផ្សេងទៀត
- ត្រូវការតម្លាភាពនៅក្នុងសវនាការ

ថតដោយ ឡា យុំ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៩៦ ខែធ្នូ ឆ្នាំ២០០៧

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៩៦ ខែធ្នូ ឆ្នាំ២០០៧


## មាតិកា


◆ សំបុត្រ ៖ តម្លៃនៃឯកសារនៅក្នុងសាលាក្ដីខ្មែរក្រហម ........................១

**ផ្នែកឯកសារ**

◆ អ៊ាន យុទ្ធនារីក្រសួងពាណិជ្ជកម្ម ....................................................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ...............................................៧

◆ គុកខ្មែរក្រហម ......................................................................១៣

◆ តម្លៃនៃការនិយាយពីជម្ងោះអតីតកាល .........................................២២

**ផ្នែកច្បាប់**

◆ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន អៀង សារី ..........................២៥

◆ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន អៀង ធីរិទ្ធ...........................៣៤

◆ របាយការណ៍ស្ដីពីការពិនិត្យលើករណីបណ្ដឹងឧទ្ធរណ៍របស់ ឌុច ........៣៩

◆ សេចក្ដីប្រកាសព័ត៌មានការនាំខ្លួន ខៀវ សំផន ............................៥៥

**វេទិកាពិភាក្សាសាធារណៈ**

◆ ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ ...................................៥៦

◆ ត្រូវការតម្លាភាពនៅក្នុងសវនាការ .........................................៥៩

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ លិខិតរបស់លោក គុង រ៉ា ..................................................៦០






## រក្សាសិទ្ធិ


មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ ៖** ឌី ខាំបូលី, ដេផ ពន្សរ៉ាស៊ី, ជ្ជីទីល ក្រូឌឹម, អេតែល ហ៊ីហ្គនេត, ន័រមែន ហែនរី ប៉េនគេលៀរី, គុង រ៉ា **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ ៖** ព្រំ ផល្លា និង ជា ផល្លា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** លី សុផល **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន គារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# តម្លៃនៃឯកសារនៅក្នុងសាលាក្តីខ្មែរក្រហមនិងការប្រើប្រាស់ផ្សេងទៀត

ការជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមកំពុងតែខិតមកជិតដល់ ប្រជាជនកម្ពុជាជាច្រើនមានបំណងមកធ្វើជាសាក្សីឬដើមបណ្តឹងរដ្ឋប្បវេណី ។ ដំណើររឿងរ៉ាវរបស់ប្រជាជនកម្ពុជានឹងរួមចំណែកដ៏សំខាន់ដល់ប្រវត្តិសាស្ត្រខ្មៅងងឹតរបស់ប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហម និងជួយជំរុញដល់ការស្វែងរកយុត្តិធម៌សម្រាប់ប្រទេសកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងជួយសាក្សីសំខាន់ៗមកពីគ្រប់ទិសទីនៃប្រទេសកម្ពុជា និងបរទេសដើម្បីដាក់ពាក្យបណ្តឹងដល់សាលាក្តីខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏កំពុងតែចូលរួមចំណែកយ៉ាងសំខាន់ឥតលម្អៀងដល់ការស្វែងរកយុត្តិធម៌តាមរយៈឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ។ ខណៈពេលដែលដំណើររឿងរបស់សាក្សីប្រហែលជាត្រូវបានជជែកវែកញែកនៅសាលាក្តីខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារជាង៦សែនទំព័រដែលបានប្រមែប្រមូលតាំងពីឆ្នាំ១៩៩៥ អាចបម្រើជាវត្ថុតាងបញ្ជាក់អំពីកិច្ចការផ្ទៃក្នុងរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

ឯកសារនៅក្នុងបណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជាភាគច្រើនជាឯកសារដែលត្រូវបានប្រមូលបន្ទាប់ពីរបបកម្ពុជាប្រជាធិតេយ្យដួលរលំភ្លាមៗ រួចហើយទើបប្រគល់មកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ប៉ុន្តែមជ្ឈមណ្ឌលឯកសារកម្ពុជានៅតែបន្តទទួលឯកសារជាច្រើនមកពីសាធារណជនក្នុងប្រទេសកម្ពុជានិងបរទេស ។

យើងបានបែងចែកឯកសារចងក្រងជាពីរផ្នែកសំខាន់ៗគឺ ឯកសារដើមដែលបានមកពីរបបកម្ពុជាប្រជាធិបតេយ្យ និង ឯកសារបន្ទាប់បន្សំដែលត្រូវបានបង្កើតឡើងបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩ ។ ឯកសារដែលស្ថិតក្នុងប្រភេទនេះទៀតសោតត្រូវបានបែងចែកជា៥ប្រភេទ ១) ឯកសារជាក្រដាស ២) ព័ត៌មានវត្ថុតាង (ឧទាហរណ៍ ឯកសារស្តីអំពីរណ្តៅសាកសពរួម) ៣) បទសម្ភាសន៍ ៤) រូបថត និង ៥) ខ្សែភាពយន្តឯកសារ ។

ឯកសារផ្នែកទី១ដែលទំនងបង្កើតបានជាវត្ថុតាងសំខាន់ដល់សាលាក្តីខ្មែរក្រហមគឺជាឯកសារប្រមូលបានមកពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាឯកសារបានមកពីរបបនេះភាគច្រើនត្រូវបានបំផ្លាញជាប្រព័ន្ធនៅពេលខ្មែរក្រហមភៀសខ្លួនចេញនៅឆ្នាំ១៩៧៩ក៏ដោយ ក៏មានឯកសាររាប់ពាន់សន្លឹកទៀតនៅសេសសល់ដែរ ។ ឯកសារទាំងអស់រួមគ្នាអាចលាតត្រដាងពីការយល់ដឹងនិងការឃុបឃិតគ្នារបស់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ និងសបញ្ជាក់អំពីខ្សែសង្វាក់នៃការបញ្ជានៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។

ឯកសារមួយប្រភេទក្នុងចំណោមឯកសារសំខាន់បំផុតនិងច្រើនសន្ធឹកសន្ធាប់ដែលនៅសល់ពីការបាត់បង់គឺចម្លើយសារភាព ។ ចម្លើយសារភាពជាច្រើនត្រូវបានធ្វើឡើងនៅមន្ទីរសន្តិសុខទួលស្លែង និងរួមមានរបាយការណ៍ដែលរៀបចំឡើងដោយអ្នកសួរចម្លើយនៅទីនោះ ។ ចម្លើយសារភាពមួយចំនួនមានកំណត់ចំណាំដែលសរសេរឡើងដោយមន្ត្រីជាន់ខ្ពស់ ។ ជាផ្នែកមួយរបស់ឯកសារចងក្រងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាតម្កល់ទុកបញ្ជីឈ្មោះជនបរទេសដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខទួលស្លែងដាច់ដោយឡែកមួយ ឯកសារចម្លើយសារភាពរបស់សាច់សាលោហិតរាជវង្ស និងបញ្ជីឈ្មោះអ្នកដែលរស់រានមានជីវិតពីមន្ទីរសន្តិសុខនោះ ។

ប្រភេទឯកសារមួយទៀតគឺលិខិតឆ្លើយឆ្លងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឯកសារទាំងនោះរួមមានរបាយការណ៍ពីមន្ត្រីថ្នាក់ទាបទៅមន្ត្រីថ្នាក់ខ្ពស់ សេចក្តីបង្គាប់បញ្ជាពីមន្ត្រីថ្នាក់ខ្ពស់ និងសំណើសុំព័ត៌មានផ្សេងៗ ។

***របាយការណ៍និងកំណត់ហេតុគណៈកម្មាធិការបក្ស*** រួមមានកំណត់ហេតុមកពីការប្រជុំគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការតាមភូមិភាគនិងតំបន់ និងអង្គភាពយោធាជាក់លាក់ជាច្រើនទៀត ។ លើសពី

នេះទៀត យើងរក្សាទុកសេចក្តីប្រកាសជាសាធារណៈមួយចំនួនធ្វើឡើងដោយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារទាំងនេះជួយឲ្យយើងមើលឃើញអំពីអាជ្ញាធររូបវ័ន្តបុគ្គលតាមឋានានុក្រមនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងការបង្កើតមេដឹកនាំបក្សក្នុងជួររដ្ឋាភិបាល ។ ឯកសារមួយចំនួនត្រូវបានផ្តល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាដោយអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ប៉ុន្តែឯកសារផ្សេងទៀតប្រហែលជាស្ថិតក្នុងការសម្រាំងទុកប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកសិក្សាទាំងនោះ ។

ឯកសារបន្ទាប់គឺជាឯកសារជីវប្រវត្តិ យើងតម្កល់ទុកជីវប្រវត្តិ៣-៤ពាន់ច្បាប់ដែលសរសេរឡើងដោយអ្នកទោសខ្មែរក្រហម នៅពេលអ្នកទាំងនោះចូលមន្ទីរឃុំឃាំង និងជីវប្រវត្តិជិត ២ម៉ឺនឯកសារ សរសេរដោយសមាជិកបក្សកុម្មុយនីស្តកម្ពុជា ដែលភាគច្រើនមានរូបថតភ្ជាប់ជាមួយ ។ ជីវប្រវត្តិទាំងអស់នេះមានតម្លៃក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះនិងជនដែលដល់និងក្នុងការបង្កើតខ្សែសង្វាក់នៃការបញ្ជា ។

***កំណត់ហេតុនិងសៀវភៅកំណត់ត្រា***របស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាចំនួន៥២០នាក់ យោធាខ្មែរក្រហម និងមន្ត្រីផ្សេងទៀតដែលជាកម្មសិទ្ធិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជួនកាលរៀបរាប់នូវកំណត់ត្រាស្តីពីបទពិសោធន៍ប្រចាំថ្ងៃនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងជួនកាលអាចផ្តល់ជាដំណើររឿងអំពីសកម្មភាពបទល្មើសព្រហ្មទណ្ឌ ។

***ឯកសារសារព័ត៌មាន*** រួមមានសេចក្តីថតចម្លងរបស់កម្ពុជាប្រជាធិបតេយ្យតាមកាល ដែលរួមមានដំបូន្មាននិងការដាស់តឿនក្រើនរំឭកពីមេដឹកនាំបក្ស របាយការណ៍ព័ត៌មានស្តីពីជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា និងជួនកាលនិយាយអំពីកំណាព្យកាព្យឃោសនា ។ យើងក៏មានកុនឯកសារ៩៥រឿងនិងខ្សែភាពយន្តឯកសារស្តីពីការអប់រំដែលផលិតដោយរបបកម្ពុជាប្រជាធិបតេយ្យនិងសម្ព័ន្ធមិត្តរបស់របបនេះ ។ ខ្សែវីដេអូភាគច្រើនរួមមានភស្តុតាងសកម្មភាពបទឧក្រិដ្ឋដែលកើតរាលដាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

***ឯកសារស្តីពីទំនាក់ទំនងការបរទេស*** គឺជាប្រភពមួយទៀតនៃភស្តុតាងសំខាន់ ។ ឯកសារទាំងនោះរៀបរាប់ពីទំនាក់ទំនងពាណិជ្ជកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា និងការផ្គត់ផ្គង់ដល់ពលរដ្ឋនិងការផ្គត់ផ្គង់ទំនិញមកពីបរទេសសម្រាប់យោធានៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។ បន្ថែមលើកនេះទៀតនៅឆ្នាំ២០០៦ សាកលវិទ្យាល័យលុនៃប្រទេសស៊ុយអ៊ែតបានបញ្ជូនមកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានូវឯកសាររាប់ម៉ឺនសន្លឹកដែលវិសេសប្លែកពីគេទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យដែលអាចសបញ្ជាក់ពីអត្ថប្រយោជន៍សម្រាប់សាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានរក្សាទុកសម្ភារៈឯកសារក្រសាំក្រែលដែលផលិតឡើងក្រោយខែមករា ឆ្នាំ១៩៧៩ដែរ ។ ឯកសារទាំងនោះផ្តល់នូវព័ត៌មានសម្បូរបែបស្តីពីការរំលោភបំពានមកលើអ្នករស់រានមានជីវិត និងបទពិសោធន៍របស់ជនដែលដល់ក្នុងអំឡុងពេលប៉ុលពតកាន់អំណាច ។

ញត្តិធ្វើឡើងដោយអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រោយខែមករា ឆ្នាំ១៩៧៩ មន្ត្រីរបបសាធារណរដ្ឋកម្ពុជាបានប្រមែប្រមូលញត្តិគាំទ្រដែលសរសេរដោយដៃចំនួន១លានច្បាប់ពីអ្នករស់រានមានជីវិត ញត្តិគាំទ្រភាគច្រើនត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ញត្តិជាច្រើនផ្តល់ព័ត៌មានលម្អិតអំពីភាពឃោរឃៅយង់ឃ្នងរបស់បក្សកុម្មុយនីស្ត



ឯកសារទាក់ទងនឹងរបបខ្មែរក្រហមដែលមជ្ឈមណ្ឌលឯកសារកម្ពុជា

កម្ពុជានិងឈ្មោះជនរងគ្រោះ សាក្សីនិងជនដៃដល់ ។ ញត្តិទាំងនោះមិនត្រូវបានសរសេរឡើងក្រោមទោសបញ្ញត្តិនៃការភូតកុហកទេ ហើយទម្ងន់នៃភស្តុតាងនឹងយោងទៅលើការប៉ាន់ស្មានអំពីភាពគួរឲ្យទុកចិត្តបានរបស់ញត្តិទាំងនោះ ។

ឯកសារសវនាការឆ្នាំ១៩៧៩ រួមមានរបាយការណ៍កសិណសាក្សី របាយការណ៍ទូទៅ ដំណើររឿងព័ត៌មាន និងឯកសារដទៃទៀតជាច្រើនបានមកពីតុលាការបដិវត្តន៍ដែលពេញនិយមនៅឆ្នាំ១៩៧០ ។ ខណៈពេលដែលឯកសារទាំងនេះជាច្រើនផ្ទុកនូវព័ត៌មានពិតដែលពាក់ព័ន្ធដោយឥតសង្ស័យ អ្នកវិនិច្ឆ័យទោសប្រហែលជាចាត់ទុកថាមិនសូវគួរឲ្យជឿជាក់បានដោយសារការបារម្ភអំពីភាពលម្អៀង (ឧទាហរណ៍ គ្មានភស្តុតាងណាបង្ហាញពីជនជាប់ចោទដែលមិនមានវត្តមាននៅសវនាការទេ) ។

ឯកសារសម្ភាសន៍ដោយអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ អ្នកកាសែត និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាប្រភពនៃភស្តុតាងដ៏សំខាន់ ។ អ្នកវិនិច្ឆ័យទោសត្រូវការវាស់វែងនូវភាពគួរឲ្យជឿជាក់បានទៅលើបទសម្ភាសន៍១៥០០ច្បាប់ដែលយើងតម្កល់ទុកដោយធ្វើការពិចារណានូវភវនីយភាព អំពីការចងចាំរបស់អ្នកធ្វើបទសម្ភាសន៍ដែលផ្តល់ឲ្យនៅក្នុងដំណើររឿងជាក់លាក់មួយ ។ បទសម្ភាសន៍នឹងកាន់តែមានតម្លៃ ប្រសិនបើអ្នកសម្ភាសន៍និងអ្នកផ្តល់សម្ភាសន៍មានឆន្ទៈធ្វើជាកសិណសាក្សីចំពោះការសន្ទនារបស់ខ្លួន ហើយបញ្ជាក់ឲ្យឃើញនូវភាពត្រឹមត្រូវនៃបទសម្ភាសន៍ ។



ទទួលបានពីប្រទេសស៊ុយអ៊ែត នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧

**របាយការណ៍ផែនទីរណ្តៅសាកសព** ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាទម្រង់សំខាន់ចុងក្រោយនៃភស្តុតាងបន្ទាប់បន្សំ ។ របាយការណ៍ទាំងនេះរៀបរាប់លម្អិតអំពីទីតាំងនិងលក្ខណៈភិនភាគនៃរណ្តៅសាកសពរួមចំនួន១៩៧០០កន្លែងនៅទូទាំងប្រទេសកម្ពុជា ។ របាយការណ៍ទាំងនោះរួមមាន ព័ត៌មានអំពីលលាដ៍ក្បាលសាកសពដែលនៅសេសសល់និងមន្ទីរសន្តិសុខឬមន្ទីរឃុំឃាំងជិត២០០កន្លែងដែលលេចឡើងយ៉ាងច្បាស់ក្រឡែតតាំងពីរបបកម្ពុជាប្រជាធិបតេយ្យកើតឡើង ដែលមន្ទីរសន្តិសុខជាច្រើនមានផ្ទុកសំណល់ឧបករណ៍ធ្វើទារុណកម្មទៀតផង ។ រូបថតនិងបទសម្ភាសន៍របស់សាក្សី របាយការណ៍ផែនទី រណ្តៅសាកសពគឺជាការបញ្ជាក់ឲ្យឃើញនូវវត្ថុតាងដ៏ច្រើនសន្ធឹកសន្ធាប់អំពីឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា ។

ឯកសារទាំងអម្បាលម៉ាននេះនឹងមានតម្លៃដើម្បីជួយឲ្យជនរងគ្រោះស្វែងរកយុត្តិធម៌ មិនមែនដោយការសងសឹកដូចដែលបានកើតឡើងនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ទេ ប៉ុន្តែតាមរយៈដំណើរការផ្លូវច្បាប់ ។ ឯកសារទាំងនោះក៏បម្រើឲ្យគោលបំណងសំខាន់ពីរដែលមិនលម្អៀង ទី១) ឯកសារនោះនឹងជួយឲ្យយើងបង្កើតបាននូវការចងចាំអំពីរបបប៉ុលពត ដែលអាចឲ្យយើងប្រមូលបញ្ចូលគ្នាឡើងវិញ និងស្វែងយល់អំពីអ្វីដែលពិតជាបានកើតឡើងចំពោះបុគ្គលគ្រប់រូបនិងប្រទេសជាតិយើង ។ ទី២) តាមរយៈការផ្តល់ឲ្យនូវការចងចាំឡើងវិញសម្រាប់មនុស្សគ្រប់គ្នាដើម្បីពិនិត្យពិច័យនិងធ្វើការពិភាក្សាគ្នា ប្រហែលជាជួយឲ្យយើងឈានដល់ការផ្សះផ្សាចុងក្រោយជាមួយអតីតកាលដ៏ជូរចត់ ។ តាមរយៈការនាំយករឿងរ៉ាវទាំងអស់ពីអតីតកាលមកដាក់ពីមុខក្នុងអំឡុងពេលសវនាការ និងទុកឲ្យមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ខ្លួន សាលាក្តីខ្មែរក្រហមផ្ទាល់នឹងជួយឲ្យយើងសម្រេចបានគោលបំណងទាំងនេះ គឺការចងចាំ យុត្តិធម៌ និងការផ្សះផ្សា ។ **ឆាំង យុ**

# អ៊ាន យុទ្ធនារីក្រសួងពាណិជ្ជកម្ម

ចាប់តាំងពីខ្មែរក្រហមផ្តើមបានការគ្រប់គ្រងខេត្តមួយចំនួននៅក្នុងអំឡុងទសវត្សន៍ឆ្នាំ១៩៧០ គ្រប់ភូមិ ឃុំ ខ្មែរក្រហមតែងតែចុះទៅឃោសនាបបួលបំផុសឲ្យយុវជនយុវនារីចូលធ្វើបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិ ។ ចំណែកក្មេងៗវិញមិនបានដឹងថាបដិវត្តន៍មានសារសំខាន់អ្វីទេ ប៉ុន្តែគ្រាន់តែពួកគឺចង់ទៅចូលរួមជាមួយដែរ ។ អ៊ាន ហៅ ដាង មានអាយុ៤៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រែកដឹក ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ដែលធ្លាប់ជាយុទ្ធនារីបម្រើការនៅក្រសួងពាណិជ្ជកម្មបាននិយាយថា ពេលនោះគាត់មានវ័យនៅក្មេងទើបតែមានអាយុ១៣ឆ្នាំប៉ុណ្ណោះ ក៏សប្បាយរីករាយដែរនៅពេលពួថាបានចូលធ្វើបដិវត្តន៍ ។


អ៊ាន ហៅ ដាង

ដាង បានទទួលការសិក្សាត្រឹមថ្នាក់ទី១១(សង្គមចាស់) បន្ទាប់ពីរដ្ឋប្រហារនៅឆ្នាំ១៩៧០ ដាង បានឈប់រៀនមកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ ។ នៅឆ្នាំ១៩៧៣ ប្រធាននារីប្រចាំភូមិព្រែកដឹកនៅឃុំសោបឈ្មោះ សិន ដែលមានអាយុប្រហែល២០ឆ្នាំ បានមកធ្វើការឃោសនាតាមភូមិឃុំនិងស្នើសុំអាណាព្យាបាលឲ្យបញ្ជូនកូនចូលធ្វើបដិវត្តន៍ ហើយ សិន ក៏បានមកសុំ ដាង ពីឪពុកម្តាយដែរ ។ ដោយសារនៅវ័យក្មេងខ្ចីនិងមិនដឹងពីស្ថានភាពនយោបាយស្រុកទេស ដាង សប្បាយចិត្តជាខ្លាំងព្រោះពួថាបានចូលធ្វើបដិវត្តន៍ ។ ពេលចាកចេញពីផ្ទះបានមួយរយៈ ដាង មានការនឹករឭកឪពុកម្តាយនិងស្រុកកំណើតជាខ្លាំង ព្រោះមិនដែលបានលេងផ្ទះ ។ នៅទីនេះអង្គការបានចាត់តាំងឲ្យ ដាង ដាំទឹកក្តៅសម្រាប់ទទួលភ្ញៀវដែលមកប្រជុំក្នុងរយៈពេលកន្លះខែម្តង ។ អ្នកចូលរួមដូចជាប្រធានភូមិ ប្រធានឃុំ ឬប្រធានផ្នែកជាដើម ។ ក្នុងចំណោមអ្នកដែលការធ្វើការនៅទីនេះភាគច្រើនជាមនុស្សពេញវ័យមានអាយុប្រហែល២០ឆ្នាំឡើងទៅ ។

បីខែក្រោយមក ដាង ត្រូវបានផ្លាស់ឲ្យទៅធ្វើការនៅមន្ទីរស្លថ្នាំនៅព្រែករកា ក្រោមការគ្រប់គ្រងរបស់ប្រធានឈ្មោះ សំ និង ខៃ ជាអនុប្រធាន ។ ដាង ស្ថិតនៅក្នុងក្រុមកុមារីមានគ្នាជាង ១០នាក់ មានភារកិច្ចចិតសំបកថ្នាំដូចជាសំបកស្តៅ សំបកក្តុល ដាក់ហាល ឬកាប់ចាំងជាដុំៗ ។ ក្រោយពីហាលស្ងួត សំបកឈើទាំងនេះត្រូវយកទៅបុកឲ្យម៉ដ្ឋ ហើយដាក់កញ្ច្រែងរែងដើម្បីចម្រាញ់យកប្រភេទលេខ១និងលេខ២ ។ បន្ទាប់មក យកស្លឹកប្រេងខ្យល់រំងាស់ជាមួយមេថ្នាំនិងថ្នាំផ្សេងៗទៀត ។ ថ្នាំដែលផលិតបាននោះជាប្រភេទថ្នាំអាចម៍ទន្សាយ អង្គការបានយកថ្នាំទាំងនេះទៅចែកឲ្យប្រជាជននៅក្នុងភូមិសម្រាប់ព្យាបាលជំងឺគ្រុនចាញ់ ឬអាចជាថ្នាំកម្លាំងផងដែរ ។ ក្រៅពីនេះ ដាង ត្រូវនៅប្រចាំការនៅទីនេះទៀត ហើយបានទទួលរបបបាយលាយចេកត្រឡាច ឬល្ពៅ ។ នៅទីនេះ ដាង អាចសុំប្រធានមកលេងផ្ទះបានចំនួន២ដងដែរ ។ ចុងឆ្នាំ១៩៧៣ ដាង ត្រូវបានផ្លាស់ទៅលើកទំនប់និងវែកដីចាក់ព្រែកនៅភូមិកែង ហើយមួយសប្តាហ៍ក្រោយមកផ្លាស់ឲ្យទៅធ្វើការនៅព្រែកសង្កែ ត្រង់កាំបិតស្ងួល ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមវិញ ជាកន្លែងចាក់ជ័រកៅស៊ូក្រោមការគ្រប់គ្រងរបស់ ស និងប្រធាននារីឈ្មោះ ស្រ៊ុន ។ អ្នកដែលផ្លាស់ពីមន្ទីរស្លថ្នាំទៅធ្វើការទីនោះមានតែ៤-៥នាក់ប៉ុណ្ណោះ ក្រៅនេះគឺមកពីអង្គភាពផ្សេងៗទៀត ។ ដាង ជាដំបូងត្រូវបានបង្រៀនឲ្យចេះពីរបៀបចាក់ជ័រកៅស៊ូ ។ ប៉ុន្តែការងារនេះ ដាង ធ្វើមិនបានរយៈពេលយូរទេ ៨ថ្ងៃក្រោយមក ដាង ក៏មានជំងឺគ្រុនចាញ់ ហើយត្រូវបានដឹកបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យនៅព្រះអណ្តូងក្នុងឃុំបឹងកេត ខេត្តកំពង់ចាម ។ ការហូបចុកនៅទីនេះមានលក្ខណៈដូចមុន ប៉ុន្តែ ដាង មិនដែលទទួលបានការអនុញ្ញាតមកលេងផ្ទះទេ ។

នៅខែ៧ ឆ្នាំ១៩៧៥ បន្ទាប់ពីជាសះស្បើយ ប្រធានឈ្មោះ ស បានបញ្ជូនគាត់ទៅធ្វើការនៅភ្នំពេញជាមួយនារីពីរនាក់ឈ្មោះ ស្រ៊ុន និង ភ័ក្ត្រ ដែលធ្លាប់រស់នៅក្នុងស្រុកជាមួយគ្នា ។ អ្នកទាំងបីនាក់ត្រូវអង្គការចាត់តាំងឲ្យស្នាក់នៅជុំគ្នានៅឬស្សីកែវគីឡូលេខ៦

រាជធានីភ្នំពេញ ។ ដាង មានភារកិច្ចមើលថែទាំកូនម្នាក់របស់ប្រធានឈ្មោះ លំ និងប្រពន្ធឈ្មោះ យ៉ាន ជាជាងកាត់ដេរនៅផ្ទះដែលមានមិត្តនារីចំនួន៤-៥នាក់នៅជួយដេរក្រណាត់គ្របខ្នើយ និងប៉ះខោអាវ ។ រយៈពេល៥ខែក្រោយមក យ៉ាន បានផ្លាស់ ដាង និងអ្នកផ្សេងទៀតទៅធ្វើការនៅមន្ទីរក-២១ ដែលមានទីតាំងនៅជិតកន្លែងយាយស៊ូ សង្កាត់ឬស្សីកែវ រាជធានីភ្នំពេញ ។ មន្ទីរនេះមានបែងចែកជាច្រើនកងដូចជាកងកាប់ដី កងវែក កងដាំបន្លែ ដោយកងនីមួយៗមានគ្នាប្រហែលជា៣០នាក់ជាស្ត្រី ។ ដាង ទទួលភារកិច្ចដាំនិងថែបន្លែ ដូចជាត្រកួន និងស្ពៃក្រញាញ់ក្រោមការគ្រប់គ្រងរបស់នារី រឿន ជាស្ត្រីមានចរិតឆ្នាសនិយាយរដីនៗ ប្តី ឈ្មោះ ត្រា ។ ដាង ត្រូវក្រោកទៅធ្វើការតាំងពីម៉ោង៤កន្លះព្រឹក ប៉ុន្តែអាហារដែលគាត់ទទួលបានគឺហូបបបរ ជួនកាលហូបនំបុ័ង ហើយត្រូវចូលរួមប្រជុំជីវភាពតាមក្រុមរយៈពេលមួយសប្តាហ៍ម្តង ស្តីពីការកសាង ស្វ័យទិតៀននិងឲ្យយោបល់គ្នាទៅវិញទៅមក ប្រសិនបើអ្នកណាធ្វើខុសត្រូវជួយកែលំអឲ្យល្អ ។ ក្រៅពីប្រជុំជីវភាព ដាង ក៏ត្រូវចូលរួមប្រជុំរួម(ប្រជុំធំ)ជាមួយនឹងក្រុមដទៃទៀតដែលតែងតែធ្វើឡើងរយៈពេលកន្លះខែឬមួយខែម្តង ។ ការប្រជុំទាំងពីរនេះធ្វើឡើងនៅម៉ោង៦យប់ ។

ប្រហែលជាកន្លះឆ្នាំក្រោយមក រឿន ដែលជាប្រធានបានជ្រើសរើស ដាង បញ្ជូនឲ្យទៅធ្វើការនៅគីឡូលេខ៦ ដាយក្រុងភ្នំពេញ ។ ដាង មានតួនាទីចិញ្ចឹមជ្រូក ដាក់បាយជ្រូក និងចិញ្ចឹមសត្វផ្សេងទៀតដូចជា មាន់និងទា ទុកសម្រាប់ធ្វើម្ហូបទទួលភ្ញៀវបរទេសដែលមកស្នាក់នៅមន្ទីរប-១ ។ មន្ទីរប-១ ជាកន្លែងសម្ល្បរម្ហូបអាហារជាងគេ ប្រសិនបើម្ហូបសល់ច្រើនត្រូវបញ្ជូនទៅផ្សារថ្មីផ្គត់ផ្គង់កម្មកររោងចក្រតម្បាញ ។ នៅទីនេះ ដាង ហូបបាយបានឆ្អែត ថែមទាំងមានម្ហូបឆ្ងាញ់ទៀតផង ប៉ុន្តែគាត់មិនដែលត្រូវបានអនុញ្ញាតឲ្យមកលេងផ្ទះទេ ។ ដាង នៅចាំសម្តីដែល រឿន បានប្រាប់មកគាត់ថា «កុំអាលទៅលេងអី ត្រូវទៅតាមខេត្ត» ។ ដាង គិតថាដោយសារតែស្រុកកំណើតនៅឆ្ងាយពេក ទើបមិនងាយបានទៅលេង ព្រោះអ្នកដែលមានស្រុកកំណើតនៅខេត្តសៀមរាប និងកំពង់ធំ អាចមកលេងផ្ទះបាន ។ ដាង និយាយថា «បើរត់សុទ្ធតែងាប់ហើយ ព្រោះរកផ្លូវមិនឃើញ ហើយរត់ក៏ចេញមិនរួចដែរ» ។ ដាង ធ្លាប់សុំប្រធានមកជាមួយអ្នកស្រុកម្នាក់ឈ្មោះ ឈិន ជាអ្នកបើករថយន្តដឹកជញ្ជូនភូមិភាគនៅមន្ទីរ៤៤ ហើយចម្លើយដែលគាត់ទទួលបានគឺ «អត់បាន» ព្រោះខុសបទបញ្ជា ។

នៅឆ្នាំ១៩៧៧ រឿន បានផ្លាស់ ដាង ឲ្យទៅធ្វើការនៅផ្សារថ្មីក្រោមការគ្រប់គ្រងរបស់ ឈឿន និង ធី ជាអនុប្រធាន ។ ឈឿន បានប្រគល់ភារកិច្ចឲ្យ ដាង និងនារី១០នាក់ទៀតរៀបចំខោអាវនិងបោសសម្អាតផ្ទះសម្រាប់ទទួលភ្ញៀវចិននិងកូរ៉េ ។ នៅទីនេះ ដាង ខស្សរាហ៍បានទៅមើលការសម្តែងសិល្បៈជាមួយប្រតិភូបរទេសណាស់ ព្រោះភ្ញៀវបរទេសដែលមកតែងតែស្នើសុំឲ្យបុគ្គលិកពាណិជ្ជកម្មក្រុងអមដំណើរដើម្បីជូនទៅមើលការសម្តែងសិល្បៈ ។ សម្លៀកបំពាក់ដែលត្រូវស្លៀកទៅចូលរួមពេលនោះគឺនារីស្លៀកហូលពាក់អាវស និងបុរសស្លៀកខោបារាំងពាក់អាវស ។ សម្លៀកបំពាក់ទាំងនេះអង្គការចែកឲ្យស្លៀកតែពេលទទួលភ្ញៀវប៉ុណ្ណោះ បន្ទាប់មកប្រមូលបោកទឹកហាលឲ្យស្ងួតរួចយកទៅទុកនៅកន្លែងដើមវិញ ។ ក្រៅពីការងារនេះ ដាង ត្រូវទៅជួយជញ្ជូនសម្ភារៈចេញពីឃ្លាំងនៅគីឡូលេខ៦ទៀតដូចជា អំបិល ស៊ីម៉ងត៍ នៅពេលមានទឹកជំនន់ដែលមាន ខៀវ សំផន ខទ្ទេសនាមតាមមីក្រូឲ្យបងប្អូនឃុំយកសម្ភារៈចេញពីឃ្លាំងឲ្យទាន់ពេលវេលា ។ ដាង បានឃើញ អៀង សារី និង នួន ជា ផងដែរ ពេលទៅចូលមីទ្ទិងនៅស្តាតនិងបូរីកីឡាដោយមាន នួន ជា ជាអ្នកឡើងមកថ្លែងសុន្ទរកថាបើកកិច្ចប្រជុំ ។

នៅចុងឆ្នាំ១៩៧៧ ក្រោយពី កុយ ធួន និង ភី ដែលជាប្រធានធំរបស់គាត់ត្រូវបានអង្គការចាប់ខ្លួន កន្លះខែក្រោយមក ដាង ត្រូវបានបញ្ជូនឲ្យទៅចូលរួមមីទ្ទិងនៅផ្សារចាស់ជាមួយអ្នកនៅអង្គភាពចំនួន៥នាក់ ។ មីទ្ទិងនោះមានសមាជិកចូលរួមប្រហែលពី២០០ទៅ៣០០នាក់ ដោយលើកឡើងពីសកម្មភាពក្បត់របស់ កុយ ធួន និង ភី ។ ក្រោយពីមីទ្ទិងបញ្ចប់បានប្រហែលជាកន្លះខែ អង្គការបានចាប់ខ្លួន រឿន និង ប្រពន្ធ របស់ ភី ឈ្មោះ ឃីម យកទៅដាក់នៅព្រៃស ហើយតំណែងរបស់ ភី ត្រូវជំនួសដោយ ដន មកពីស្រុកព្រែកប្រសព្វ ។ មួយសប្តាហ៍ក្រោយមក ដាង បានទទួលសំបុត្រមួយច្បាប់មកពីមន្ទីរ៨៧០ ដែលមាននិរសារម្នាក់ជាអ្នកអានឲ្យស្តាប់ ។ សំបុត្រនោះមានអត្ថន័យថា ÷ «មិត្តនារី

ឈ្មោះ ជាង អង្គការផ្លាស់ទៅឲ្យបកគនៅផ្សារទួលទំពូង» ។ ជាង រៀបរាប់ថា អង្គការបានបំបែកសមាជិកនៅក្នុងក្រុមមិនឲ្យនៅជុំគ្នាទេ ដោយដកម្តងមួយៗទៅកាន់កន្លែងផ្សេងៗ ។ នៅកន្លែងបកគមានបែងចែកជាពីរកងធំ ហើយក្នុងកងនោះមានបែងចែកជាក្រុមតូចៗទៀត ។ កងធំទី១មាន ណាង ជាអ្នកគ្រប់គ្រង និងកងធំទី២មាន សី ដែលមានសមាជិកទាំងអស់ប្រហែល១០០នាក់ កម្លាំងប្រុសផ្សេងនិងកម្លាំងស្ត្រីផ្សេង ។ ជាង ស្ថិតនៅក្នុងកងលេខមួយក្រោមការគ្រប់គ្រងរបស់ប្រធានក្រុមឈ្មោះ នួន ត្រូវធ្វើការចាប់ពីម៉ោង៨ព្រឹកដល់ម៉ោង១០កន្លះ និងពីម៉ោង១១ដល់ម៉ោង៤រសៀល ។ លើសពីនេះទៅទៀត ជាង ព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួន ព្រោះឈ្មោះរបស់គាត់មានគូសប៊ិចក្រហមពីក្រោមគឺជាអ្នកមានទោស ។ និរសារម្នាក់ដែលគាត់មិនបានចាំឈ្មោះបានខ្សឹបប្រាប់គាត់ថា «ឈ្មោះមិត្តឯងត្រូវគូសប៊ិចក្រហមហើយ ដូច្នេះត្រូវខិតខំកសាងខ្លួន គេមិនទាន់សម្លាប់ចោលទេ បើយើងខំធ្វើការល្អ គេនឹងសម្រាលទោសយើង បើយើងខ្ជិល គេនឹងយកយើងទៅសម្លាប់ចោលដោយទម្លាក់ជ្រោះនៅភ្នំពេជ្រនិលហើយ» ។

ចុងឆ្នាំ១៩៧៨ តាវិទ្ធ ដែលជាប្រធានមន្ទីរពាណិជ្ជកម្មបានបើកការប្រជុំជាញឹកញាប់អំពីវៀតណាមចូលមកវាយដល់ខេត្តកំពង់ចាម ។ មិនយូរប៉ុន្មាន វៀតណាមវាយចូលដល់ភ្នំពេញ អ្នកនៅអង្គភាពទាំងអស់បាននាំគ្នារត់បែកផ្លូវគ្នាឆ្ពោះទៅកាន់ផ្ទះរៀងៗខ្លួន ចំណែក ជាង ជិះរថយន្តចេញតាមផ្លូវពោធិ៍ចិនតុងសំដៅទៅខេត្តពោធិ៍សាត់ ។ ស្នាក់នៅបាន២យប់ ជាង ក៏បានបន្តដំណើរទៅស្រុកសំឡូត ខេត្តបាត់ដំបង រួចរត់ឡើងភ្នំកាត់វាលស្រែ១០០សំដៅទៅព្រំដែនថៃ ហើយថៃបាននាំ ជាង ឆ្លងកាត់ផ្សារអារញ្ញទៅដាក់នៅខេត្តឧត្តរមានជ័យ ។ នៅទីនេះ ជាង បម្រើការឲ្យខ្មែរក្រហមដដែលដោយធ្វើជាកម្មករដឹកជញ្ជូនគ្រាប់កាំភ្លើង ដឹកស្បៀង និងសែងអ្នករបួសនៅពេលមានការប្រយុទ្ធគ្នា ។

នៅឆ្នាំ១៩៨២ ជាង បានរៀបការជាមួយបុរសម្នាក់ឈ្មោះ ខឿន ហើយអ្នកទាំងពីរលះបង់ការតស៊ូជាមួយខ្មែរក្រហមនាំគ្នាមករស់នៅជំរំសាយប៊ី ។ នៅឆ្នាំ១៩៩២ ជាង បានវិលត្រឡប់មករស់នៅភូមិកំណើតវិញ ។ សព្វថ្ងៃនេះ ជាង មានកូន៥នាក់ ប្រុសពីរនាក់និងស្រីបីនាក់ ។ **គាត លក្ខិណា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុFM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជារៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុFM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា និង គាត លក្ខិណា**

## ដំណឹងស្វែងរកកូនប្រុស

ខ្ញុំបាទឈ្មោះ ចាប រស់ អាយុ៨៤ឆ្នាំ បច្ចុប្បន្នរស់នៅភូមិត្បែង ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ ខ្ញុំបាទមានកូន៦នាក់គឺ÷ កូនទី១) ចាប ហេម (ស្លាប់) កូនទី២) ចាប ហ៊ឹ កូនទី៣) ចាប វ៉ន កូនទី៤) ចាប ខា កូនទី៥) ចាប រាំង និងកូនទី៦) ចាប រីម ។

សូមប្រកាសសួររកកូនទី៥ឈ្មោះ ចាប រាំង កាលសម័យប៉ុលពតឡើងកាន់អំណាច ចាប រាំង នៅកងកុមារត្រាំខ្នារហូតមកដល់ឆ្នាំ១៩៧៩ រាំង ត្រូវបានជម្លៀស ប៉ុន្តែមិនដឹងថាជម្លៀសទៅទីណា ។ បច្ចុប្បន្ន ចាប រាំង អាយុប្រហែល៤៥ឆ្នាំ ។

ប្រសិនបើបងប្អូនញាតិមិត្តណាបានទទួលដំណឹងអំពីឈ្មោះនេះ សូមមេត្តាជួយផ្តល់ដំណឹងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើឬទូរស័ព្ទលេខ (៨៥៥) ០១២ ២៨៣ ៥៤៧ ឬ (៨៥៥) ០១២ ៣៥៤ ៥០៧ ។ សូមអរគុណ ។

# ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ជំពូកទី៩
## មន្ទីរស-២១ (គុកទួលស្លែង)

គុកសំខាន់បំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានស្គាល់ថាជា“មន្ទីរសន្តិសុខស-២១” ។ អក្សរ“ស” តំណាងឲ្យពាក្យ “សន្តិសុខ” ហើយលេខ“២១” តំណាងឲ្យលេខសម្ងាត់ ។ គុកនេះមានទីតាំងស្ថិតនៅប៉ែកខាងត្បូងទីក្រុងភ្នំពេញ (សង្កាត់ទួលស្វាយព្រៃ) ។

មន្ទីរស-២១ជាគុកសម្ងាត់សម្រាប់ឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្មនិងសម្លាប់អ្នកទោសដែលត្រូវបានចាប់ខ្លួនបញ្ជូនមកដាក់នៅទីនេះ ។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦មក មិនមានអ្នកទោសណាម្នាក់ត្រូវបានដោះលែងទេ ។ ក្នុងចំណោមអ្នកទោសប្រហែលមួយម៉ឺនបួនពាន់នាក់ មានតែ១២នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកទាំងនេះត្រូវបានទុកជីវិត ព្រោះមានជំនាញពិសេសដែលមានប្រយោជន៍ដល់មន្ទីរស-២១ ។ អ្នកទាំងនេះជាជាងគំនូរ ជាងជួសជុលនាឡិកា និងជាងចម្លាក់ ។

### ១) អគារនៅមន្ទីរស-២១

មន្ទីរស-២១ជាអតីតវិទ្យាល័យពញាយ៉ាតដែលសាងសង់ឡើងក្នុងឆ្នាំ១៩៦២ ។ គុកនេះស្ថិតនៅលើផ្ទៃដីដែលមានបណ្តោយ៦០០ម៉ែត្រ និងទទឹង៤០០ម៉ែត្រ ។ នៅពីក្រោយរបងសាលានេះ មានអគារធ្វើពីឈើប្រក់ស្បូវពីរខ្នងដែលជាអតីតសាលាបឋមសិក្សាបឹងកេងកង ។ អគារទាំងអស់នេះបង្កើតបានទៅជាមន្ទីរស-២១ ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមន្ទីរស-២១ រុំព័ទ្ធដោយរបងស័ង្កសីនិងលួសបន្លាដែលមានភ្ជាប់ចរន្តអគ្គិសនី ។ នៅក្នុងបរិវេណគុក មានអគារធំៗបួន ។ បន្ទប់រៀនជាន់ក្រោមត្រូវបាន


បរិវេណគុកទួលស្លែង

បែងចែកទៅជាបន្ទប់តូចៗដែលមានទំហំ០,៨គុណនឹង២ម៉ែត្រ ដែលបន្ទប់មួយសម្រាប់ដាក់អ្នកទោសម្នាក់ ។ បន្ទប់រៀនជាន់ទីមួយដែលមានទំហំ៨គុណនឹង៦ម៉ែត្រប្រើសម្រាប់ដាក់អ្នកទោសរួម ។ នៅជាន់ទីពីរ បន្ទប់នីមួយៗមានទំហំធំជាងហើយដាក់អ្នកទោសពី៤០ទៅ៥០នាក់ ។ បន្ទប់មួយត្រូវបានប្រើជាការិយាល័យធ្វើការរបស់ ឌុច ដែលជាប្រធានគុក ហើយបន្ទប់មួយទៀតត្រូវបានប្រើប្រាស់ជាការិយាល័យឯកសារនិងការិយាល័យរដ្ឋបាលទូទៅ ។ ផ្ទះមួយចំនួនដែលនៅក្បែរគុកត្រូវបានប្រើធ្វើជាកន្លែងសួរចម្លើយនិងកន្លែងធ្វើទារុណកម្ម ។

## ២) អ្នកទោស

អ្នកទោសភាគច្រើននៅមន្ទីរស-២១ត្រូវបានចោទប្រកាន់ពីបទក្បត់បក្សឬក្បត់បដិវត្តន៍ ឬធ្លាប់បានធ្វើការឲ្យកម្មាភិបាលក្បត់ដែលត្រូវចាប់ខ្លួនរួចហើយ ។ មួយរយៈកាលកន្លងទៅ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមានការសង្ស័យនិងមានការមិនទុកចិត្តកាន់តែខ្លាំងឡើងៗចំពោះកម្មាភិបាលនិងកងទ័ពរបស់ខ្លួន ។ ឧទាហរណ៍ នៅខែតុលា ឆ្នាំ១៩៧៦ នៅក្នុងដំណើរការរឹតបន្តឹងសន្តិសុខជាតិ ប៉ុល ពត បានធ្វើការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់បក្សជាច្រើនរូបហើយយកទៅឃុំនៅមន្ទីរស-២១ ។ ថ្នាក់ដឹកនាំខ្មែរក្រហមយល់ថាសត្រូវមាននៅគ្រប់ទីកន្លែងទាំងអស់ក្នុងផ្ទៃប្រទេស ហើយបានធ្វើការចាប់ខ្លួនសមាជិកកុម្មុយនីស្តរបស់ខ្លួនជាច្រើននាក់ក្នុងមួយខែៗ ។ អ្នកទោសនៅមន្ទីរស-២១រួមមានទាំងជនបរទេសប្រហែលបួនរយនាក់ដែលភាគច្រើនជាជនជាតិវៀតណាម ។

កម្មាភិបាលដែលបម្រើការងារក្នុងគុកមួយចំនួនបានក្លាយជាអ្នកទោសនៅទីនោះដែរ ។ កម្មាភិបាលទាំងនោះបានសារភាពពីការខ្ជិលច្រអូសក្នុងការរៀបចំឯកសារធ្វើឲ្យខូចម៉ាស៊ីននិងឧបករណ៍ដទៃទៀត ឬវាយអ្នកទោសរហូតដល់ស្លាប់ក្នុងពេលសួរចម្លើយដោយគ្មានការអនុញ្ញាត ។ ចម្លើយសារភាពភាគច្រើននៅមន្ទីរស-២១ជាចម្លើយមិនពិត ពីព្រោះអ្នកទោសភាគច្រើនមិនបានប្រព្រឹត្តកំហុសអ្វីធ្ងន់ធ្ងរទេ ហើយអ្នកទោសបានសារភាពដើម្បីឲ្យតែរួចខ្លួនពីទារុណកម្មប៉ុណ្ណោះ ។

ឡៅ ចេស ហៅ ពៅ ប្រជាពលរដ្ឋមកពីខេត្តកំពង់ឆ្នាំងជាអតីតអ្នកយាមនៅមន្ទីរស-២១ ។ ពៅ បានរ៉ាយរ៉ាប់ពីប្រវត្តិរបស់គាត់នៅពេលនោះថាៈ នៅឆ្នាំ១៩៧៧ មិត្តភក្តិរបស់ខ្ញុំពីរនាក់ ហុង និង មឿន បានប្រព្រឹត្តកំហុស ហើយត្រូវបានយកទៅសម្លាប់ចោល ។ បន្ទាប់ពីនោះមក អង្គការចាប់ខ្លួនខ្ញុំ ព្រោះខ្ញុំជាមិត្តភក្តិរបស់អ្នកទាំងពីរ ហើយបញ្ជូនខ្ញុំទៅព្រៃស ។ ពួកគេបានសួរចម្លើយខ្ញុំក្រែងលោខ្ញុំមានជាប់ពាក់ព័ន្ធជាមួយអ្នកទាំងពីរ ប៉ុន្តែខ្ញុំឆ្លើយថា “អត់មានទេ” ។ អ្នកសួរចម្លើយឈ្មោះ សែម ផល ។ គាត់បានដឹងច្បាស់ណាស់ថាខ្ញុំធ្វើការនិងស្មោះត្រង់ ។ ដូច្នេះហើយខ្ញុំត្រូវបានដោះលែង ហើយត្រូវបានបញ្ជូនទៅកងពល៥០២ ហើយបើកឡានដឹកគ្រាប់ទៅតៃនិញទៅវៃជាមួយវៀតណាម ។


កម្មាភិបាលបម្រើការនៅមន្ទីរស-២១និងក្រុមគ្រួសារ

ជីវិតនៅមន្ទីរស-២១ពោរពេញទៅដោយភាពភ័យខ្លាច ។ យើងមិនហ៊ាននិយាយសើចលេងរកគ្នាទេ ។ យើងមិនទុកចិត្តអ្នកណាទាំងអស់ សូម្បីមិត្តភក្តិជិតស្និទ្ធរបស់យើងក៏ដោយ ។ គ្រប់គ្នាត្រូវខិតខំធ្វើការ ។ ក្រៅពីការយាមកាម យើងត្រូវដាំបន្លែនិងចិញ្ចឹមជ្រូក ។ យើងត្រូវប្រុងប្រយ័ត្នបំផុតពេលធ្វើការ ។ កំហុសបន្តិចបន្តួចដូចជាភ្លេច ឬដេក

នឹងជញ្ជាំងអាចធ្វើឲ្យយើងស្លាប់បាន ។

### ៣) បទបញ្ញត្តិសម្រាប់អ្នកទោស

បទបញ្ញត្តិនេះត្រូវបានបិទនៅលើជញ្ជាំងក្នុងបរិវេណគុក ។

### វិន័យសន្តិបាល (នគរបាលសន្តិសុខ) នៅមន្ទីរស-២១

១) សួរអីឆ្លើយហ្នឹង មិនបង្វែរសំណួររបស់អញ ។

២) មិនឲ្យដោះស្រាយ យកលេសនេះលេសនោះតាមគំនិតឯងលាក់ឬប្រកែកតមាត់មិនបានដាច់ខាត

៣) មិនឲ្យធ្វើល្ងង់ មិនយល់បញ្ហា ព្រោះឯងជាមនុស្សហ៊ានប្រឆាំងនឹងបដិវត្តន៍ ។

៤) សួរភ្លាម ឆ្លើយភ្លាម មិនឲ្យដឹអក់មួយនាទីឡើយ ។

៥) រឿងខុះខាត កំហុសបន្តិចបន្តួច ដូចជាសីលធម៌ ខូចនេះខូចនោះ ក៏មិនឲ្យនិយាយ រឿងខ្លឹមសារបដិវត្តន៍ ក៏មិនឲ្យនិយាយ ។

៦) រំពីឬឆក់ខ្សែភ្លើងមិនឲ្យស្រែកដាច់ខាត ។

៧) មិនឲ្យធ្វើអ្វីទាំងអស់ គឺអង្គុយស្ងៀមរង់ចាំបញ្ជាអញ អត់បញ្ជាកុំធ្វើ អញបញ្ជាអីធ្វើហ្នឹងភ្លាម ប្រកែកប្រិមប្រិយមិនបានទេ ។

៨) កុំយកលេសកម្ពុជាក្រោម បាំងមុខមាត់ក្បត់របស់អាឯងឲ្យសោះ ។

៩) គ្រប់បញ្ហាខាងលើ មិនធ្វើតាម គឺមួយថ្ងៃរងរំពាត់ ខ្សែភ្លើងឆក់រាប់មិនឈ្នះទេ ។

១០) ប្រឆាំងវិន័យអញមួយចំណុច ត្រូវរងរំពាត់ដប់រំពាត់ ឬឆក់ខ្សែភ្លើងប្រាំឆាប់ ។

បទបញ្ញត្តិមួយទៀតសម្រាប់អ្នកទោសត្រូវបានបិទនៅអគារ «ខ-គ-ឃ» ។

### បម្រាមនៅអគារ "ខ-គ-ឃ"

១) មិនឲ្យនិយាយទាក់ទងគ្នាដាច់ខាត ទោះជាស្គាល់ ឬមិនស្គាល់ ។

២) បើចង់ធ្វើអ្វី ត្រូវមានការអនុញ្ញាតពីអ្នកយាម ។

៣) មិនឲ្យព្រួងរ៉ាងទឹកខ្វែងនៅ ។

៤) ពេលអ្នកយាម ឬអ្នកផ្សេងៗចូល ត្រូវដេកទាំងអស់ ។

៥) ពេលដេក ត្រូវដាក់ដៃក្រោយខ្នង ។ កុំសេរី ។

## ៤. ស្ថានភាពនៅក្នុងមន្ទីរស-២១

នៅពេលបញ្ជូនទៅដល់មន្ទីរស-២១ អ្នកទោសទាំងអស់ត្រូវបានថតរូបនិងតម្រូវឲ្យសរសេរប្រវត្តិរូបលម្អិតចាប់តាំងពីកុមារភាពរហូតដល់ថ្ងៃចាប់ខ្លួន ។ អ្នកទោសត្រូវដោះសម្លៀកបំពាក់ចេញទុកតែខោក្នុងមួយ ហើយសម្ភារដាប់ខ្លួនទាំងប៉ុន្មានត្រូវបានរឹបអូសយក ។ បន្ទាប់មកអ្នកទោសនឹងត្រូវនាំយកទៅឃុំក្នុងបន្ទប់ ដែលនៅទីនោះអ្នកទោសទាំងនេះត្រូវដាក់ខ្នោះជើងដែលមានចង្កាប់ដោយច្រវាក់ទៅនឹងជញ្ជាំងឬឥដ្ឋ ។ ចំណែកអ្នកទោសឃុំនៅបន្ទប់ធំត្រូវបានដាក់ខ្នោះជើងដោយរនុកដែកវែងមួយរួមគ្នា ។ ខ្នោះជើងទាំងនេះត្រូវភ្ជាប់ទៅនឹងរនុកដែកឆ្លាស់គ្នាដូច្នេះអ្នកទោសត្រូវដេកដាក់ក្បាលទល់គ្នា ។ អ្នកទោសត្រូវដេកផ្ទាល់នឹងឥដ្ឋ ដោយគ្មានកន្ទេល មុង ឬភួយទេ ។ អ្នកទោសត្រូវបានហាមប្រាមមិនឲ្យនិយាយរកគ្នា ។

វ៉ាន់ ណាត អ្នកនៅរស់រានមានជីវិតម្នាក់បានរៀបរាប់ពីជីវិតរបស់លោកនៅក្នុងមន្ទីរស-២១ថា ៖ នៅក្នុងមន្ទីរស-២១ ខ្ញុំត្រូវបានដាក់ខ្នោះជើងភ្ជាប់ទៅនឹងរនុកដែកវែងមួយជាមួយអ្នកទោសជាងសាមសិបនាក់ទៀត ។ ខ្មែរក្រហមឲ្យយើងហូបពីរដងក្នុងមួយថ្ងៃ ។ អ្នកទោសគ្រប់រូបទទួលបានបបរបបរបួនស្លាបព្រាតូច និងសម្លលាយស្លឹកឈើខ្លះ ។ ការនិយាយគ្នាត្រូវបានហាមឃាត់ដាច់ខាត ។ ប្រសិនបើអ្នកណាម្នាក់ចង់ក្រោកអង្គុយឬផឹកទឹកត្រូវសុំការអនុញ្ញាតពីអ្នកយាមជាមុនសិន ។ ការធ្វើអ្វីមួយដែលមិនមានការអនុញ្ញាតពីអ្នកយាម នឹងត្រូវទទួលការវាយដំជាទម្ងន់ ។ គេឲ្យយើងមុជទឹករៀងរាល់បួនថ្ងៃម្តង ។ គេយកទុយយ៉ូមកបាញ់ជះពីមាត់ទ្វារ ។ ប្រសិនបើយើងនៅឆ្ងាយពីមាត់ទ្វារយើងនឹងមិនបានទទឹកគ្រប់គ្រាន់ទេ ។ ជារៀងរាល់ថ្ងៃ អ្នកទោសត្រូវបាននាំយកទៅសួរចម្លើយ ហើយមួយចំនួនមិនដែលឃើញត្រឡប់មកវិញទេ ប៉ុន្តែយើងឃើញអ្នកទោសថ្មីៗត្រូវបាននាំចូលមកជំនួសវិញ ។

នៅម៉ោងបួនកន្លះព្រឹក អ្នកទោសត្រូវស្រាតខោដើម្បីឲ្យអ្នកយាមត្រួតពិនិត្យ ។ អ្នកយាមត្រូវពិនិត្យមើលក្រែងលោខ្នោះជើងរលុង ឬក្រែងលោអ្នកទោសមានលាក់វត្ថុអ្វីដែលគេអាចប្រើដើម្បីធ្វើអត្តឃាត ។ មួយរយៈកាលកន្លងមកមានអ្នកទោសជាច្រើនបានសម្លាប់ខ្លួនឯង ដូច្នេះអ្នកយាមមានការប្រុងប្រយ័ត្នណាស់ក្នុងការត្រួតពិនិត្យមើលខ្នោះជើងនិងបន្ទប់ ។

ស្ថានភាពរស់នៅក្នុងមន្ទីរស-២១មានភាពកខ្វក់ដែលធ្វើឲ្យអ្នកទោសភាគច្រើនកើតស្រែង កមរមាស់ និងចៃ ។ មិនមានថ្នាំព្យាបាលទេនៅក្នុងគុក ។ កម្មាភិបាលពេទ្យនៅមន្ទីរស-២១សុទ្ធតែមិនបានទទួលការហាត់រៀនត្រឹមត្រូវ ហើយធ្វើការព្យាបាលគ្រាន់តែដើម្បីពន្យារការស្លាប់របស់អ្នកទោស បន្ទាប់ពីរងរបួសធ្ងន់ក្នុងអំឡុងពេលសួរចម្លើយប៉ុណ្ណោះ ។

អ្នកទោសត្រូវបានបិទមុខជិត ពេលត្រូវនាំពីកន្លែងឃុំឃាំងទៅកន្លែងសួរចម្លើយ ។ អ្នកយាមនិងអ្នកទោសមិនអនុញ្ញាតឲ្យនិយាយគ្នាឡើយ ។ ជាងនេះទៅទៀត បុគ្គលិកដែលនៅក្រុមផ្សេងគ្នាក៏មិនត្រូវបានអនុញ្ញាតឲ្យធ្វើការទាក់ទងគ្នាដែរ ។

## ៤) ការសួរចម្លើយ

វិធីសាស្ត្រព្រៃផ្សៃជាច្រើនត្រូវបានប្រើដើម្បីសួរចម្លើយនៅមន្ទីរស-២១ ។ អ្នកទោសត្រូវបានវាយដោយដៃ ដំបងឬមែកឈើ ។ជួនកាលអ្នកសួរចម្លើយវាយអ្នកទោសនឹងខ្សែភ្លើងឬឆក់ខ្សែភ្លើង ។ វិធីសាស្ត្រធ្វើទារុណកម្មផ្សេងទៀតដែលប្រើនៅមន្ទីរស-២១មានអុចភ្លើងបារី បង្ខំឲ្យស៊ីលាមក ឬដឹកទឹកនោមយកម្ជុលចាក់ចូលសាច់ និងព្យួរដៃ ឡើងលើពេញមួយថ្ងៃ ឬព្យួរជើងឡើងលើដាំក្បាលចុះក្រោម ។ អ្នកទោសខ្លះទៀតត្រូវបានឆូតសាច់នឹងកាំបិត ឬយកថង់ខ្ទប់ច្រមុះ ។ វិធីសាស្ត្រមួយចំនួនទៀតដែលប្រើសម្រាប់ចម្រាញ់យកចម្លើយសារភាព រួមមានដកក្រចកដៃហើយចាក់អាកុលពីលើ ឬជ្រមុជទឹក ។ អ្នកទោសមួយចំនួនត្រូវស្លាប់ក្នុងអំឡុងពេលធ្វើទារុណកម្ម ។

អ្នកទោសស្រីត្រូវបានធ្វើទារុណកម្មដោយកាត់ដោះ ឬបង្ខំឲ្យស្ត្រីទាំងនោះដោះខោអាវចេញ ។ អ្នកទោសស្រីមួយចំនួនត្រូវអ្នកសួរចម្លើយចាប់រំលោភ ទោះជាការរំលោភផ្លូវភេទផ្ទុយនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យក៏ដោយ ។ អ្នកសួរចម្លើយដែលត្រូវរកឃើញថាបានប្រព្រឹត្តអំពើនេះត្រូវបានសម្លាប់ចោល ។

នៅក្នុងចម្លើយសារភាព អ្នកទោសត្រូវរៀបរាប់ពីប្រវត្តិរូបផ្ទាល់ខ្លួន ។ ប្រសិនបើជាសមាជិកបក្ស អ្នកទោសត្រូវបង្ហាញថ្ងៃដែលខ្លួនចូលបដិវត្តន៍ និងរៀបរាប់ពីកិច្ចការដែលខ្លួនបានធ្វើ ។ បន្ទាប់មកអ្នកទោសត្រូវរៀបរាប់ពីសកម្មភាពក្បត់របស់ខ្លួនតាមលំដាប់លំដោយ ។ ក្នុងផ្នែកទីបីនៃចម្លើយសារភាព អ្នកទោសបានរៀបរាប់ពីការរួមគំនិតក្បត់មិនបានសម្រេចរបស់ខ្លួន ឬកិច្ចសន្ទនាក្បត់ផ្សេងៗ ។ នៅចុងបញ្ចប់នៃចម្លើយសារភាព អ្នកទោសនឹងរាយឈ្មោះជនក្បត់ដែលត្រូវជាមិត្តភក្តិ មិត្តរួមការងារ ឬមនុស្ស


កម្មាភិបាលបម្រើការនៅក្នុងមន្ទីរសន្តិសុខហូបអាហាររួមគ្នា

*ដែលអ្នកទោសធ្លាប់ស្គាល់ ។ បញ្ជីខ្លះមានរាយឈ្មោះមនុស្សដែលពាក់ព័ន្ធរហូតដល់ទៅជាងមួយរយនាក់ ។ អ្នកដែលមានឈ្មោះក្នុងបញ្ជីភាគច្រើនត្រូវបានចាប់យកមកសួរចម្លើយ ។*

*ដោយសារតែទារុណកម្មនៅមន្ទីរស-២១សាហាវព្រៃផ្សៃពេក អ្នកទោសតែងតែសារភាពនូវអ្វីដែលខ្លួនអាចគិតឃើញ ទោះជាចម្លើយនោះខុសក៏ដោយ ។ អ៊ឹ សំណាង កម្មករ រទេះភ្លើង បានសារភាពពីកិច្ចសន្ទនាក្បត់របស់ គុន កម្មករជួសជុលរទេះភ្លើងថា៖ គុន ជាកម្មករចាស់ ។ វាមិនពេញចិត្តនឹងបដិវត្តន៍ដូចគ្នាវាឯទៀតដែរ ។ រាល់ថ្ងៃវាតែងឃោសនា ដូចតទៅនេះ ÷*

- *ពួកអាអស់នេះ ដល់ឯងបង្រៀនបច្ចេកទេសវាចេះច្រើនចង់ដេញក្បាលឯងចេញ ។*
- *ឲ្យតែយ៉ាងនេះចុះ ថ្ងៃណាមួយពួកហ្អែងត្រូវលោយដូចអំបិលត្រូវទឹក ។*
- *សព្វថ្ងៃ កម្មករចាស់ប្រៀបដូចសំរាមក្រោមបាតជើងវា វាចង់ជាន់ពេលណាក៏បានស្រេចតែនឹងចិត្តវា ។*
- *ពួកវាពូកែខាងអំនួតនិងទ្រឹស្តី តែខ្ជិលធ្វើការ ។*
- *ធ្វើការគ្រាន់តែដូរបាយស៊ីបានហើយ ខូចស្អីក៏ខូចទៅ ។*

*ក្រៅពីនេះ វាពង្រឹងខ្លួនត្រៀមវាយបដិវត្តន៍ ពេលណាមានទ័ពមកពីក្រៅ ។*

*ជា ហឿង សាស្ត្រាចារ្យជម្លៀសទៅស្រុកបារាយណ៍ ខេត្តកំពង់ធំ បានសារភាពពីសកម្មភាពក្បត់របស់ តាំង ឡុញ អតីតអ្នកធ្វើការនៅក្រសួងប្រៃសណីយ៍ ក្រោយមកធ្វើទាហានពាក់សក្តិពីរថា ÷*

*ជម្លៀសទៅដល់ភូមិកំណើតវិញ តាំង ឡុញ ដើរប្រមូលជើងដើម្បីប្រឆាំងបដិវត្តន៍ ។ វាបានធ្វើវិទ្ធង្សនកម្មប្រឆាំងយើងជាបន្តបន្ទាប់ ។*

- *ណែនាំឲ្យបក្សពួកលែងគោឲ្យស៊ីស្រូវ ។*
- *ណែនាំឲ្យបក្សពួកកម្ទេចចានតិចៗជាបណ្តើរៗ ។*
- *ណែនាំឲ្យសម្លាប់ទាម្តងមួយឬពីរ ហើយរាយការណ៍ថាងាប់ ។*
- *យកដុះខ្លួនជាកន្ទែងសរសេរត្រាក់ ហើយបានយកត្រាក់ទៅបាចតាមការដ្ឋាន ។*

## ៦) *របនាសម្ព័ន្ធចាត់តាំងនៅក្នុងមន្ទីរស-២១*

*បុគ្គលិកជាងមួយពាន់នាក់នៅបម្រើការក្នុងមន្ទីរស-២១ ។ ក្នុងនោះមនុស្សប្រហែលបី-បួនរយនាក់បម្រើការជាបុគ្គលិកទូទៅ ដោយរួមទាំងអ្នកដាំបន្លែបង្ការសម្រាប់បម្រើសេចក្តីត្រូវការក្នុងគុកផង ។ ក្រៅពីនេះ ជាកងកម្លាំងធ្វើការ ក្នុងបរិវេណគុកដែលធ្វើការនៅក្នុងអង្គភាពមួយក្នុងចំណោមអង្គភាពទាំងបីរបស់គុក និងរួមទាំងបុគ្គលិកការិយាល័យផង ។*

*អង្គភាពនៅមន្ទីរស-២១រួមមាន អង្គភាពរៀបចំឯកសារ អង្គភាពការពារ និងអង្គភាពសួរចម្លើយ ។ អង្គភាពរៀបចំឯកសារមាននាទីចម្លងចម្លើយសារភាពចេញពីកាសែ្សត វាយអត្ថបទចម្លើយសារភាពរបស់អ្នកទោស សង្ខេបអត្ថបទ ចម្លើយសារភាព និងរៀបចំទុកដាក់ឯកសារ ។ បុគ្គលិកនៅក្នុងអង្គភាពរងផ្នែកថតរូបមាននាទីថតរូបអ្នកទោសពាក់កណ្តាលខ្លួន ពេលអ្នកទោសមកដល់ភ្លាម ថតរូបអ្នកទោសដែលស្លាប់ក្នុងបន្ទប់ឃុំឃាំងនិងថតរូបអ្នកទោសសំខាន់ៗក្រោយពេលសម្លាប់ហើយ ។ រូបថតរាប់ពាន់សន្លឹកនៅសេសសល់រហូតមកដល់សព្វថ្ងៃ ប៉ុន្តែរាប់ពាន់សន្លឹកផ្សេងទៀតបានបាត់បង់ ។*

*អង្គភាពការពារគឺជាអង្គភាពធំបំផុតនៅមន្ទីរស-២១ ។ កងសន្តិសុខ ក្នុងអង្គភាពនេះភាគច្រើនជាក្មេងជំទង់ ។ កងសន្តិសុខភាគច្រើនមានការលំបាកក្នុងការគោរពបទបញ្ជាដ៏តឹងតែងរបស់អង្គភាព ។ កងសន្តិសុខមិនអនុញ្ញាតឲ្យនិយាយជាមួយអ្នកទោស សួរឈ្មោះ ឬវាយតប់អ្នកទោសឡើយ ។ កងសន្តិសុខត្រូវបានហាមឃាត់មិនឲ្យលួចមើលឬលួចស្តាប់ការសួរចម្លើយ ហើយត្រូវគោរពឲ្យបានខ្ជាប់ខ្ជួននូវបទបញ្ជាសាមសិបចំណុចដែលហាមប្រាមមិនឲ្យលួច ដេក អង្គុយលេង ឬផ្អែកជញ្ជាំងក្នុងពេលធ្វើការងារ ។ កងសន្តិសុខត្រូវដើរទៅ ដើរមក ធ្វើការយាមល្បាត និងពិនិត្យពិច័យអ្វីៗគ្រប់យ៉ាងដោយប្រុងប្រយ័ត្នបំផុត ។ កងសន្តិសុខណាដែលបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរនឹងត្រូវចាប់ខ្លួន សួរចម្លើយ យកទៅឃុំឃាំងនិងយកទៅសម្លាប់ចោល ។ មនុស្សភាគច្រើនធ្វើការនៅមន្ទីរស-២១ មានការភ័យខ្លាចយ៉ាងខ្លាំងចំពោះកំហុសផ្សេងៗដែលអាចកើតឡើង និងភ័យខ្លាចចំពោះទារុណកម្ម និងការសម្លាប់ ។*

*អង្គភាពសួរចម្លើយបែកចេញជាក្រុមរងក្តៅ ក្រុមរងត្រជាក់*

និងក្រុមវង់អង្កៀម ។ ក្រុមក្តៅ (ជួន កាលហៅ កង់កាច) អាចធ្វើទារុណកម្មក្នុងពេលសួរចម្លើយបាន ។ ផ្ទុយទៅវិញ ក្រុមត្រជាក់ (ជួនកាល ហៅ កង់ស្លូត) មិនត្រូវបានអនុញ្ញាតឲ្យធ្វើទារុណកម្មដើម្បីសួរចម្លើយទេ ។ ប្រសិនបើក្រុមនេះមិនអាចធ្វើឲ្យអ្នកទោសសារភាព គេនឹងបញ្ជូនអ្នកទោសទៅក្រុមក្តៅ ។ ក្រុមអង្កៀមធ្វើការជាមួយករណីធ្ងន់ធ្ងរនិងករណីសំខាន់ៗ ។

ការសួរចម្លើយមានរយៈពេលវែង ។ ជួនកាលដំណើរការនេះបន្តធ្វើរហូតដល់យប់អធ្រាត្រ ។ អ្នកសួរចម្លើយទាំងនោះចេះអាន និងចេះសរសេរ ហើយជាទូទៅមានអាយុប្រហែលជាជាងម្ភៃឆ្នាំ ។

## ៧) ថ្នាក់ដឹកនាំមន្ទីរស-២១

មន្ទីរស-២១ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិដឹកនាំដោយ សុន សេន (ហៅ សមមិត្តខៀវ) ។ មុនពេលចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា សុន សេន ធ្លាប់បានទៅសិក្សានៅប្រទេសបារាំងនិងធ្លាប់ធ្វើជាគ្រូបង្រៀន ។

មេដឹកនាំជាន់ខ្ពស់នៅមន្ទីស-២១រួមមាន ឌុច (ប្រធានមន្ទីរ ស-២១) , ឃឹម វ៉ាត ហៅ ហ៊ី (អនុប្រធានមន្ទីរ ស-២១) , ប៉េង (បញ្ជាការលើអ្នកយាម) , ចាន់ (ប្រធានអង្គភាពសួរចម្លើយ) និង ប៉ុន (អ្នកសួរចម្លើយ) ។ ប៉ុន ជាអ្នកសួរចម្លើយអ្នកទោសសំខាន់ៗជាច្រើនរូបរួមមាន កែវ មាស, ណៃ សារ៉ាន់, ហ៊ូ នឹម, ទីវ អុល និង ភោគ ឆាយ ។ មេដឹកនាំគុកទាំងនេះសុទ្ធតែជាអតីតគ្រូបង្រៀន ។

## ៨) ការសម្លាប់នៅមន្ទីរស-២១

អ្នកទោសភាគច្រើននៅមន្ទីរស-២១ជាប់ឃុំឃាំងនៅទីនោះរយៈពេលពីរទៅបីខែ ។ ទោះជាយ៉ាងនេះក្តី កម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់មួយចំនួនជាប់ឃុំឃាំងនៅទីនោះរាប់ខែ ហើយចម្លើយសារភាពវែងរាប់រយទំព័រ ។ បន្ទាប់ពីត្រូវនាំខ្លួនមកដល់មន្ទីរស-២១បានពីរ-បីថ្ងៃ អ្នកទោសទាំងអស់នឹងត្រូវនាំយកទៅសួរចម្លើយដោយគ្មានខ្វល់ខ្វាយគិតគូរពីការពិតអ្វីឡើយ ។ អ្នកទោសទាំងអស់ត្រូវតែសារភាពថាខ្លួនគឺជាជនក្បត់បដិវត្តន៍ និងធ្លាប់បានប្រព្រឹត្តបទល្មើសទាំងឡាយដែលអ្នកសួរចម្លើយសូត្រឲ្យថាតាម ។ បន្ទាប់ពីការសួរចម្លើយចប់សព្វគ្រប់ហើយ អ្នកទោសនឹងត្រូវនាំយកទៅ "កម្ទេចចោល" ដែលជាពាក្យប្រើក្នុងរបបកម្ពុជាប្រជាធិបតេយ្យជំនួសឲ្យពាក្យ"សម្លាប់" ។

នៅឆ្នាំទីមួយនៃប្រតិបត្តិការរបស់មន្ទីរស-២១ សាកសពអ្នកទោសត្រូវបានកប់នៅក្បែរមន្ទីរ ។ ប៉ុន្តែ ចាប់តាំងពីចុងឆ្នាំ ១៩៧៦មក មិនមានដីទំនេរសម្រាប់កប់ខ្មោចនៅក្បែរគុកទៀតទេ ហេតុដូច្នេះហើយអ្នកទោសត្រូវបានដឹកតាមឡាននៅពេលយប់ទៅកាន់បឹងជើងឯក (ស្ថិតនៅចម្ងាយ១៣គីឡូម៉ែត្រ ភាគនិរតីទីក្រុងភ្នំពេញ) ដែលនៅកន្លែងនោះអ្នកទោសត្រូវបានវាយនឹងត្បូងចប ខ្នងពូថៅ ឬដំបង ឬបាញ់សម្លាប់ចោលតែម្តង ។ ជាទូទៅនៅពេលដែលអ្នកទោសត្រូវបានសម្លាប់ហើយ កងទ័ពដែលដឹកអ្នកទោសពីមន្ទីរស-២១ ទៅបានកប់សាកសពទាំងនេះនៅក្នុងរណ្តៅសាកសពរួមដែលរណ្តៅតូចមានប្រហែលប្រាំមួយនាក់ ហើយរណ្តៅធំមានសាកសពរហូតដល់ទៅជាងមួយរយនាក់ ។


កម្មាភិបាលខ្មែរក្រហម

មន្ទីរស-២១ និង បឹងជើងឯកត្រូវបានប្រែក្លាយទៅជាសារមន្ទីរប្រល័យពូជសាសន៍ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាក្រោមជំនួយឧបត្ថម្ភរបស់វៀតណាមក្នុងឆ្នាំ១៩៧៩ ។ **(នៅមានត)**

**ឌី ខាំបូលី**

# គុកខ្មែរក្រហម

## ខេត្តតាកែវ

### ស្រុកបាទី

#### ១) មន្ទីរសន្តិសុខវត្តកកោះ

វត្តសូភី ហៅ កកោះ មានទីតាំងស្ថិតនៅក្នុងភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី បានក្លាយជាមន្ទីរសន្តិសុខនិងទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហមតាំងពីឆ្នាំ១៩៧៣ ។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះជាប្រជាជនមូលដ្ឋាន ។ សូរ ញ៉ អាយុ ៦៩ឆ្នាំ បច្ចុប្បន្នមានទីលំនៅ នៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ជាអតីតអ្នកទោសដែលជាប់ក្នុងមន្ទីរសន្តិសុខវត្តកកោះកាលពីចុងឆ្នាំ១៩៧៣ បាននិយាយថា គាត់ត្រូវកងសន្តិសុខចាប់ខ្លួនពីបទដេរប្រទេចបក្ខពួកខ្មែរក្រហម ។ នៅពេលដែល ញ៉ ជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខវត្តកកោះ គាត់បានឃើញមនុស្សជាប់ខ្នោះពីរខ្សែដែលក្នុងមួយខ្សែៗមានប្រហែល២០នាក់ ។

ប្រជាជនដែលរស់នៅក្បែរនិងជុំវិញវត្តនោះ ត្រូវបានជម្លៀសចេញទៅកាន់តំបន់ឆ្ងាយៗ ។ ការស្លាប់និងការសម្លាប់អ្នកទោសនៅមន្ទីរសន្តិសុខវត្តកកោះ បានកើតឡើងនៅក្រោយពេលមន្ទីរនេះបង្កើតឡើងបន្តិច ។ សូរ ញ៉ និយាយថា អ្នកទោសខ្លះបានស្លាប់ដោយសារការបង្អត់អាហារ ការធ្វើទារុណកម្មខ្លាំងហួសប្រមាណ ហើយអ្នកទោសខ្លះទៀតត្រូវកងឈ្លបសម្លាប់យ៉ាងព្រៃផ្សៃ ។

ពុត ជាប្រធានគ្រប់គ្រងមន្ទីរសន្តិសុខវត្តកកោះដំបូងគេបង្អស់ ។ ពុត បានដាក់បញ្ជាឲ្យកងសន្តិសុខប្រាប់អ្នកទោសដែលត្រូវនាំយកទៅសម្លាប់ថា ត្រូវផ្លាស់ប្តូរទៅកាន់«តំបន់» ដើម្បីទទួលការកិច្ចថ្មីមួយទៀត ។ សូរ ញ៉ រំឭកថា អ្នកទោសគ្រប់គ្នាភ័យខ្លាចខ្លាំងណាស់ចំពោះពាក្យថា «ត្រូវផ្លាស់ទៅកាន់តំបន់» ព្រោះដឹងថាមុខជាស្លាប់មិនខាន ។

នៅដើមឆ្នាំ១៩៧៤ សូរ ញ៉ ត្រូវបានដោះលែងឲ្យមកកាន់ទីលំនៅវិញ ប៉ុន្តែគាត់ត្រូវសន្យាជាមួយ ពុត ថា មិនប្រាប់គេឯងឲ្យដឹងពីការសម្លាប់មនុស្ស ការហូបមិនឆ្អែត និងការធ្វើទារុណកម្មអ្នកទោសនៅក្នុងមន្ទីរសន្តិសុខវត្តនេះឡើយ ។



មន្ទីរសន្តិសុខវត្តកកោះ

ក្រោយថ្ងៃជ័យជម្នះ១៧ ខែមេសា ឆ្នាំ១៩៧៥ សន្តិសុខបានចាប់អ្នកទោសបញ្ជូនមកឃុំឃាំងជាបន្តបន្ទាប់ ។ ប៊ុន ហ៊ីង ដែលមានស្រុកកំណើតនៅឃុំចំបក់ ស្រុកបាទី បច្ចុប្បន្នរស់នៅសហរដ្ឋអាមេរិកបានរាយការណ៍ឲ្យដឹងពីទីកន្លែងឃុំឃាំងសួរចម្លើយនិងសម្លាប់មនុស្សនៅមន្ទីរសន្តិសុខវត្តសូភីហៅវត្តកកោះថា «នៅឆ្នាំ១៩៧៥ កងសន្តិសុខបានសម្លាប់មនុស្សយ៉ាងច្រើននៅក្នុងបរិវេណមន្ទីរសន្តិសុខវត្តកកោះ ។ កាលនោះប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញដែលធ្វើដំណើរឆ្លងកាត់តាមផ្លូវជាតិលេខ២ និងលេខ៣ ត្រូវកងសន្តិសុខ

កៀរបញ្ចូលមកដាក់នៅវត្តកកោះនិងវត្តទ្រព្យគរ ។ ប្រជាជនជម្លៀសទាំងនោះត្រូវបានសម្លាប់ទម្លាក់ក្នុងស្រះទឹកជុំវិញព្រះវិហារវត្តកកោះដែលមានទំហំប្រមាណជា៥០ម៉ែត្រការេនិងជម្រៅប្រហែល៤ម៉ែត្រ នៅប៉ែកខាងជើង ខាងកើត និងខាងត្បូងបរិវេណវត្ត ។ សាកសពដែលកងសន្តិសុខសម្លាប់នៅជុំវិញបរិវេណវត្តកកោះ មានទាំងក្មេង ចាស់ ប្រុស ស្រីរាប់ពាន់នាក់គរលើគ្នាកម្ពស់ប្រមាណ២ម៉ែត្រ ។ ការសម្លាប់ប្រជាជនជម្លៀសនេះបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៨រហូតដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥ ។ ប៊ុន ហ៊ីង បានឲ្យដឹងថាឈ្មោះ អ៊ុយ មេបញ្ជាការរងភូមិភាគនិរតីជាអ្នកសម្លាប់មនុស្សច្រើនជាងគេ ។

ចាប់ពីឆ្នាំ១៩៧៦ដល់ចុងឆ្នាំ១៩៧៨ ការសម្លាប់និងការចាប់មនុស្សមកដាក់ឃុំឃាំងចេះតែបន្តមកទៀត ។ មន្ទីរសន្តិសុខវត្តកកោះមានប្រជាជនជាប់ឃុំឃាំងកាន់តែច្រើន ទាំងប្រជាជនមូលដ្ឋាននិងប្រជាជនជម្លៀស ។ ទឹម គុណ និង មុយ ចក់ ដែលជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តកកោះតាំងពីឆ្នាំ១៩៧៦ដល់ចុងឆ្នាំ១៩៧៨បានប្រាប់ថា គាត់ជាប្រជាជនមូលដ្ឋានដែលប្រព្រឹត្តខុសអង្គការវិន័យបន្តិចបន្តួច ។ គាត់ដឹងច្បាស់ថា អ្នកទោសស្ទើរទាំងអស់ត្រូវកងសន្តិសុខនាំយកទៅសម្លាប់នៅប៉ែកខាងកើតខាងលិច ខាងជើង ខាងត្បូងព្រះវិហារ ខាងក្នុងបរិវេណសាលាបឋមសិក្សាសូភី និងនៅមាត់ត្រពាំងខាងជើងសាលារៀន ។ ការសម្លាប់មនុស្សច្រើនប្រព្រឹត្តទៅនៅម៉ោង៣រសៀល ដោយមានចាក់ភ្លេងពុទ្ធខ្លាំងៗដើម្បីបន្លប់សំឡេងស្រែករបស់អ្នកទោស ។ ខ្មែរក្រហមបានប្រើដំបងត្បូងចបនិងដែកក្រៀវទេះជាឧបករណ៍សម្លាប់មនុស្ស ។

នៅឆ្នាំ១៩៧៨ មុនពេលសមមិត្ត ពុត ត្រូវអង្គការផ្លាស់ចេញហើយជំនួសដោយសមមិត្ត កន (ប្អូនប្រុសរបស់គណៈស្រុកបាទីឈ្មោះ សមមិត្ត ជឹម) អ្នកទោសជាច្រើនត្រូវកងឈ្លបយកទៅសម្លាប់ចោល ។ ពុត ត្រូវអង្គការដកចេញពីតំណែងពីព្រោះរឿងខុសសីលធម៌ជាមួយនារីម្នាក់ ។ ។

ទឹម គុណ និយាយថា ក្នុងពេលដែលធ្វើជាប្រធានគ្រប់គ្រងមន្ទីរសន្តិសុខនិងកន្លែងសម្លាប់វត្តកកោះ គណៈស្រុកឈ្មោះ ជឹម បានរៀបចំផែនការឲ្យកងឈ្លបអនុវត្តការសម្លាប់មនុស្ស ។ មុយ ចក់ បានប្រាប់ថា នៅពេលដែលគណៈស្រុក ជឹម ជិះម៉ូតូសេអឹល ៩០ពណ៌ក្រហមចូលក្នុងវត្តកកោះម្តងៗ និងក្រោយពេលដែល ជឹម ចាកចេញគឺប្រាកដជាឆ្នាំគុកបញ្ជាឲ្យហៅអ្នកទោសមកសួរចម្លើយនិងយកទៅសម្លាប់ភ្លាមៗ ។ ការសួរចម្លើយមិនមែនសួរពីប្រវត្តិធ្វើការពីមុននោះទេ ។ តុសួរចម្លើយស្ថិតនៅចម្ងាយតែ៥ម៉ែត្រប៉ុណ្ណោះ ពីរណ្តៅដែលត្រូវសម្លាប់ ។ ពេលសួរចម្លើយ ពុត បានបើកបញ្ជីមួយមើលថាតើឈ្មោះអ្នកទោសណាខ្លះដែលត្រូវសម្លាប់និងឈ្មោះណាខ្លះដែលត្រូវទុក ។ បញ្ជីដែល ពុត បើកហៅឈ្មោះអ្នកទោសនៅពេលសម្លាប់សុទ្ធតែមានគូសប៊ិចក្រហមឬសញ្ញាខ្វែងជើងក្អែក នៅខាងចុងឈ្មោះនោះដោយប៊ិចក្រហមដដែល ។ មុយ ចក់ បន្តថា ឈ្មោះនៅក្នុងបញ្ជីដែលសមមិត្ត ពុត កាន់ជាប់ក្នុងដៃសុទ្ធតែកត់បញ្ចូលតាមរបាយការណ៍របស់ប្រធានភូមិ ឬគណៈឃុំមុនពេលបញ្ជូនអ្នកទាំងនោះមកកាន់មន្ទីរវត្តកកោះឬមន្ទីរ០៨ ។ បន្ទាប់មក បញ្ជីនេះត្រូវបញ្ជូនទៅកាន់មន្ទីរស្រុកដើម្បីធ្វើការពិនិត្យ ។ ជឹម ជាអ្នកពិនិត្យបញ្ជីនិងជាអ្នកគូសសញ្ញាខ្វែងជើងក្អែកឬគូសប៊ិចក្រហមលើឈ្មោះដែលត្រូវសម្លាប់ ។ បន្ទាប់ពីពិនិត្យរួច ជឹម បានបញ្ជូនបញ្ជីឈ្មោះមកកាន់មន្ទីរ០៨វិញដោយមានសមមិត្តស្រ្ដី អនុប្រធានមន្ទីរសន្តិសុខ ជាអ្នកកាន់កាប់បញ្ជី និងកងសន្តិសុខប្រចាំមន្ទីរ ជាអ្នកអនុវត្តការសម្លាប់អ្នកទោសដោយផ្ទាល់ ។ មុនពេលសម្លាប់អ្នកទោសទាំងអស់ត្រូវកងសន្តិសុខចងស្លាបសេកនិងរុំមុខជិត ហើយបញ្ជូនឲ្យទៅលុតជង្គង់នៅមាត់រណ្តៅតែម្តង ។ ការសម្លាប់នេះបានប្រព្រឹត្តទៅស្ទើរតែរាល់ថ្ងៃ ។ ក្នុងមួយថ្ងៃៗមានអ្នកទោសស្លាប់ចាប់ពី៥០នាក់ទៅ១០០នាក់ ។ មុយ ចក់ សន្និដ្ឋានថា ពីឆ្នាំ១៩៧៦ មកដល់ចុងឆ្នាំ១៩៧៨ កងសន្តិសុខនៅមន្ទីរសន្តិសុខវត្តកកោះបានសម្លាប់អ្នកទោសអស់ប្រមាណ ២០.០០០នាក់ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកទោសមួយចំនួនដែលជាប្រជាជនមូលដ្ឋានត្រូវអង្គការលើកលែងទោសហើយនៅរស់រហូតដល់បច្ចុប្បន្ននេះ ដូចជា មុយ ចក់ ព្រមទាំងមិត្តភក្តិប៉ុន្មាននាក់ទៀត ។ មុយ ចក់ ប្រាប់ថាគាត់និងមិត្តភក្តិត្រូវកងសន្តិសុខចាប់ «ច្រឡំឈ្មោះ» ។

នៅចុងឆ្នាំ១៩៧៨ មន្ទីរសន្តិសុខវត្តកកោះលែងមានសកម្មភាពសម្លាប់មនុស្សទៀតហើយ បន្ទាប់ពីកងឈ្លបប្រធាននិងអនុប្រធានមន្ទីររត់ប្រាសអាយុ ។ ចំណែកអ្នកទោសដែលនៅសល់

ពីស្លាប់ ក៏ចែកផ្លូវគ្នាវិលត្រឡប់ទៅរកគ្រួសាររៀងៗខ្លួន ។

ព្រះតេជគុណ កែវ កុសល ព្រះជន្ម២៥ព្រះវស្សា ធ្លាប់បានព្រលោកគ្រូព្រះនាម សួរ សាត់ មានសង្ឃដីកាថា ក្រោយឆ្នាំ១៩៧៩ ខាងក្នុងព្រះវិហារវត្តកកោះនៅមានស្នាមឈាមប្រឡាក់លើកម្រាលឥដ្ឋ ខាងមុខបល្ល័ង្កព្រះពុទ្ធបដិមាដែលបាក់បែកនៅឡើយ ។ ចំណែកនៅតាមជញ្ជាំងព្រះវិហារទាំងសងខាងមានស្នាមចោះទម្លុះជញ្ជាំងដើម្បីស៊ករនុកដែកសម្រាប់ដាក់ខ្នោះកជើងអ្នកទោស ។ រហូតមកដល់បច្ចុប្បន្ននេះ ស្នាមចោះទម្លុះទាំងនោះត្រូវបានប៉ះភ្ជិតវិញ ប៉ុន្តែនៅតែអាចមើលឃើញស្នាមខ្លះដែរ ។ ខ្នោះជាច្រើនដែលប្រជាជននាំគ្នារើចេញពីមន្ទីរឃុំឃាំងអ្នកទោសត្រូវរដ្ឋអំណាចភូមិយកទៅដាក់តម្កល់ក្នុងបូជនីយដ្ឋានមួយស្ថិតនៅខាងកើតឆៀងខាងត្បូង ព្រះវិហារវត្តកកោះជាមួយនឹងអដ្ឋិធាតុមួយចំនួនតូចដែលប្រជាជនគាស់ពីរណ្តៅសាកសពជុំវិញបរិវេណវត្តនៅក្នុងឆ្នាំ១៩៨០ ។ ព្រះតេជគុណ កែវ កុសល មានសង្ឃដីកាថាអដ្ឋិធាតុដែលគាស់រួចមានចំនួនស្មើនឹងមួយភាគប្រាំនៃឆ្អឹងទាំងអស់ ។

មន្ទីរនេះបានបង្កើតឡើងដំបូងនៅឆ្នាំ១៩៧៣ ដែលកាលនោះមានឃុំឃាំងតែប្រជាជនមូលដ្ឋានប៉ុណ្ណោះ ។ ការសម្លាប់បានកើតឡើងជាបណ្តើរៗតាំងពីពេលនោះមក ។ ចាប់ពីឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៨ មន្ទីរសន្តិសុខនេះបានឃុំឃាំងនិងសម្លាប់អ្នកទោសគ្រប់ប្រភេទ ។ ការសម្លាប់បានធ្វើឡើងតាមបញ្ជីឈ្មោះអ្នកទោសដែលកត់ចូលសៀវភៅរបាយការណ៍របស់ប្រធានភូមិឃុំនិងសហករណ៍ ក្រោយពីសមមិត្ត ជឹម ជាគណៈស្រុកសម្រេចរួចហើយ ។ នៅចុងឆ្នាំ១៩៧៨ មន្ទីរសន្តិសុខវត្តកកោះលែងមានសកម្មភាពបន្ទាប់ពីកម្មាភិបាលទាំងអស់ដែលធ្វើការនៅក្នុងមន្ទីរនេះរត់ចេញយកតែព្រះអាយុសរៀងៗខ្លួន ។ អ្នកទោសស្ទើរតែទាំងអស់ត្រូវបានសម្លាប់ ហើយមួយចំនួនតូចបានរួចខ្លួនត្រឡប់មកផ្ទះវិញ ។

## ស្រុកបូរីជលសារ

### ២) មន្ទីរសន្តិសុខទួលអង្គក្រូច

ទួលអង្គក្រូច ជាទួលធំល្វឹងល្វើយមួយស្ថិតនៅភូមិអង្គក្រូច ឃុំបូរីជលសារ ស្រុកបូរីជលសារ ខេត្តតាកែវ ។ បច្ចុប្បន្ននេះនៅលើទួលអង្គក្រូចមានសាលាបឋមសិក្សាមួយសាងសង់ពីបេតុងនិងវត្តអង្គក្រូច មួយនៅក្បែរនោះ ផង ។ កាលពីជំនាន់ខ្មែរក្រហមទួលនេះត្រូវអង្គការយកធ្វើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សធំមួយនៅឃុំបូរីជលសារ ។ អ្នកទោសភាគច្រើនជាទាហានរបស់របបសាធារណរដ្ឋខ្មែរ ដែលត្រូវខ្មែរក្រហមយកមកសម្លាប់នៅលើបរិវេណទីតាំងសម្លាប់ទួលអង្គក្រូចនេះ ។ ណៅ សេង អាយុ៥៦ឆ្នាំ បានឲ្យដឹងថា ប្រធានមន្ទីរសន្តិសុខទួលអង្គក្រូចមានឈ្មោះថា ឆាន ។ ចំណែក ចត់ ជាកម្មាភិបាលធ្វើការនៅក្នុងមន្ទីរនេះដែរ ។ ការសម្លាប់មនុស្សនៅទួលអង្គក្រូចបានចាប់ផ្តើមនៅឆ្នាំ១៩៧៧ ។ ស៊ុម ចន្ថា អាយុ៣៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិអង្គក្រូចបាននិយាយថា នៅទីនឹងបរិវេណទីតាំងសម្លាប់ខ្មែរក្រហមបានដាំដើមដូងជាច្រើនដើមដែលសុទ្ធតែមានកប់សាកសពជនរងគ្រោះពីក្រោមទាំងអស់ ។ ចំណែករោងតូចមួយបណ្តោយ៣ម៉ែត្រ និងទទឹង១ម៉ែត្រកន្លះដែលជាអតីតបន្ទប់សួរចម្លើយ បច្ចុប្បន្នត្រូវបានកែឆ្នៃថ្មីឲ្យក្លាយទៅជាបន្ទប់ម៉ាស៊ីនភ្លើងប្រចាំវត្តអង្គក្រូចទាំងមូលវិញ ។ ចន្ថា បានប្រាប់ថា បន្ទាប់ពីថ្ងៃរំដោះឆ្នាំ១៩៧៩ភ្លាម គាត់បានឃើញនៅលើជញ្ជាំងនិងលើកម្រាលឥដ្ឋរោងម៉ាស៊ីននោះមានស្នាមប្រឡាក់ឈាមពេញព្រមទាំងមានខ្នោះឃ្នាងជាច្រើនផង ។

## ស្រុកគីរីវង្ស

### ៣) មន្ទីរសន្តិសុខវត្តព្រះធាតុសួស្តី

វត្តព្រះធាតុសួស្តីស្ថិតនៅក្នុងភូមិក្បាលដំរី ឃុំគោកព្រេច ស្រុកគីរីវង្ស ខេត្តតាកែវ ។

នៅឆ្នាំ១៩៧៥ មន្ទីរសន្តិសុខមួយត្រូវបានខ្មែរក្រហមកសាងឡើងនៅក្នុងបរិវេណវត្តព្រះធាតុសួស្តី ដែលមានទីតាំងនៅក្នុងភូមិក្បាលដំរី ឃុំគោកព្រេច ស្រុកគីរីវង្ស ខេត្តតាកែវ ។ នៅក្បែរមន្ទីរសន្តិសុខនេះមានទីតាំងសម្លាប់ធំមួយប្រចាំស្រុកគីរីវង្ស ។ ខ្មែរក្រហមបានយកសាលាបុណ្យរបស់វត្តនេះធ្វើជាមន្ទីរឃុំឃាំងនិងកុដិពីរទៀតធ្វើជាផ្ទះស្នាក់នៅរបស់កងសន្តិសុខ ។ មុននឹងសម្លាប់អ្នកទោស កងសន្តិសុខបានសួរចម្លើយ និងធ្វើទារុណកម្ម ។ លី ជន អាយុ៥៥ឆ្នាំ ជាអតីតអ្នកទោសម្នាក់នៅក្នុងមន្ទីរសន្តិសុខវត្តព្រះធាតុសួស្តី បានរៀបរាប់ថា គាត់ធ្លាប់ឮសម្រែកអ្នកទោសស្រែកយ៉ាងអាណោចអាធ័មនៅពេលសួរចម្លើយម្តងៗ ។ អ្នកទោស

ខ្លះបានស្លាប់នៅពេលសួរចម្លើយ ហើយខ្លះទៀតត្រូវបញ្ជូនទៅកាន់ទីតាំងសម្លាប់ ។ ក្រោយពេលសម្លាប់អ្នកទោសចាស់ អ្នកទោសថ្មីត្រូវកងសន្តិសុខចាប់បញ្ជូនមកដាក់ឃុំឃាំងបន្តទៀត ។ ជន បាន លើកឧទាហរណ៍ថា បើមានអ្នកទោសស្លាប់៥០នាក់ អ្នកទោសថ្មីដែលចាប់បញ្ជូនមកក៏មានចំនួន៥០នាក់ដែរ ។ កងសន្តិសុខបានបញ្ជូនអ្នកទោសមកតាមមធ្យោបាយធ្វើដំណើរផ្សេងៗដូចជារថយន្តតូច រទេះសេះ និងរទេះគោជាដើម ។ អ្នកទោសភាគច្រើនត្រូវកងសន្តិសុខចាប់មកពីភូមិ ឃុំ និងសហករណ៍នានាក្នុងស្រុកគិរីវង្ស ។ ប៉ុន្តែអ្នកទោសដែលជាប់ឃុំមុនគេនៅវត្តព្រះធាតុសួស្តីគឺប្រជាជន១៧មេសា បន្ទាប់មកប្រជាជនមូលដ្ឋាននិងកម្មាភិបាលខ្មែរក្រហម ។

## ស្រុកព្រៃកប្បាស

### ៤) មន្ទីរសន្តិសុខភូមិឫស្សី


មន្ទីរសន្តិសុខភូមិឫស្សី

ភូមិឫស្សីស្ថិតនៅក្នុងឃុំបានកាម ស្រុកគិរីវង្ស ខេត្តតាកែវ ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខមួយឈ្មោះថាមន្ទីរសន្តិសុខភូមិឫស្សី ។ មន្ទីរនេះជាមន្ទីរសន្តិសុខធំជាងគេប្រចាំស្រុក៥៥ (ស្រុកព្រៃកប្បាស) ខេត្តតាកែវ ។ អ្នកទោសដែលកងសន្តិសុខចាប់មកឃុំនៅក្នុងមន្ទីរសន្តិសុខភូមិឫស្សីគឺប្រជាជនមូលដ្ឋានទាំងគ្រួសារៗដែលរស់នៅក្នុងឃុំព្រៃផ្តៅ និងឃុំចំប៉ា ស្រុកព្រៃកប្បាស និងប្រជាជនជម្លៀសមកពីទីកន្លែងផ្សេងៗ ។ មធ្យោបាយបញ្ជូនអ្នកទោសយកមកកាន់មន្ទីរឃុំឃាំងនេះគឺរទេះសេះ ។ ដឹម ចែម អាយុ៨៦ឆ្នាំ បាននិយាយថាការដឹកជញ្ជូនអ្នកទោសភាគច្រើនធ្វើឡើងនៅវេលាម៉ោង៤ឬ៥រសៀល ហើយការសម្លាប់ក៏កើតមានក្នុងពេលដំណាលគ្នាដែរ ។ ការសម្លាប់មនុស្សបានកើតឡើងតាំងពីពេលបង្កើតមន្ទីរនេះដំបូងម្ល៉េះ ។ អង្គការបានបែងចែកភារកិច្ចឲ្យកងសន្តិសុខនាំយកអ្នកទោសទៅសម្លាប់ផ្សេងពីគ្នាគឺអ្នកទោសនារី ត្រូវកម្មាភិបាលនារីខ្មែរក្រហមសម្លាប់ដោយផ្ទាល់អ្នកទោសបុរសគឺត្រូវសម្លាប់ដោយកម្មាភិបាលបុរស ចំណែកអ្នកទោសកុមារត្រូវប្រធានកងកុមារជាអ្នកសម្លាប់ ។ ប្រធានគ្រប់គ្រងនៅមន្ទីរសន្តិសុខភូមិឫស្សីគឺឈ្មោះ សួត និង សារ៉ន ។ ក្រោយមក សារ៉ន បានត្រូវប្រជាជនសម្លាប់ ហើយ សួត បានរត់គេចខ្លួនបាត់រហូតមកដល់សព្វថ្ងៃនេះ ។

### ៥) មន្ទីរសន្តិសុខទួលកំពង់ចក


មន្ទីរសន្តិសុខទួលកំពង់ចក

ទួលកំពង់ចកស្ថិតនៅក្នុងភូមិព្រៃល្វា ឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

មន្ទីរសន្តិសុខទួលកំពង់ចកកសាងឡើងនៅឆ្នាំ១៩៧៣ ដោយជីកដីលុងទៅក្រោម រួចធ្វើដំបូលប្រក់ពីលើ ។ អ្នកទោសដែលជាប់មុនដំបូងគេសុទ្ធតែជាទាហានឈ្លើយសឹករបស់របបសាធារណរដ្ឋខ្មែរដែលចាញ់សង្គ្រាម ។ អ្នកទោសទាំងនេះត្រូវកងឈ្លបសម្លាប់ចោលទាំងអស់ក្រោយពេលជាប់ឃុំឃាំងមួយរយៈខ្លី ។

ចាប់ពីឆ្នាំ១៩៧៥ ជនរងគ្រោះដែលជាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខទួលកំពង់ចកគឺជាប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ ខេត្តតាកែវ និងពីកន្លែងដទៃទៀត ។ ប្រជាជនមូលដ្ឋានដែលមានកំហុសឆ្គងបន្តិចបន្តួច ក៏ត្រូវខ្មែរក្រហមចាប់យកមកដាក់ក្នុងមន្ទីរសន្តិសុខទួលកំពង់ចកនេះដែរ ។ អ្នកទោសទាំងអស់ត្រូវដេកផ្ទាល់ដី

គម្រៀបគ្នាជាពីរជួរ ។ កងសន្តិសុខបានឲ្យអ្នកទោសធ្វើពលកម្មនៅពេលថ្ងៃ ហើយដាក់ខ្នោះវិញនៅពេលហូបបាយល្ងាចរួច ។ ពេលបន្ទោរបង់ម្តងៗ អ្នកទោសមិនត្រូវបានឆ្មាំគុកដោះខ្នោះចេញឡើយ ។ ការងាររបស់អ្នកទោសគឺជីកស្រះនៅក្នុងបរិវេណមន្ទីរសន្តិសុខនិងធ្វើស្រែ ។ អ្នកទោសត្រូវបានសម្លាប់នៅទួលត្រពាំងគ្នោត(ព្រៃល្វា) ។ ថោង កាំង អាយុ៦០ឆ្នាំ បច្ចុប្បន្នជាអ្នកចិញ្ចឹមទានៅក្បែរទួលកំពង់ចកបាននិយាយថា នៅឆ្នាំ១៩៧៨ មានអ្នកទោសច្រើននាក់ណាស់ដែលកងសន្តិសុខនាំយកទៅសម្លាប់ដោយចងបណ្តើរទាំងវែងៗ ។

នៅក្រោយឆ្នាំ១៩៧៩ ថោង កាំង បានចូលមកកាន់ទីតាំងមន្ទីរសន្តិសុខនេះមុនគេ ហើយឃើញមានខ្នោះនៅពាសពេញមន្ទីរឃុំឃាំង ។ រហូតមកដល់សព្វថ្ងៃ អតីតមន្ទីរសន្តិសុខខ្មែរក្រហមនេះគឺជាកន្លែងផលិតឥដ្ឋក្បឿងដែលជាកម្មសិទ្ធិរបស់ប្រជាជននៅក្នុងភូមិ ។

## ស្រុកសំរោង

### ៦) មន្ទីរសន្តិសុខវត្តស្រះក្រាំងបន្ទាយ


មន្ទីរសន្តិសុខវត្តស្រះក្រាំងបន្ទាយ

វត្តស្រះក្រាំងបន្ទាយស្ថិតនៅភូមិពេជឥន្ទ្រ ឃុំបឹងត្រាញ់ជើង ស្រុកសំរោង ។ កាលពីជំនាន់ខ្មែរក្រហម វត្តស្រះក្រាំងបន្ទាយត្រូវខ្មែរក្រហមជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខ ។ សាលាឆាន់និងកុដិធ្វើជាមន្ទីរឃុំឃាំង ចំណែកព្រះវិហារជាមន្ទីរសួរចម្លើយនិងធ្វើទារុណកម្ម ។ សំ ផុន ភេទប្រុស អាយុ៥២ឆ្នាំ ដែលកាលពីជំនាន់ខ្មែរក្រហមរស់នៅទល់មុខវត្តស្រះក្រាំងបន្ទាយបាននិយាយថា កងសន្តិសុខបានបណ្តើរអ្នកទោសចូលក្នុងបរិវេណវត្តជាហូរហែ ។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរឃុំឃាំងវត្តស្រះក្រាំងបន្ទាយគឺប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ ទីរួមខេត្តតាកែវ ទីប្រជុំជនផ្សេងៗ និងប្រជាជនមូលដ្ឋានមួយចំនួនទៀត ។ អ្នកទោសទាំងអស់ត្រូវកងសន្តិសុខសួរចម្លើយនិងធ្វើទារុណកម្មមុននឹងសម្លាប់ចោល ។ អ្នកទោសខ្លះត្រូវកងឈ្លបចងខ្សែពួរយោលទៅបុកជញ្ជាំងព្រះវិហារ ដួនកាលយោលទៅបុកសសរព្រះវិហារ ។ ផុន បានឮសូរសម្រែកអ្នកទោសចេញពីព្រះវិហារនៅពេលកងសន្តិសុខសួរចម្លើយម្តងៗ ។

ទេស បាន អាយុ៦១ឆ្នាំ បានប្រាប់ថាឃាតករនៅក្នុងមន្ទីរសន្តិសុខវត្តស្រះក្រាំងបន្ទាយមាន ឈ្មោះ មឿន ជេង យឹម ភន និង រិច ។

នៅក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខវត្តស្រះក្រាំងបន្ទាយបានបន្សល់ទុកបញ្ជីឯកសារមួយចំនួនដែលក្រោយមកបានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់រដ្ឋអំណាចស្រុកវិញ ។ នៅក្នុងឯកសារទាំងនោះ គេសង្កេតឃើញមានឈ្មោះអ្នកទោសសរុបទាំងអស់ចំនួន ៣.៧៧៥នាក់ ។

### ៧) មន្ទីរសន្តិសុខអូរតាមោក

មន្ទីរសន្តិសុខវត្តប៉ាណា ឬអូរតាមោកស្ថិតនៅភូមិប៉ាណា ឃុំសឹង្ហ ស្រុកសំរោង ។ មន្ទីរឃុំឃាំងរយៈពេលខ្លីមួយបានត្រូវបង្កើតឡើងនៅក្នុងទីធ្លាវត្តប៉ាណា ក្បែរបរិវេណទីតាំងសម្លាប់មនុស្សអូរតាមោក ។ ទីតាំងនេះស្ថិតនៅក្នុងភូមិប៉ាណា ឃុំសឹង្ហ ស្រុកសំរោង ។ ការឃុំឃាំង និងសម្លាប់អ្នកទោសបានប្រព្រឹត្តទៅនៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ។

កាលពីខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានកៀរប្រជាជនមួយចំនួនដែលជម្លៀសចេញពីក្រុងភ្នំពេញ មកទុកនៅទីវត្តប៉ាណា ហើយមួយចំនួនទៀតត្រូវខ្មែរក្រហមប្រមូលយកទៅឲ្យស្នាក់នៅក្នុងបរិវេណវត្តទម្លាប់ ។ នៅខែកក្កដាឆ្នាំដដែលអ្នកទោសភាគច្រើនត្រូវកងឈ្លបនាំយកទៅសម្លាប់ ។ ចំណែកអ្នកដែលនៅសល់ត្រូវអង្គការតម្រូវឲ្យផ្លាស់ប្តូរទីលំនៅ ។ ទឹម ទង អាយុ៧១ឆ្នាំ រស់នៅភូមិទម្លាប់ ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ បានឃើញមានមនុស្សស្នាក់នៅពេញទីធ្លាវត្តប៉ាណា ពេលដែលគាត់ទៅឃ្វាលគោនៅក្បែរៗទីនោះ ។ ទង និយាយទៀតថា ប្រជាជនទាំងនោះត្រូវកងសន្តិសុខប្រើឲ្យកាប់រណ្តៅជាច្រើន ។ ពេលក្រោយមករណ្តៅ

ទាំងប៉ុន្មាននេះបានក្លាយទៅជារណ្តៅកប់សាកសពអ្នកទោសទៅវិញ ។ ស្រី សុគន្ធ អាយុ៤៥ឆ្នាំ ជាគ្រូបង្រៀននៅសាលាបឋមសិក្សាប៉ាំណា បានឃើញកងសន្តិសុខចាប់ចងអ្នកទោសហើយបណ្តើរចេញពីវត្តប៉ាំណាឆ្ពោះទៅកាន់ទីតាំងសម្លាប់អូរតាមោក ដោយផ្ទាល់ភ្នែក ។ មិនយូរប៉ុន្មាន សាកសពអ្នកទោសទាំងប៉ុន្មានត្រូវអ្នកទោសដូចគ្នាគាស់ឡើងមកវិញ ដើម្បីយកទៅដុតកម្ទេចជាមួយរុក្ខជាតិផ្សេងទៀត ធ្វើជីដាក់ស្រែនិងដំណាំផ្សេងៗ ។

តាមសង្ឃដីការបស់ព្រះសង្ឃមួយអង្គគង់នៅវត្តប៉ាំណា បានឲ្យដឹងថា នៅជុំវិញព្រះវិហារមានរណ្តៅច្រើនណាស់ ។ មេ សាម៉េត អាយុ៥២ឆ្នាំ ជានាយកសាលាបឋមសិក្សាប៉ាំណា ឃុំសីធ្លូ ស្រុកសំរោង ខេត្តតាកែវ បានឲ្យដឹងថា តាំងពីឆ្នាំ១៩៧៩ ពេលដែលគាត់ចូលធ្វើគ្រូបង្រៀននៅសាលាបឋមសិក្សាប៉ាំណា ដំបូងគាត់បានពិនិត្យឃើញអគារសិក្សាទាំងអស់សុទ្ធតែគ្មានដំបូល ជញ្ជាំង ទ្វារនិងបង្អួច ។ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ន ទីនោះគឺជាបរិវេណសាលាបឋមសិក្សាប៉ាំណា ។

## ៨) មន្ទីរសន្តិសុខវត្តទន្ទាប់

វត្តទន្ទាប់ ស្ថិតក្នុងភូមិទន្ទាប់ ឃុំសីធ្លូ ស្រុកសំរោង ខេត្តតាកែវ ។ នៅដើមឆ្នាំ១៩៧៥ មន្ទីរសន្តិសុខវត្តទន្ទាប់មានឃុំឃាំងអ្នកទោសយ៉ាងច្រើនដែលជាប្រជាជនជាប់ពាក់ព័ន្ធរឿងនយោបាយពីសង្គមចាស់ និងអ្នកមានទ្រព្យសម្បត្តិ ។ វត្តនេះស្ថិតនៅក្នុងភូមិទន្ទាប់ ឃុំសីធ្លូ ស្រុកសំរោង ខេត្តតាកែវ ។ ខ្មែរក្រហមបានហាមឃាត់មិនឲ្យប្រជាជនចូលក្នុងបរិវេណវត្តទន្ទាប់ឡើយ ។ ទឹម ទង និយាយប្រាប់ថា នៅក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហមបរិវេណវត្តទន្ទាប់មានពោរពេញទៅដោយអ្នកទោសជាច្រើននាក់ ប៉ុន្តែនៅពុំទាន់ដាក់ខ្នោះ ឬច្រវាក់នៅឡើយទេ ។ កងសន្តិសុខបានបញ្ជាឲ្យអ្នកទោសទាំងនោះធ្វើពលកម្មផ្សេងៗជារៀងរាល់ថ្ងៃដូចជាជីករណ្តៅ និងធ្វើស្រែជាដើម ។ នៅឆ្នាំ១៩៧៦ ការឃុំឃាំងត្រូវបានរឹតបន្តឹងជាងមុន ហើយមានអ្នកទោសខ្លះត្រូវកងឈ្លបនាំយកទៅដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខវត្តប៉ាំណាបន្តទៀតនិងសម្លាប់ចោលខ្លះ ។

## ស្រុកត្រាំកក់

## ៩) មន្ទីរសន្តិសុខក្រាំងតាចាន់

តំបន់ក្រាំងតាចាន់ ត្រូវបានអង្គការបដិវត្តន៍ប្រើប្រាស់ជាបរិវេណមន្ទីរអប់រំស្រុកត្រាំកក់កាលពីជំនាន់ខ្មែរក្រហម ។ ខ្មែរក្រហមបានហៅមន្ទីរអប់រំនេះម្យ៉ាងទៀតថា «គុកក្រាំងតាចាន់» ។ មន្ទីរនេះបានបន្សល់ទុកនូវឯកសារយ៉ាងច្រើនរហូតដល់សព្វថ្ងៃ ។ មន្ទីរអប់រំរបស់ស្រុកត្រាំកក់ ស្ថិតនៅភូមិក្រាំងតាចាន់ ឃុំគុស ស្រុកត្រាំកក់ ខេត្ត តាកែវ ។ គណៈស្រុកត្រាំកក់ឈ្មោះ ជឹម និង ឈ្មោះ សាន ។ ប្រធានសន្តិសុខស្រុកឈ្មោះ ភី និងប្រធានមន្ទីរអប់រំឈ្មោះ អាន់ ។ អ្នកទាំងអស់នេះសុទ្ធតែមានដើមកំណើតនៅឃុំត្រពាំងធំខាងត្បូង និងឃុំជាងទង ស្រុកត្រាំកក់ ហើយត្រូវអង្គការប្រគល់ភារកិច្ចឲ្យគ្រប់គ្រងស្រុកនិងមន្ទីរអប់រំតាំងពីឆ្នាំ១៩៧៣ដល់១៩៧៩ ។ ជឹម និង ភី គឺជាសាច់ញាតិរបស់ តាម៉ុក ចំណែក អាន់ គឺជាអ្នកស្គាល់ តាម៉ុក ជិតដិត ។

នៅឆ្នាំ១៩៧៧ ភី ត្រូវអង្គការផ្លាស់ពីប្រធានសន្តិសុខស្រុកត្រាំកក់ទៅធ្វើប្រធានសន្តិសុខស្រុកទ្រាំងវិញ ។ អាន់ ទទួលភារកិច្ចជាប្រធានមន្ទីរអប់រំរបស់ស្រុកត្រាំកក់ បន្ទាប់ពីប្រធានមុនឈ្មោះ គិល ត្រូវអង្គការផ្លាស់ទៅធ្វើជាប្រធានការដ្ឋាន ២០២ នៅឆ្នាំ១៩៧៤-១៩៧៥ ។

មន្ទីរសន្តិសុខស្រុកត្រាំកក់សាងសង់



មន្ទីរសន្តិសុខវត្តទន្ទាប់

ឡើងនៅលើដីទួលមួយដែលមានដើមឈើធំៗដុះព័ទ្ធជុំវិញ ។ អគារដែលបានសាងសង់មានអគារឃុំឃាំងចំនួនពីរនិងអគារសម្រាប់ទុកសម្ភារៈមួយ ។ អគារទាំងបីនោះសង់ពីឈើប្រក់ស័ង្កសី ។ បន្ទប់សួរចម្លើយនិងទីតាំងប្រហារជីវិតស្ថិតនៅខាងត្បូងអគារឃុំឃាំង ។ ម៉ៅ អតីតអ្នកទោសម្នាក់ក្នុងមន្ទីរអប់រំនេះបានឲ្យដឹងថា បន្ទប់ឃុំឃាំងទាំងពីរដែលបន្ទប់នីមួយៗមានទទឹង៤ម៉ែត្រនិងបណ្តោយ៨ម៉ែត្រត្រូវបានកសាងឡើងអំពីឈើកំណាត់ៗកប់ទៅក្នុងដី ហើយវាយផ្ទឹបព័ទ្ធជុំវិញដោយបន្ទះក្តារនិងប្រក់ស័ង្កសី ។ នៅពីលើបន្ទះក្តារមានត្បាញបន្លាលួសយ៉ាងញឹក ។ បន្ទប់ឃុំឃាំងមានលក្ខណៈបួនជ្រុងទ្រវែងដូចទ្រុងកណ្តុរ ។ នៅលើផ្ទឹម បន្ទប់ឃុំឃាំងអគារខាងកើតមានសរសេរផ្លាកថា «នៅរស់ រត់ស្លាប់» ។ ដាំ ជាអតីតកម្មាភិបាលខ្មែរក្រហមនៅអំឡុងឆ្នាំ១៩៧៣-១៩៧៥ និងជាអ្នកទោសម្នាក់ដោយសារប្រព្រឹត្តខុសសីលធម៌ជាមួយនារីភេទបានឲ្យដឹងថាស្លាក «នៅរស់ រត់ស្លាប់»នេះ បានពុកផុយនិងធ្លាក់ចុះមកដីនៅឆ្នាំ១៩៧៥ ។ (ចាប់ពីឆ្នាំ១៩៧៥មក ដាំ ត្រូវអង្គការផ្លាស់ចេញពីមន្ទីរអប់រំទៅធ្វើការនៅកងរទេះក្នុងឃុំដាំងទងវិញ ។ តាមរបាយការណ៍ដែលបញ្ជូនទៅឲ្យមន្ទីរអប់រំរបស់ស្រុកបានបញ្ជាក់ពីមូលហេតុនៃការចាប់ខ្លួន ដាំ ថាបានដើរនិយាយបរិហារបដិវត្ត ។ នៅចុងឆ្នាំ១៩៧៧ ដាំ ត្រូវកងសន្តិសុខចាប់ខ្លួនមកដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់វិញ ។ ដាំ បានរៀបរាប់ពីកន្លែងធ្វើការចាស់ និងទីតាំងដែលគាត់ធ្លាប់ជាប់ឃុំឃាំងថា បន្ទប់ឃុំឃាំងសង់ពីឈើមានរាងទ្រវែងកម្ពស់ប្រវែង២ម៉ែត្រ ។ អ្នកទោសត្រូវឆ្នាំគុកដាក់ខ្នោះជា២ជួរ ដែលក្នុងមួយជួរៗមានអ្នកទោសពី២០-៣០នាក់ និងមានធុងដាក់លាមកមួយសម្រាប់អ្នកទោសទាំងអស់បន្ទោរបង់ ។ ចំណែកត្រឡោកនិងវែកសម្រាប់ដាក់និងហូបបបរ ។ អ្នកទោសដែលមិនដែលបានងូតទឹករាប់ខែបូករួមទាំងក្លិនធុងលាមកផងបានធ្វើឲ្យបន្ទប់ឃុំឃាំងទាំងមូលមានក្លិនស្អុយខ្មោះខ្មួរពិបាកទ្រាំ ។ កែវ ម៉ៅ បានហៅបន្ទប់ក្នុងគុកក្រាំងតាចាន់ដែលគាត់ធ្លាប់រស់នៅរាប់ឆ្នាំថា ជា «ឋាននរក» ។ ម៉ៅ និយាយថា «អត់មានខ្មាសអៀនអីទេ ទាំងស្រីទាំងប្រុស ។ ឆ្នាំងមួយហុចគ្នាជុះរួចហុចទៅវិញទៅមក រួចចាក់ដាក់ក្នុងពាងទៅ» ។ ម៉ៅ ដែលចូលមើលមន្ទីរអប់រំរបស់ស្រុកត្រាំកក់ក្នុងដើមឆ្នាំ១៩៧៩ បានបញ្ជាក់ថា សភាពកខ្វក់ដែលមាននៅលើក្តារអគារទាំងអស់បានបណ្តាលឲ្យកើតចៃនិងសង្កើចយ៉ាងច្រើន ។ សែន និយាយថា «មានអ្នកទោសមិនតិចទេដែលមានជំងឺ និងស្លាប់ដោយសាររស់នៅជាមួយសត្វចៃនិងសង្កើច ។ ខ្ញុំផ្ទាល់ ដិបូងសង្កើច ខាំឈឺដល់ខាំរាល់ថ្ងៃយូរៗទៅធម្មតា ប៉ុន្តែសត្វចៃ«សៗ» ចេញពីសាច់ដែលនៅតាមដៃអាវនិងថ្នេរអាវ ខាំរមាស់ពិបាកទ្រាំបំផុត» ។

អ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ សុទ្ធតែត្រូវកងសន្តិសុខចាប់ខ្លួនតាមបញ្ជាពីអង្គការថ្នាក់លើទាំងអស់ ។ ការចាប់នេះធ្វើឡើងតាមរយៈលិខិតរបស់កម្មាភិបាលថ្នាក់ក្រោមដែលបានរាយការណ៍ ជូនអង្គការ ជូនសមមិត្តបង ឬគោរពជូនបក្ស ជូនមន្ទីរអប់រំរបស់ស្រុកត្រាំកក់ ។ លិខិតទាំងនេះកើតចេញមកពីការធ្វើប្រវត្តិរូបតាមបណ្តាភូមិនិងឃុំទូទាំងស្រុក ព្រមជាមួយការតាមដានយ៉ាងខ្ជាប់ខ្ជួនពីកម្លាំងសម្ងាត់ដែលដាក់ពង្រាយឲ្យរស់នៅលាយឡំជាមួយកសិករទូទៅ ។ គណៈស្រុកត្រាំកក់បានរៀបចំផែនការដាក់ឲ្យថ្នាក់ក្រោមរបស់ខ្លួនអនុវត្តនូវការងារធ្វើប្រវត្តិរូបប្រជាជនទូទៅក្នុងស្រុក ។ គណៈឃុំគ្រប់ឃុំ ក្នុងស្រុកត្រាំកក់ ត្រូវបានចាត់តាំងឲ្យចុះធ្វើបញ្ជីស្រង់ឈ្មោះនិងធ្វើប្រវត្តិរូបប្រជាជនដែលរស់នៅក្នុងឃុំរបស់ខ្លួន រួចផ្ញើទៅអង្គការស្រុក ។ សមមិត្ត ស៊ឹម គណៈឃុំញ៉ែងញ៉ង បានរកឃើញសមាសភាពអតីតទាហាន និងប៉ូលិសរបបសាធារណរដ្ឋខ្មែរដែលរស់នៅក្នុងឃុំញ៉ែងញ៉ងចំនួន១១នាក់ (ឯកសារD០០២៥៨) ។ សមមិត្ត មៀន ប្រធានកងភ្ជួរឃុំញ៉ែងញ៉ង ក៏បានរកឃើញនិងរាយការណ៍ពីសមាសភាពខ្មាំងជាអតីតទាហាននិងប៉ូលិសរបបសាធារណរដ្ឋខ្មែរចំនួន៤នាក់នៅក្នុងកងរបស់គាត់ជូនអង្គការស្រុកត្រាំកក់ដែរ ។ សមាសភាពខ្មាំងទាំងនោះមាន ១) ឡូ អេងថ្វី ខាងបើកបរយន្តហោះ ២)យន់ ហាន លេខាធិការឃ្លាំងសម្ភារៈសឹក ៣) សួស ទី សេហ្ ប៉េអ៊ឹម និង ៤) ប៉ាង ណាន ទាហានពលបាលទោ (ឯកសារD០០៥០២) ។ សមមិត្ត ឆោម គណៈឃុំអង្គតាសោមបានចូលរួមបំពេញភារកិច្ចប្រមូលខ្មាំងតាមផែនការរបស់បក្សយ៉ាងសស្រាក់សស្រាំ ។ បន្ទាប់ពីបញ្ជូនសមាសភាពខ្មាំងមួយចំនួនទៅអង្គការស្រុករួចហើយ សមមិត្ត ឆោម បានបន្តតាមរកសមាសភាពខ្មាំងក្នុងឃុំរបស់គាត់ថែមទៀត ។ ឧទាហរណ៍ក្នុងសេចក្តីរាយការណ៍

មួយចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៧ របស់សមមិត្ត ឆោម ផ្ញើជូនអង្គការស្រុកត្រាំកក់ គាត់បានសរសេរថា «សូមបញ្ជាក់បន្ថែមចំពោះអ្នកមានស័ក្តិពីរមួយចំនួន ឬមួយយើងខ្ញុំទាក់ទងមិត្ត យនខាងយោធាស្រុកយកល្ងាចនេះហើយ ។ សូមអង្គការជ្រាប» ។

អ្នកទោសដែលកងឈ្លបបញ្ជូនមកដាក់ឃុំឃាំងនៅមន្ទីរអប់រំរបស់ស្រុកត្រាំកក់ (គុកក្រាំងតាចាន់) សុទ្ធតែត្រូវយកទៅកម្ទេចចោល បន្ទាប់ពីបានឈ្លេចសួរចម្លើយរកខ្សែរយៈក្បត់ ។ ការបាត់ខ្លួនមនុស្សពីភូមិ-ឃុំ ចេះតែបាត់ទៅៗមិនដែលឃើញវិលត្រឡប់មករស់នៅជួបជុំគ្រួសារវិញឡើយ ហើយការចាប់មនុស្សថ្មីៗទៀត មកដាក់ឃុំឃាំងចេះតែមានជាហូរហែ ។ គេង អតីតកម្មាភិបាលឃុំពពេលជាអ្នកបានដឹងនិងចូលរួមអនុវត្តវិធានការរបស់បក្សចំពោះខ្មាំង ។ គេង ប្រាប់ឲ្យដឹងថា នៅពាក់កណ្តាលឆ្នាំ១៩៧៥ សមមិត្ត ជន គណៈឃុំពពេលបានចាត់តាំងប្រធានភូមិនិងប្រធានក្រុមឲ្យដើរសួរប្រវត្តិរូបប្រជាជនដែលរស់នៅក្នុងឃុំពពេល ។ គេង បញ្ជាក់ថា ក្នុងការធ្វើប្រវត្តិរូបនៅពេលនោះមានសួរនាំអំពីឈ្មោះការងារ ប្តីប្រពន្ធ កូនចៅ និងមុខរបររកស៊ីយ៉ាងលម្អិត ។ ភស្តុតាងឯកសាររបាយការណ៍របស់សមមិត្ត ជន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ បានបញ្ជាក់បន្ថែមលើការអះអាងរបស់ គេង ឲ្យរឹតតែជាក់លាក់ថែមទៀត ។ ជន រៀបរាប់នៅក្នុងរបាយការណ៍របស់គាត់ដែលផ្ញើជូនអង្គការស្រុកត្រាំកក់ស្តីពីលទ្ធផលអនុវត្តការងារធ្វើប្រវត្តិរូបប្រជាជនក្នុងឃុំរបស់គាត់ថា «គ្រួសារទាហានដែលត្រូវអង្គការកម្ទេចមានចំនួន១០៦គ្រួសារ ត្រូវជា៣៩៣នាក់ ។ គ្រួសារទាហានដែលនៅសល់មានចំនួន២៣១គ្រួសារ ត្រូវជា៨៩២នាក់» ។ ចំពោះប្រជាជនដែលនៅសល់ សមមិត្ត ជន បានបញ្ជាក់នៅចុងបញ្ចប់នៃលិខិតរបស់គាត់ប្រាប់អង្គការថាកំពុងតែព្យាយាមពិនិត្យតាមដានរកគ្រួសារទាហានពិសេសក្នុងចំណោមប្រជាជនថ្មី «ប្រជាជនជម្លៀស» បន្តទៀត ។ (ឯកសារD០០២០៣) ។

ខ្សែសង្វាក់ការងារនៅក្នុងមន្ទីរអប់រំស្រុកត្រាំកក់បានប្រព្រឹត្តទៅយ៉ាងមមាញឹកនិងទទួលបានលទ្ធផលល្អជានិច្ច ។ កម្មាភិបាលថ្នាក់ភូមិឃុំនិងសហករណ៍ចេះតែធ្វើសេចក្តីរាយការណ៍ជូនថ្នាក់ស្រុក ឯកម្មាភិបាលដែលប្រចាំការនៅក្នុងមន្ទីរអប់រំរបស់ស្រុកមានភារកិច្ចចាំទទួលនិងជម្រិតយកចម្លើយ ហើយចុងបញ្ចប់កម្ទេចចោលគ្មានសល់ម្នាក់ ។ សមមិត្ត សាំង កម្មាភិបាលមន្ទីរអប់រំរបស់ស្រុកត្រាំកក់ បានឃើញនិងទទួលយកអតីតទាហាន និងប៉ូលិសរបបសាធារណរដ្ឋខ្មែរដែលគណៈឃុំគ្រប់ឃុំចាប់ខ្លួន ហើយបញ្ជូនមកមន្ទីរអប់រំស្រុកត្រាំកក់ ។ សាំង បន្តថា «ក្នុងពាក់កណ្តាលឆ្នាំ១៩៧៥ អ្នកទោសដែលកងឈ្លបចាប់បញ្ជូនមកមានច្រើនណាស់ទាំងយប់ទាំងថ្ងៃ អត់មានបានដេកពួនទេ» ។ ណម អតីតប្រជាជនមូលដ្ឋាននៅភូមិក្រាំងតាចាន់បានអះអាងថា ក្នុងពាក់កណ្តាលឆ្នាំ១៩៧៥ ប្រជាជន១៧មេសា ដែលមានសាច់ស ធាត់ទ្រលុកទ្រលន់ និងមានឃ្មួរកាបូប វ៉ាលិសគ្រប់ដៃ ត្រូវកងឈ្លបបណ្តើរមកជាជួរចូលក្នុងមន្ទីរអប់រំនេះ ។ បន្ទាប់ពីឃុំឃាំងនិងសួរចម្លើយ អតីតទាហាននិងប៉ូលិសទាំងនោះត្រូវអង្គការបដិវត្តន៍សម្រេចយកទៅសម្លាប់ ។ បញ្ជីស្ថិតិអ្នកទោសនៅមន្ទីរអប់រំស្រុកត្រាំកក់បង្ហាញថាអ្នកទោសដែលជាអតីតទាហាននិងប៉ូលិសរបបសាធារណរដ្ឋខ្មែរមានចំនួនជាងពាក់កណ្តាលក្នុងចំណោមអ្នកទោសទាំងអស់ដែលកងឈ្លបសម្លាប់ ។ ក្នុងចំនួនអ្នកទោស៥០០នាក់ ដែលត្រូវប្រហារជីវិតមាន២៥២នាក់ជាអតីតទាហាន និងប៉ូលិសរបបសាធារណរដ្ឋខ្មែរ ។ ក្នុងបញ្ជីស្នើកម្ទេចអ្នកទោស៤០នាក់ ថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៧៧ មានទាហានស័ក្តិ១ ស័ក្តិ២ និងប៉ូលិស របបសាធារណរដ្ឋខ្មែរចំនួន២៦នាក់ កាប៉ូរ៉ាល់៦នាក់ អាត់ស៊ីដង់៣នាក់ ពាក់ដោយចំនួន៣នាក់ កុងស៊ីយ៍១នាក់ និងសិស្សថ្នាក់ទី១ មួយនាក់ ។ ក្នុងចំណោមអ្នកទោស២៦នាក់ដែលស្នើកម្ទេចថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៨ មានអតីតស័ក្តិ១ និងស័ក្តិ២ ទាហាន និងប៉ូលិសរបបសាធារណរដ្ឋខ្មែរចំនួន១៨នាក់ កាប៉ូរ៉ាល់២នាក់ ពលទោ១នាក់ និងប្រជាជន៥នាក់ ។ ក្នុងចំណោមអ្នកទោស២៨នាក់ ដែលគណៈតំបន់ (សមមិត្ត ប្រាក់) បញ្ជាឲ្យ កម្ទេចថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៧ មានពលទោ៨នាក់ កាប៉ូរ៉ាល់២នាក់ ស័ក្តិមួយ៨នាក់ ស័ក្តិ២ចំនួន៣នាក់ និងអាត់ស៊ីដង់៣នាក់ (ឯកសារ D០០៥០២) ។

នៅពាក់កណ្តាលឆ្នាំ១៩៧៦ អង្គការបានបើកយុទ្ធនាការចាប់ខ្លួននិងកម្ទេចប្រជាជនជាប់និន្នាការនយោបាយ ជាប់សាច់ញាតិបងប្អូននឹងអតីតទាហាន ប៉ូលិស គ្រូបង្រៀន និងសក្តិភូមិម្ចាស់ដីនៃរបបសាធារណរដ្ឋខ្មែរ និងប្រជាជនមានកំហុសដូចជា

វត់ចោលកងសហករណ៍ និយាយស្តីប្រឆាំងបដិវត្តន៍និងខុសសីលធម៌ជាដើម ។ យុទ្ធនាការនេះបានចាប់ផ្តើមធ្វើឡើងតាំងពីឆ្នាំ១៩៧៥ ហើយបន្តអនុវត្តរហូតដល់ចុងឆ្នាំ១៩៧៨ ។ ក្នុងរបាយការណ៍ចុះថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៧ របស់សមមិត្ត យុន គណៈឃុំស្រែរនោង ផ្ញើជូនអង្គការបក្សស្រុកត្រាំកក់ បានបញ្ជាក់នៅខាងចុងលិខិតរបស់គាត់ជូនអង្គការថា «ចំពោះប្រជាជនថ្មីនៅមានច្រើនទៀតដែលប្រឆាំងនឹងអង្គការបក្ស ហេតុនេះខ្ញុំនឹងចាប់បញ្ជូនទៅជាបន្តបន្ទាប់ទៀត ។ ភារកិច្ចបម្រើបក្សដាច់ខាត ។ ស្រែរនោងថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៧ ។ ហត្ថលេខា យុន» ។ (ឯកសារ D០០២២៧) ។

ប្រព័ន្ធគ្រប់គ្រងនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់គឺសមមិត្ត អាន់ មានភារកិច្ចសួរចម្លើយ ហើយ សមមិត្ត ចេង មានភារកិច្ចកត់ត្រាចម្លើយសារភាពរបស់អ្នកទោសដោយដៃដាក់ក្នុងសៀវភៅរួចប្រគល់ទៅឲ្យសមមិត្ត អាន់ វិញ ។ សមមិត្ត អាន់ យកសៀវភៅនោះទៅឲ្យសមមិត្ត ឌុច ដើម្បីវាយអង្គុលីលេខ ។ បន្ទាប់ពីវាយអង្គុលីលេខរួច សមមិត្ត ឌុច បានយកទៅប្រគល់ឲ្យសមមិត្ត អាន់ វិញ រួចប្រគល់ឲ្យថ្នាក់លើបន្តទៀតដើម្បីពិនិត្យនិងសម្រេច ។ ចំណាររបស់សមមិត្ត ប្រាក់ គណៈតំបន់១៣ ចំនួន១៥សន្លឹក បង្ហាញថា សមមិត្ត អាន់ ពិតជាបានផ្ញើចម្លើយសារភាពរបស់អ្នកទោសដែលវាយអង្គុលីលេខរួចនេះទៅជូនគណៈតំបន់ ហើយ ចំណាររបស់សមមិត្ត ប្រាក់ បង្ហាញថាគាត់បានទទួលនិងសម្រេចវាសនាអ្នកទោសដោយ«កម្ទេចចោល» ឬ «សួរបន្ត» ។

នៅចុងបញ្ចប់មន្ទីរអប់រំរបស់ស្រុកត្រាំកក់របស់ខ្មែរក្រហមបានបន្សល់ទុកនូវរណ្តៅសាកសពរួមចំនួន២១ រណ្តៅ និងមានប្រជាជនចំនួន១០.០៤៥នាក់ស្លាប់ ព្រមទាំងអគារគុកចាស់ៗដែលពោរពេញទៅដោយខ្នោះឃ្នាងរដូករណែល ។ សព្វថ្ងៃក្នុងបរិវេណអតីតមន្ទីរអប់រំរបស់ស្រុកត្រាំកក់ មានរោងដាក់អដ្ឋិធាតុមួយធ្វើពីឈើទទឹង៣ម៉ែត្រនិងបណ្តោយ៥ម៉ែត្រ និងសាលាឆទាន (សាលាសំណាក់) មួយធ្វើអំពីឈើទំហំ៥ម៉ែត្រ និង៨ម៉ែត្រត្រូវរដ្ឋអំណាចសាងសង់ឡើងបន្ទាប់ពីថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ។ រោងនេះសង់ឡើងដើម្បីប្រារព្វពិធីបុណ្យប្រចាំឆ្នាំក្នុងភូមិ ដើម្បីឧទ្ទិសមគ្គផលដល់អ្នកដែលបានស្លាប់ក្នុងមន្ទីរអប់រំរបស់ស្រុកត្រាំកក់នេះ ។

## ស្រុកទ្រាំង

### ១០) មន្ទីរសន្តិសុខភ្នំសន្ទុង

មន្ទីរសន្តិសុខភ្នំសន្ទុងត្រូវបានបង្កើតឡើងកាលពីជំនាន់-ខ្មែរក្រហមដើម្បីឃុំឃាំងអ្នកទោសជាខ្មាំងរបស់អង្គការ ។ មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងភូមិស្រះត្រកួន ឃុំសន្ទុង ស្រុកទ្រាំង ខេត្តតាកែវ ។

រហូតមកដល់សព្វថ្ងៃនេះ អតីតមន្ទីរសន្តិសុខភ្នំសន្ទុងពុំមានបន្សល់ទុកនូវស្លាកស្នាមអ្វីបន្តិចឡើយ ក្រៅពីដើមឈើធំៗដែលដុះប្រជ្រៀតគ្នាស្មុកស្មះនិងគ្របពីលើរណ្តៅសាកសពដែលនៅក្បែរនោះ ។

### ១១) មន្ទីរសន្តិសុខវត្តជើងចាប

វត្តជើងចាបស្ថិតនៅក្នុងឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ ។ នៅមិនឆ្ងាយប៉ុន្មានពីភូមិព្រៃផ្អាវមានវត្តមួយឈ្មោះថា វត្តជើងចាប និងមានតម្កល់អដ្ឋិធាតុជនរងគ្រោះជាច្រើនដែលស្លាប់កាលពីជំនាន់ខ្មែរក្រហម ។ កាលនោះ វត្តជើងចាបគឺជាមន្ទីរសន្តិសុខ ។ សំណង់ផ្សេងៗដែលមាននៅក្នុងបរិវេណវត្តជើងចាប ត្រូវខ្មែរក្រហមបំផ្លាញខ្ទេចខ្ទី នៅពេលចាប់ផ្តើមយកវត្តនេះធ្វើជាមន្ទីរសន្តិសុខ ។ ចេតិយនិងព្រះវិហារត្រូវខ្មែរក្រហមដាក់មីនឲ្យផ្ទុះបំផ្លាញចោល ។

ក្រោយឆ្នាំ១៩៧៩ សំណង់នេះត្រូវប្រជាជនរុះរើសល់តែកម្រាលឥដ្ឋប៉ុណ្ណោះ ។ នៅលើកម្រាលឥដ្ឋមាននៅសល់ខ្នោះដែកដែលបណ្តុះភ្ជាប់ទៅក្នុងស៊ីម៉ងត៍ ។ តាមព័ត៌មានដែលផ្តល់មកថាជនរងគ្រោះដែលខ្មែរក្រហមសម្លាប់នៅក្នុងមន្ទីរសន្តិសុខវត្តជើងចាបនេះគឺមានមួយចំនួនត្រូវកងឈ្លបយកទៅកប់នៅក្បែរៗគល់ដូងក្នុងរបងវត្តតែម្តង ។ ចំណែកមួយចំនួនទៀតយកទៅសម្លាប់ចោលនៅទីតាំងពិឃាតផ្សេងពីនេះ ដែលបច្ចុប្បន្នទីតាំងទាំងនោះបានក្លាយទៅជាភូមិករបស់ប្រជាជនអស់ទៅហើយ ។ ចំណែករណ្តៅសាកសពទាំងប៉ុន្មាន ក៏ត្រូវប្រជាជន សាងសង់ផ្ទះពីលើអស់ដែរ ។

***(នៅមានត)***

**ផេង ពងរ៉ាស៊ី**

# តម្លៃនៃការនិយាយពីជម្លោះអតីតកាល

**(តពីលេខមុន)**

***តម្លៃសំខាន់នៃការនិទានរឿងទាក់ទងទៅនឹងតុលាការខ្មែរក្រហម***

*នាយករដ្ឋមន្ត្រីរបស់ប្រទេសកម្ពុជាលោក ហ៊ុន សែន បាននិយាយនៅពេលមួយនោះថា «ជីករណ្តៅកប់រឿងរ៉ាវអតីតកាល» ។ សម្តីនេះមិនមែនជាការឆ្លុះបញ្ចាំងពីសម្តីរបស់សម្តេច ហ៊ុន សែន នៅពេលបច្ចុប្បន្ននេះទេ ប៉ុន្តែវាបញ្ជាក់ពីចំណុចសំខាន់មួយ ។ នៅប្រទេសកម្ពុជាអតីតកាលត្រូវបាននិទានបង្កើត និងធ្វើឲ្យមានទំនាក់ទំនង ឬមិនទំនាក់ទំនងគឺផ្អែកលើអ្វីដែលបម្រើដល់ផលប្រយោជន៍នយោបាយ ។*

*ដូចនេះហើយវាជាហេតុផលមួយដែលខ្ញុំធ្វើការអះអាងថា វាមានសារសំខាន់ណាស់ដែលសាធារណជនត្រូវតែដឹងពីភាពពិតប្រវត្តិសាស្ត្រទៅនឹងរឿងរ៉ាវដែលបានកើតឡើងដែលសហគមន៍អាចរាប់ពីការចែករំលែកការយល់ដឹងពីអ្វីដែលបានកើតឡើងនៅរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ប្រហែលជាការនិយាយរឿងប្រាប់ និងនិទានកថាទាក់ទងទៅនឹងតុលាការអាចចែករំលែកក្នុងការបង្កើតទម្រង់ការឆ្លុះបញ្ចាំងប្រវត្តិសាស្ត្រនិងមនសិការប្រវត្តិ-សាស្ត្រក្នុងការជាសះស្បើយ ការផ្សះផ្សា និងសន្តិភាពយូរអង្វែង ។*

*រ៉ូប៊ីត ប៊ុទី ជាមេធាវីកាណាដាម្នាក់មានបទពិសោធន៍តុលាការព្រហ្មទណ្ឌនៅប្រទេសរ៉ាន់ដា សេរ៉ាឡេអូន កូសូវ៉ូ និងទីម័រខាងកើត ត្រូវបានជ្រើសតាំងដោយអង្គការសហប្រជាជាតិដើម្បីដឹកនាំការសហការជាមួយមេធាវីកម្ពុជាលោកស្រី ជា លាង នៅក្នុងដំណើរការតុលាការនេះ ។ នៅក្នុងបទសម្ភាសន៍មួយជាមួយ តូរ៉ូនតូ លោក រ៉ូប៊ីត ប៊ុទី និយាយថា «យើងដឹងថាតុលាការនេះត្រូវបានរំពឹងថានឹងជួយប្រជាជនដើម្បីដោះស្រាយ និងចេញផុតពីសោកនាដកម្មដ៏សោកសៅនេះ ។ តុលាការនេះមានអាណត្តិច្បាស់លាស់ ប៉ុន្តែត្រូវតែធ្វើការរួមចំណែកទៅដល់កម្រិតបុគ្គលជាតិនិងអន្តរជាតិ» ។*

*នៅក្នុងបទសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី លោក រ៉ូប៊ីត ប៊ុទី ពិពណ៌នាពីស្ថានភាពដូចខាងក្រោមនេះ «ប្រជាជនកម្ពុជាជាច្រើនមានការស្ទាក់ស្ទើរក្នុងការនិយាយពីរឿងដែលបានកើតឡើង ហើយម្យ៉ាងវិញទៀតរដ្ឋាភិបាលរបស់ខ្លួនពុំមានការលើកទឹកចិត្តដល់ការពិភាក្សាពីបញ្ហានេះ ។ សៀវភៅរបស់សិស្សសាលាក៏ពុំមាននិយាយពីបញ្ហានេះ ។ ប្រជាជនជាច្រើននៅតែមិនដឹងពីមូលហេតុដែលខ្មែរក្រហមសម្លាប់ប្រជាជនស្លូតត្រង់ជាច្រើននាក់» ។*

*រ៉ូប៊ីត ប៊ុទី កំពុងនិយាយពីកង្វះខាតចំណេះដឹងដែលមិនមាននៅក្នុងតុលាការដែលគាត់ធ្លាប់ធ្វើការ ។*

*មានការអះអាងថា តុលាការនេះនឹងនាំដល់ប្រជាជនកម្ពុជា*



***ហាកិម-ខ្លូន ទស្សនាអគារមន្ទីរស-២១***

នូវចំណេះដឹងថ្មីមួយ និងចំណាប់អារម្មណ៍ចង់ដឹងពីអ្វីដែលបានកើតឡើងពិតប្រាកដនៅរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ និងអាចជាធាតុសំខាន់មួយនាំឲ្យប្រជាជនកម្ពុជាមានសន្តិភាពនិងផ្សះផ្សារឿងរ៉ាវពីអតីតកាល ។ ម្យ៉ាងវិញទៀតមានអ្នកពន្យល់ខ្លះមានអំណះអំណាងថា ការបង្ហាញការពិតពីអតីតកាលនឹងនាំឲ្យមានជម្លោះហិង្សានិងការសងសឹក ។

អង្គជំនុំជម្រះនិងខិតខំប្រឹងប្រែងដើម្បីធានាឲ្យមានការចូលរួមនៅក្នុងដំណើរការតុលាការនេះពីសំណាក់ប្រជាជនយ៉ាងច្រើន ។ រថយន្តដឹកប្រជាជនមិនគិតថ្លៃត្រូវបានរៀបចំដើម្បីដឹកអ្នកមកកាន់តុលាការ ហើយសវនាការកាត់ទោសនឹងផ្សព្វផ្សាយជាសាធារណៈតាមកញ្ចក់ទូរទស្សន៍ និងវិទ្យុ និងមានការបោះពុម្ពជាកូនសៀវភៅតូចៗដែលជូនដំណឹងដល់ប្រជាជនអំពីមុខងាររបស់តុលាការ និងប្រាប់ប្រជាជនឲ្យចូលរួម ។ លើសពីនេះទៀតមានអង្គការក្រៅរដ្ឋាភិបាលផ្សេងៗបានចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មាននិងចំណេះដឹងទាក់ទងនឹងតុលាការនេះថែមទៀត ។



អង្គការក្រៅរដ្ឋាភិបាលមួយចំនួនកំពុងតែប្រើប្រាស់តុលាការនេះដើម្បីអប់រំប្រជាជនកម្ពុជាអំពីទំនាក់ទំនងរវាងមូលហេតុដែលនាំឲ្យកើតមានអំពើឃោរឃៅនេះ ពីការប្រឈមមុខពេលបច្ចុប្បន្ននិងតម្លៃជាមួយនឹងចំណេះដឹង និងយុទ្ធសាស្ត្រដែលចាំបាច់ក្នុងការបង្កើតសង្គមអនាគតមួយល្អប្រសើរ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាស្ថាប័នមួយដែលចូលរួមយ៉ាងសំខាន់នៅក្នុងដំណើរការនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាជាអង្គការក្រៅរដ្ឋាភិបាលមួយដែលបង្កើតឡើងដោយលោក ឆាំង យុ ដែលជាសាក្សីម្នាក់ និងជាអ្នករស់រានមានជីវិតពីរបបកំណាចនេះ ។ តាមរយៈការចងក្រងព័ត៌មានប្រវត្តិសាស្ត្រឥតឈប់ឈរដែលអាចប្រើប្រាស់ជាភ័ស្តុតាងសម្រាប់តុលាការ លោក ឆាំង យុ និងបុគ្គលិកទាំងអស់ត្រូវបានមើលឃើញថាជាមូលហេតុចម្បងដែលតុលាការនេះជាចុងបញ្ចប់ត្រូវបានបង្កើតឡើង ។

នៅលើគេហទំព័ររបស់ខ្លួន មជ្ឈមណ្ឌលបានបង្ហាញពីគោលបំណងសំខាន់របស់ខ្លួន៖ «មជ្ឈមណ្ឌលមានគោលបំណងសំខាន់ពីរ ។ ទីមួយគឺដើម្បីចងក្រង និងថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យសម្រាប់ក្មេងៗជំនាន់ក្រោយ ។ គោលបំណងទីពីរគឺចងក្រងនិងប្រមូលព័ត៌មានដែលអាចប្រើប្រាស់ជាភ័ស្តុតាងក្នុងការដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហម ។ គោលបំណងទាំងនេះបង្ហាញពីការជំរុញរបស់យើងលើបញ្ហាចងចាំនិងយុត្តិធម៌ ដែលទាំងពីរនេះជាមូលដ្ឋានគ្រឹះសម្រាប់នីតិរដ្ឋនិងការផ្សះផ្សានៅប្រទេសកម្ពុជា» ។

នៅក្នុងការខិតខំជាពិសេសមួយ ដែលធ្វើឡើងដោយមជ្ឈ-មណ្ឌលឯកសារកម្ពុជាដើម្បីធានានូវយុត្តិធម៌អន្តរកាលទាក់ទងនឹងតុលាការនេះ មជ្ឈមណ្ឌលបានបង្កើតដំណើរទស្សនកិច្ចនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតជើងឯក និងអគារតុលាការ ។ ដំណើរទស្សនកិច្ចនេះជាកម្មវិធីរបស់ «គម្រោងឯកសាររស់» ។ គម្រោងនេះផ្តួចផ្តើមឡើងដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ទីបីរ ក្រូស មកពី *The Christian Science Monitor* បានសម្ភាសជាមួយលោក លី សុខឃាង ជាអ្នកគ្រប់គ្រងដំណើរទស្សនកិច្ចនេះបាននិយាយថា «ប្រជាជនរស់រានជីវិតភាគច្រើនដែលរស់នៅសហគមន៍ដាច់ស្រយាលមានការចងចាំអំពើឃោរឃៅនេះខុសគ្នា» ។ «ប្រជាជនជាច្រើនមិនដឹងពីអ្វីដែលកើតឡើងនៅខេត្តជិតខាងគ្នាផងទេ» ។ ចាប់តាំងពីខែកុម្ភៈមក ជារៀងរាល់ខែស្ថាប័នស្រាវជ្រាវដែលបង្កើតឡើងដោយសាកលវិទ្យាល័យយែលនៅឆ្នាំ១៩៩៥នេះ បានអញ្ជើញអ្នកភូមិមកភ្នំពេញមានចំនួនពី៤០០ ទៅ៥០០នាក់ដើម្បីបង្ហាញពីឯកសារ ជំរុញគាត់ឲ្យចែករំលែកបទពិសោធន៍គ្នា និងពន្យល់គាត់ត្រួសៗពីតុលាការដែលគាំទ្រដោយអង្គការសហប្រជាជាតិនេះ ។ សុខឃាង បន្ថែមថា «ប្រសិនបើអ្នកភូមិអាចឃើញពីទំហំរបស់ឧក្រិដ្ឋកម្ម គាត់នឹងយល់ពីអ្វីដែលបានកើតឡើង មិនមែនត្រឹមតែចំពោះខ្លួនគាត់ប៉ុណ្ណោះទេ តែចំពោះសង្គមទាំងមូល» ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញអ្នកភូមិជាង៩០០០ នាក់ពីទូទាំងប្រទេសដើម្បីទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ វាលពិឃាតជើងឯកនិងអគារតុលាការ ។ រហូតមកដល់ពេលនេះមានអ្នកដឹកនាំនយោបាយតាមមូលដ្ឋានជាង១៣០០ នាក់មកពីតំបន់ផ្សេងទូទាំងប្រទេសកម្ពុជាបានចូលរួមនៅក្នុងដំណើរទស្សនកិច្ចដែលជាផ្នែកមួយរបស់ឯកសាររស់មានឈ្មោះថាដំណើរទស្សនកិច្ចអគារតុលាការរបស់មេឃុំ ។

ដំណើរទស្សនកិច្ចរបស់មេឃុំនេះត្រូវបានរៀបចំឡើងសម្រាប់ថ្នាក់ដឹកនាំនយោបាយនៅមូលដ្ឋាន មេភូមិមកពីទូទាំងប្រទេសដើម្បីរៀនសូត្រពីតុលាការ និងពីរបៀបដែលរឿងត្រូវបានភ្ជាប់ជាមួយអំពើយង់ឃ្នងពីអតីតកាលដែលត្រូវបានបង្ហាញនៅទីវាលចងចាំ ។ ចំពោះអ្នកចូលរួមភាគច្រើនការមកទស្សនាកន្លែងនេះគឺជាលើកដំបូងនៅក្នុងជីវិតរបស់គាត់ ។ បន្ទាប់ពីការទស្សនាទីវាលចងចាំក្រុមនេះ អ្នកចូលរួមបានទស្សនាអគារតុលាការ ។ នៅទីនោះអ្នកស្រុកអង្គុយនៅកន្លែងដែលអង្គសវនាការនឹងត្រូវធ្វើឡើង ហើយយល់ដឹងពីតួនាទីនិងមុខងាររបស់តុលាការ ។ ពិសេសទៀតនោះមុនពេលចាកចេញទៅកាន់លំនៅដ្ឋានខ្លួនវិញ ប្រជាជនបាននាំយកនូវកូនសៀវភៅដើម្បីចែកជូនប្រជាជនក្នុងភូមិគាត់ ។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំនូវដំណើរទស្សនកិច្ចស្រដៀងគ្នាមួយឲ្យសិស្សានុសិស្សនៅវិទ្យាល័យមានចំនួន៣៤៣នាក់ ។ នេះជាដំណើរទស្សនកិច្ចសិក្សាលើកទីមួយដែលត្រូវបានរៀបចំនៅប្រទេសកម្ពុជាចាប់តាំងពីមានអំពើប្រល័យពូជសាសន៍មក ។ ភាគច្រើនសិស្សានុសិស្សមានអាយុចន្លោះពី១៧ឆ្នាំនិង២០ឆ្នាំ ហើយនេះជាលើកដំបូងរបស់សិស្សានុសិស្សដែលបានមកទស្សនានៅនឹងកន្លែងទាំងនេះ ។ របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាពីដំណើរ ទស្សនកិច្ចនេះបានឲ្យដឹងថា «ដំណើរទស្សនកិច្ចនេះបានផ្តល់ឲ្យសិស្សានុសិស្សនូវពេលវេលានិងឱកាសបានទស្សនាទីកន្លែងនៅក្រៅថ្នាក់រៀនដែលជាការដាស់ស្មារតីនិងទាញការយកចិត្តទុកដាក់របស់សិស្ស ។ ដំណើរទស្សនកិច្ចនេះបានធ្វើឲ្យសិស្សានុសិស្សឃើញនូវភាពភ័យរន្ធត់ក្នុងអតីតកាលរបស់ឪពុកម្តាយនិងប្រទេសជាតិរបស់ខ្លួន ។ ដំណើរទស្សនកិច្ចនេះបានបង្ហាញឃើញអំពីយុត្តិធម៌មួយតាមផ្លូវច្បាប់និងតាមស្តង់ដារអន្តរជាតិ និងជំរុញសិស្សានុសិស្សឲ្យគិតអំពីអតីតកាល បច្ចុប្បន្នកាលនិងអនាគតរបស់ប្រទេសខ្លួន ។ គឹម ធារិទ្ធិ ជាយុវជនចំណោមយុវជនកម្ពុជាទាំងឡាយមានចម្ងល់លើការកាប់សម្លាប់ ។ ធារិទ្ធិ អាយុ១៩ឆ្នាំ បាននិយាយថា បន្ទាប់ពីបានដើរមើលតាមអគារនៃសារមន្ទីរប្រល័យពូជសាសន៍មក គាត់ជឿលើរឿងរ៉ាវដែលឪពុកម្តាយរបស់គាត់បាននិយាយប្រាប់» ។

នេះជាផ្នែកមួយនៃដំណើរទស្សនកិច្ចរបស់គម្រោងឯកសាររស់ ការប្រាប់រឿងសាហាវឃោរឃៅពីអតីតកាលត្រូវបានផ្តល់ឲ្យនូវតម្លៃជាក់លាក់មួយ ការចូលរួមវិភាគទានចំពោះដំណើរការនៃការយោគយល់គ្នាក្នុងសង្គម ការធ្វើឲ្យមានអំណាច ការផ្សះផ្សានិងការបង្កើតឲ្យមានវប្បធម៌ សន្តិភាព និងប្រជាធិបតេយ្យយូរអង្វែងនៅក្នុងប្រទេសកម្ពុជា ។

តើយើងអាចយល់បានជាទ្រឹស្តីអំពីដំណើរការឯកសាររស់នៅក្នុងប្រទេសកម្ពុជា និងដំណើរទស្សនកិច្ច នៅស៊ីតេសិនអាគីវេត ដែលជាការចូលរួមចំណែកទៅលើការប្រាប់ពីគោលបំណងដ៏សំខាន់បានដោយរបៀបណា? **(នៅមានត)**

**ឌឺធីល ក្រូឌឹម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Chambres Extraordinaires au sein
des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007**

# ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន
# Provisional detention Order
# Ordonnance de placement en détention provisoire

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤
បានឃើញវិធាន ៦៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ
បានឃើញការបើកការស៊ើបសួរលើឈ្មោះ
អៀង សារី ហៅ វ៉ាន់
កើតនៅថ្ងៃទី ២៤ តុលា ឆ្នាំ ១៩២៥

ត្រូវដាក់អោយស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និង ការលោភបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ១៩៤៩ ដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៥ មាត្រា ៦ មាត្រា ២៩ ថ្មី និងមាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញថ្ងៃទី២៧ តុលា ២០០៤។

បានឃើញការជជែកដេញដោលដែលបានធ្វើនៅថ្ងៃនេះ

## ១- ស្ថានភាពអង្គហេតុ និង អង្គច្បាប់

១- នៅក្នុងករណីបច្ចុប្បន្ន (ដោយមិនប៉ះពាល់ដល់លទ្ធផលនៃការស៊ើបសួរដែលកំពុងដំណើរការ ដែលអាចអោយកំណត់ជាបទល្មើសផ្សេងទៀតដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរ និង ដែលអាចដាក់បន្ទុកលើជនត្រូវចោទ) ឈ្មោះ **អៀង** សារី ត្រូវបានដាក់អោយស្ថិតនៅក្រោមការពិនិត្យអំពី ៖

- **បទល្មើសប្រឆាំងនឹងមនុស្សជាតិ** (មនុស្សឃាត ការដាក់ឃុំឃាំង ការធ្វើទុកបុកម្នេញ ការសំលាប់បំផុតពូជ និង អំពើអមនុស្សធម៌ដទៃទៀត) និង
- **បទឧ**ក្រិដ្ឋសង្គ្រាមដែលផ្អែកលើការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៤៩ (មនុស្សឃាតដោយចេតនា ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើអោយឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ និង សុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការនិរទេស ឬ ជន្លៀស ឬ ការបង្ខាំងជនស៊ីវិលដោយខុសច្បាប់)

២- ជននេះត្រូវបានដាក់បន្ទុកថាបានប្រព្រឹត្ត នៅលើទឹកដីនៃប្រទេសកម្ពុជារវាងថ្ងៃ ១៧ មេសា ១៩៧៥ និង ថ្ងៃទី ៦ ខែ មករា ១៩៧៩ ៖

- ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងការបរទេសដែលមានអំណាច និងការត្រួតពិនិត្យជាក់ស្តែងលើក្រសួងនេះ និង ស្ថាប័នក្រោមចំណុះ និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា
- បានញុះញង់ បញ្ជា ខកខានមិនបានទប់ស្កាត់ និងផ្តន្ទាទោស ឬម្យ៉ាងទៀតបានសមគំនិតក្នុងការប្រព្រឹត្តបទល្មើសខាងលើ
- ដោយដឹកនាំ ជំរុញ ដាក់អោយដំណើរការ ឬ ផ្តល់ជំនួយក្រោមរូបភាពផ្សេងទៀតដល់នយោបាយ និង ការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជាដែលចារឹកលក្ខណៈជា មនុស្សឃាត ការដាក់ឃុំឃាំង ការសំលាប់បំផុតពូជ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬ អំពើអមនុស្សធម៌ដទៃទៀតដូចជាការជន្លៀសដោយបង្ខំ ការដាក់ជាទាសករ ឬការធ្វើការដោយបង្ខំ
- នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ និង ជាប្រព័ន្ធ សំដៅលើជនស៊ីវិល

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។



Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

- ដោយបញ្ជាក់ថា ក្នុងកំឡុងពេលទាំងអស់ ឬមួយផ្នែកនៃចន្លោះថ្ងៃទី១៧ មេសា ១៩៧៥ និង ថ្ងៃទី៦ មករា ១៩៧៩ កម្ពុជាប្រជាធិបតេយ្យ និង សាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្ថិតនៅក្នុងស្ថានភាពនៃជំលោះប្រដាប់អាវុធអន្តរជាតិជាមួយគ្នា។

៣- សហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញដែលបានបង្ហាញទឡ្ហីករណ៍ខាងអង្គហេតុ និង អង្គច្បាប់របស់ខ្លួននៅក្នុងសេចក្តីសន្និដ្ឋានដែលបានដាក់នៅក្នុងសំណុំរឿងចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៧ និង ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ បានស្នើសុំការឃុំខ្លួនបណ្តោះអាសន្នចំពោះ **អៀង សារី** ដើម្បីធានាវត្តមានរបស់ជននេះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញដោយសំអាងថា ជននេះមានលិខិតឆ្លងដែន និង មានហានិភ័យថាអាចរត់គេចខ្លួន ។ ម៉្យាងវិញទៀត ការឃុំខ្លួនជននេះជាបណ្តោះអាសន្នត្រូវធ្វើឡើងដើម្បីបង្ការរាល់អំពើសងសឹកពីសំណាក់ជនរងគ្រោះ និង ដើម្បីជៀសវាងរាល់ការដាក់សម្ពាធលើសាក្សី។

៤- **អៀង សារី** ជំទាស់នឹងអង្គហេតុដែលដាក់បន្ទុកលើខ្លួន ដោយប្រកាសថា “មានការចោទប្រកាន់មួយចំនួនដែលខ្លួនមិនអាចទទួលយកបានទេ” ហើយស្នើសុំអោយបង្ហាញភស្តុតាងអំពីពិរុទ្ធភាពរបស់ខ្លួន។ ជនត្រូវចោទបន្ថែមទៀតថា *“ខ្ញុំចង់ដឹងការពិតអំពីកំឡុងពេលខ្មៅងងឹតនៅក្នុងប្រវត្តិសាស្ត្ររបស់យើង។ ខ្ញុំមិនដឹងថាការពិតនៅឯណានោះទេ។ ខ្ញុំសប្បាយចិត្តណាស់ដែលតុលាការនេះត្រូវបានបង្កើតឡើង ពីព្រោះថានេះនឹងក្លាយជាឱកាសសម្រាប់ខ្ញុំក្នុងការស្វែងរកការពិត ក៏ដូចជាចូលរួមចំណែកនូវអ្វីដែលខ្ញុំដឹងផងដែរ”* ។ គាត់ស្នើសុំស្ថិតនៅក្រៅឃុំ ដោយភ័យខ្លាចស្លាប់នៅក្នុងមន្ទីរឃុំឃាំងមុនពេលដឹងអំពីការពិត និង លើកឡើងថាប្រសិនគាត់ស្លាប់បាត់ទៅ ជនរងគ្រោះទីមួយ គឺគ្រួសាររបស់ខ្ញុំ តែជនរងគ្រោះទីពីរគឺតុលាការដែលនឹងបាត់សាក្សីមួយយ៉ាងសំខាន់ ហើយនឹងត្រូវគេរិះគន់ជាមិនខាន។ ជនត្រូវចោទអះអាងថាខ្លួនមិនដែលមានចេតនាលូកដៃចូលនៅក្នុងនីតិវិធីឡើយ ដោយគូសបញ្ជាក់ថាខ្លួនរស់នៅក្រៅឃុំជាច្រើនឆ្នាំមកហើយ និងមានដឹងអំពីលទ្ធភាពនៃការចោទប្រកាន់លើខ្លួនជាយូរណាស់មកហើយ ហើយខ្លួនក៏អាចមានលទ្ធភាពធ្វើអន្តរាគមន៍លើសាក្សីផងដែរ តែខ្លួនមិនបានធ្វើឡើយ។ ជនត្រូវចោទសូមអោយកត់សំគាល់ថាគាត់មានអាយុច្រើនហើយមានជម្ងឺទៀត។ ជនត្រូវចោទទទូចថាគ្មានហានិភ័យនៃការរត់គេចខ្លួនទេ ដោយប្រកាសថាត្រៀមខ្លួនជាស្រេចក្នុងការចូលខ្លួនតាមការកោះហៅ និង បានបញ្ជាក់ថាអាយុ និង ស្ថានភាពសុខភាពរបស់ខ្លួនមិនអាចរត់គេចខ្លួនបានទេ ។ ម៉្យាងទៀត បើខ្លួនមានបំណងចង់រត់គេចនោះ គាត់នឹងរត់គេចតាំងពីយូរណាស់មកហើយ។ ពាក់ព័ន្ធនឹងហានិភ័យនៃការសងសឹក ចាប់តាំងពីការធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាល គាត់មិនដែលទទួលរងការគម្រាមកំហែងណាមួយកើតឡើងទេ ទោះនៅទីក្រុងប៉ៃលិន ឬ នៅក្រុងភ្នំពេញក៏ដោយ។ ផ្ទុយទៅវិញ ជនត្រូវចោទបានរំលឹកចាប់តាំងពីការកាត់ទោសដោយតុលាការបដិវត្តន៍ប្រជាជន នៅទីក្រុងភ្នំពេញកាលពីថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ គាត់បានទទួលការលើកលែងទោសដោយព្រះមហាក្សត្រកាលពីថ្ងៃទី ១៤ កញ្ញា ១៩៩៦ និង មិនដែលមានចលាចលណាមួយកើតមានឡើងនោះទេ បន្ទាប់ពីការសម្រេចនេះ។ ជនត្រូវចោទគូសបញ្ជាក់ថាដោយសារតែខ្លួន ទើបកងទ័ពខ្មែរក្រហមបានធ្វើសមាហរណកម្មជា

មួយរដ្ឋាភិបាល និង លើកឡើងថាខ្លួនបានរួមវិភាគទានក្នុងការកសាងសន្តិភាពផងដែរ។ ជាចុងបញ្ចប់ ជនត្រូវចោទស្នើសុំស្ថិតនៅក្រៅឃុំក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

## <u>២- សំអាងហេតុសេចក្តីសម្រេច</u>

៥- មុនសម្រេចលើការឃុំខ្លួនបណ្តោះអាសន្នរបស់ **អៀង សារី** យើងត្រូវរំលឹកអំពីស្ថានភាពពិសេសរបស់ជននេះ ដែលចោទជាបញ្ហាពិសេសដែលសហចៅក្រមស៊ើបអង្កេតដែលមានកាតព្វកិច្ចរកភស្តុតាងដាក់បន្ទុក និង ដោះបន្ទុកត្រូវសម្រេច។ តាមរយៈសាលក្រមរបស់តុលាការបដិវត្តន៍នៅភ្នំពេញចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៩៧៩ អៀង សារី ត្រូវបានផ្តន្ទាទោសប្រហារជីវិតដោយកំបាំងមុខ និង រឹបអូសទ្រព្យសម្បត្តិ ចំពោះបទល្មើសប្រល័យពូជសាសន៍[1]។ ជាការជាក់ស្តែង សាលក្រមនេះចូលជាស្ថាពរតាមច្បាប់កម្ពុជា។ បន្ទាប់មក អនុលោមតាមព្រះរាជក្រឹត្យចុះថ្ងៃទី ១៤ កញ្ញា ឆ្នាំ ១៩៩៦ អៀង សារីបានទទួលការអនុគ្រោះទោសចំពោះការផ្តន្ទាទោសនេះ និង ការលើកលែងទោសចំពោះច្បាប់ ចុះថ្ងៃទី ១៤ កក្កដា ឆ្នាំ ១៩៩៤ "ស្តីអំពីការដាក់ខ្មែរក្រហមអោយនៅក្រៅច្បាប់"។

៦- ស្ថានភាពនេះចោទជាបញ្ហាផ្លូវច្បាប់មួយចំនួន ៖ ជាបឋម តើការចោទប្រកាន់បច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប៉ះពាល់ដល់អាជ្ញាអស់ជំនុំ ដោយអនុលោមតាមការអនុវត្តទ្រឹស្តីទូទៅ "*Non bis in idem*ឬទេ? = ជនម្នាក់មិនអាចត្រូវបានចោទប្រកាន់ ឬ ផ្តន្ទាទោស ចំពោះបទល្មើសដែលត្រូវបានសម្រេចថាគ្មានទោស ឬ ផ្តន្ទាទោសរួចហើយនោះទេ? "។ ជាបន្តទៀត នៅពេលដែលមានចម្លើយអវិជ្ជមានចំពោះសំណួរទី ១ នេះ ( និងថាសហចៅក្រមស៊ើបអង្កេតមានសមត្ថកិច្ចដើម្បីសម្រេចលើវិសាលភាពនៃព្រះរាជក្រឹត្យឆ្នាំ ១៩៩៦) តើការអនុគ្រោះទោស និង ការលើកលែងទោសដល់អៀង សារី អាចយកមកតតាំងបានចំពោះការចោទប្រកាន់នៅអង្គជំនុំជម្រះវិសាមញ្ញដែរឬទេ? យើងនឹងពិនិត្យមើលលើបញ្ហាទាំងនេះដូចខាងក្រោម ។

### <u>*ក- Non bis in idem*</u>

៧- អនុលោមតាមមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវគោរពតាម "*ជនម្នាក់មិនអាចត្រូវបានចោទប្រកាន់ ឬ ផ្តន្ទាទោសចំពោះបទល្មើសដែលត្រូវបានសម្រេចថាគ្មានទោស ឬ ផ្តន្ទាទោសដោយសាលក្រមស្ថាពរតាមច្បាប់ និង នីតិវិធី*

[1] សាលាក្រមតុលាការប្រជាជនបដិវត្តន៍ ឯកសារ អង្គការសហប្រជាជាតិ ក/៣៤/៤៩១ ១៩ សីហា ឆ្នាំ ១៩៧៩

*ព្រហ្មទណ្ឌរបស់ប្រទេសនីមួយៗ"*។ ប៉ុន្តែ គោលការណ៍នេះនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិមិនមានភាពដាច់ខាតនោះទេ។

៨- ដូចនេះ មានការទទួលស្គាល់ជារួម នៅក្នុងលក្ខន្តិកៈ និង ការអនុវត្តរបស់តុលាការអន្តរជាតិ និង តុលាការដែលមានចារឹកលក្ខណៈជាអន្តរជាតិថាគេអាចជំនុំជម្រះជនម្នាក់ចំពោះអង្គហេតុដូចគ្នា និង ក្រោមការកំណត់បទល្មើសដូចគ្នា ដូចជាក្នុងករណី " *នីតិវិធីនៅចំពោះមុខយុត្តាធិការផ្សេង៖ ក) មានគោលបំណងធ្វើអោយជនពាក់ព័ន្ធគេចផុតពីការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលចូលសមត្ថកិច្ចរបស់តុលាការ ខ) មិនបានដំណើរការដោយឯករាជ្យ ឬ អនាគតិ ដោយគោរពការធានាដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ ប៉ុន្តែដំណើរការឡើងដើម្បីតែបដិសេធគោលបំណងនាំជននោះមកកាន់តុលាការតែប៉ុណ្ណោះ*[2]។ ជាសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេតដែលដល់ពេលណាមួយ ត្រូវសម្រេចនៅពេលក្រោយថាតើត្រូវធ្វើការវិភាគស៊ីជម្រៅលើដំណើរការក្តីដែលប្រព្រឹត្តឡើងនៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍ឆ្នាំ ១៩៧៩។ នៅក្នុងគ្រប់ករណីទាំងអស់ បញ្ហាអនុវត្តដំណោះស្រាយនេះនៅក្នុងករណី**អៀង សារី**មិនទាន់ចោទឡើងភ្លាមៗនោះទេ ពីព្រោះថា ដោយមិនប៉ះពាល់ដល់ការស៊ើបសួរបន្ត **អៀង សារី**មិនទាន់ត្រូវបានចោទប្រកាន់អំពីបទល្មើសប្រល័យពូជសាសន៍នៅឡើយ។

៩- ទោះបីជាយ៉ាងណាក៏ដោយ យុត្តិសាស្ត្ររឹងមាំមួយរបស់តុលាការអន្តរជាតិបានកំណត់ថា នៅក្នុងករណីឧក្រិដ្ឋកម្មអន្តរជាតិ ការប្រកាសពិរុទ្ធភាពត្រួតគ្នាចំពោះអង្គហេតុតែមួយអាចធ្វើឡើងទៅបាន នៅពេលដែលបទល្មើសនីមួយៗមានធាតុផ្សំខុសគ្នាច្បាស់លាស់ ដែលបទល្មើសមួយទៀតគ្មាន[3]។ ដូចនេះ គេទទួលស្គាល់ថា ជនម្នាក់អាចត្រូវបានចោទប្រកាន់អំពីបទល្មើសប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និង បទឧក្រិដ្ឋសង្គ្រាម ចំពោះអង្គហេតុតែមួយនៅពេលដែលបទល្មើសអន្តរជាតិនីមួយៗមានធាតុផ្សំខុសគ្នាច្បាស់ពីបទល្មើសដទៃទៀត និង ការពារដល់ប្រយោជន៍ផ្សេងគ្នា[4]។ ដំណោះស្រាយនេះ ត្រូវបានអនុវត្តតាំងពីមុនឆ្នាំ ១៩៧៥ មក ហើយតុលាការយោធាអន្តរជាតិ Nuremberg

---

[2] មាត្រា ២០ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៩(២) នៃលក្ខន្តិកៈតុលាការនៅ RWANDA មាត្រា ១០ នៃលក្ខន្តិកៈតុលាការសម្រាប់អតីតយូហ្គោស្លាវី មាត្រា ២០ នៃលក្ខតិកៈទីក្រុងរ៉ូម មាត្រា ៩ នៃលក្ខន្តិកៈតុលាការសម្រាប់សេរ៉ាលេអូន និង បទបញ្ជារប់ ATNUTO លេខ ២០០០/១៥

[3] សាលក្រមសាលាឧទ្ធរណ៍របស់តុលាការសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-៩៦-២១-ក ព្រះរាជអាជ្ញា ជាមួយ Delalic et Consorts, ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០០១ កថាខ័ណ្ឌ ៤១២។

[4] មើលសាលក្រមសាលាដំបូងរបស់តុលាការសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-៩៥-១៦ ព្រះរាជអាជ្ញា ជាមួយ Kupreskic et Consorts, ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០០ កថាខ័ណ្ឌ ៦៣៧។ សាលក្រមសាលាដំបូងរបស់តុលាការសម្រាប់អតីតយូហ្គោស្លាវី សំណុំរឿងលេខ IT-៩៦-៤៦ ត ព្រះរាជអាជ្ញា ជាមួយ Jean-Paul Akayesu, ថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៨ កថាខ័ណ្ឌ ៤៦៨។ Timor Leste Special Panels, ការសម្រេចផ្នែកច្បាប់លើភាពដែលអាចអនុវត្តបាននៃគោលការណ៍ *Non bis in idem* លើដំណាក់កាលនីតិវិធីដីកាចាប់ខ្លួន រឿងក្តី Wiranto

ក៏បានសម្រេចដោយប្រកាសពិរុទ្ធភាពត្រួតគ្នាចំពោះអង្គហេតុតែមួយ[5]។ ដោយអនុវត្តតាមគោលការណ៍នេះ មិនមានអ្វីជាឧបសគ្គដល់ការចោទប្រកាន់ក្រោមការកំណត់បទល្មើសអន្តរជាតិផ្សេងពីបទប្រល័យពូជសាសន៍ លើ **អៀង សារី** ចំពោះអង្គហេតុដែលត្រូវបានកាត់សេចក្តីនៅឆ្នាំ ១៩៧៩ឡើយ។

១០ - នាចុងបញ្ចប់ សាលក្រមឆ្នាំ ១៩៧៩ មិនបានចង្អុលអស់អង្គហេតុដែលត្រូវបានដាក់**អៀង សារី** ក្រោមការពិនិត្យបច្ចុប្បន្ននេះ។ ដូចនេះ អាជ្ញាអស់ជំនុំមិនអាចលើកឡើងដោយស្របច្បាប់នៅពេលនេះបានឡើយ។

***ខ. វិសាលភាពអនុវត្តនៃការអនុគ្រោះទោស និង ការលើកលែងទោសឆ្នាំ ១៩៩៦***

១១. មាត្រា ៤០ នៃច្បាប់ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ (ស្របតាមមាត្រា ១១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣) បានប្រគល់ភារកិច្ចដល់អង្គជំនុំជម្រះវិសាមញ្ញដើម្បីសម្រេចលើ *"វិសាលភាពនៃការលើកលែងទោស និង ការអនុគ្រោះទោស ដែលអាចបានត្រូវផ្តល់អោយមុនពេលចូលជាធរមាននៃច្បាប់នេះ"* ។ នេះបង្កើតបានជាសេចក្តីយោងដោយផ្ទាល់ដល់ស្ថានភាព **អៀង** ***សារី***។ ក្នុងនាមជាអង្គតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញដែលទទួលបន្ទុកស៊ើបសួរដោះបន្ទុក និងដាក់បន្ទុកលើអង្គហេតុដែលចោទលើ **អៀង** ***សារី*** សហចៅក្រមស៊ើបអង្កេតមានសមត្ថកិច្ចដើម្បីជំនុំជម្រះលើវិសាលភាពនៃការលើកលែងទោស និង ការអនុគ្រោះទោស ដែលការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតនេះមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ និង មិនចងអង្គជំនុំជម្រះឡើយ។

១២- ទាក់ទងទៅនឹងអនុភាពនៃការអនុគ្រោះទោសរបស់ព្រះមហាក្សត្រ ជាការសំខាន់ដែលត្រូវគូសបញ្ជាក់ថាការអនុគ្រោះទោសនេះកម្រិតត្រឹមការលុបចោលនូវទណ្ឌកម្ម និង ការអនុវត្តទណ្ឌកម្មតែប៉ុណ្ណោះ ការអនុគ្រោះទោសនេះមិនប៉ះពាល់ដល់សាលក្រមផ្តន្ទាទោសដោយផ្ទាល់នោះទេ។ ជាផលវិបាក ទោះបីការអនុគ្រោះទោសនេះអាចយកមកតតាំងបាននៅអង្គជំនុំជម្រះវិសាមញ្ញក៏ដោយ ក៏ការអនុគ្រោះទោសនេះមិនមានអនុភាពលើការចោទប្រកាន់នៅទីនេះឡើយ។ បញ្ហាទាក់ទងតែសាលក្រមប៉ុណ្ណោះ ដែលបញ្ហានេះបានលើកមករួចមកហើយក្នុងចំណុចខាងលើ។

---

និង consorts ន.០៥/២០០៣ ថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៥ កថាខ័ណ្ឌ ៣៣ ។ សម្រាប់យុត្តិសាស្ត្រតុលាការជាតិ តុលាការកំពូលសហរដ្ឋអាមេរិក Blockburger V. United States, ២៨៤ U.S ២៩៩, ៣០៤ (១៩៣២) ។

[5] ជាឧទាហរណ៍ ជនជាប់ចោទ ១២ រូប ដែល Goering, Ribbentropp, Keitel, Rosenberg, Jodl et Von Neurath ត្រូវបានរកឃើញដោយត្រួតគ្នានូវពិរុទ្ធភាពចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម។ សូមមើលសាលក្រមតុលាការយោធាអន្តរជាតិ Nuremberg ដែលត្រូវបានចម្លងឡើងវិញដោយកម្មវិធី Avalon របស់សាកលវិទ្យាល័យ Yale : http\\www.yale.edu\avalon\imt\proc\judocnt.htm

១៣- អំពីការលើកលែងទោសដែលយោងយ៉ាងច្បាស់ដល់ច្បាប់ឆ្នាំ ១៩៩៤ លើកលែងតែការយោងមិនច្បាស់លាស់ដល់អំពើប្រល័យពូជសាសន៍ក្នុងបុព្វកថា ច្បាប់នេះយោងដល់តែបទល្មើសនៃនីតិរួមមួយចំនួនដែលត្រូវផ្តន្ទាទោសស្របតាមច្បាប់ជាតិជាធរមាន ក៏ដូចជាប្រភេទបទល្មើសប្រឆាំងនឹងសន្តិសុខជាតិ។ ការលើកលែងទោសនេះមិនគ្របដណ្តប់លើបទល្មើសដែលជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញឡើយ។

១៤- ជាសង្ខេប ទាំងការអនុគ្រោះ ឬ ទាំងការលើកលែងទោសមិនបង្កជាឧបសគ្គនាពេលបច្ចុប្បន្ននេះដល់ការចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញចំពោះឧក្រិដ្ឋកម្មអន្តរជាតិដែលដាក់បន្ទុកលើ **អៀង សារី**ឡើយ។ បញ្ហាតែមួយគត់ដែលចោទឡើងនៅក្នុងដំណាក់កាលនេះ គឺថាតើចាំបាច់មានការឃុំខ្លួនបណ្តោះអាសន្នជននេះដែរឬទេ។

***គ. អំពីការឃុំខ្លួនបណ្តោះអាសន្ន***

១៥- តាមរយៈឯកសារ និង ចម្លើយសាក្សីជាច្រើនដែលមាននៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរដែលដាក់បន្ទុកលើ **អៀង សារី** បង្កើតបានជាហេតុផលដែលអាចអោយជឿជាក់ថា **អៀង សារី** បានប្រព្រឹត្តនូវបទល្មើសដូចដែលបានដាក់បន្ទុកមែន។

១៦- អង្គហេតុទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ ទោះជាវាមានរយៈពេល ៣០ ឆ្នាំ ក្រោយពេលបទឧក្រិដ្ឋបានកើតឡើងក៏ដោយ ក៏នៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈដដែល។ ហេតុដូច្នេះវាមិនមែនការហួសហេតុពេកដែលអះអាងថានៅក្នុងបរិបទផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជនត្រូវចោទអាចនឹងបង្កឲ្យមានការសំដែងនូវការមិនពេញចិត្តដែលអាចបង្កឲ្យមានអំពើហឹង្សា ឬ អាចប៉ះពាល់ដល់សន្តិសុខរបស់ជនត្រូវចោទផ្ទាល់។ ម្យ៉ាងវិញទៀត ស្ថានភាពមិនអាចមើលឃើញជាក់ច្បាស់ដូចគ្នាទេរវាងពេលមុនការចោទប្រកាន់ និងក្រោយពេលចោទប្រកាន់ជាផ្លូវការនោះ។

១៧- សម្រាប់បន្តការស៊ើបសួរ ជាការចាំបាច់ណាស់ដែលត្រូវបង្ការរាល់ការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ។ ដូចនេះ មានការភ័យខ្លាចថាប្រសិនបើអនុញ្ញាតិអោយនៅក្រៅឃុំ ជនត្រូវចោទព្យាយាម និង រៀបចំធ្វើការដាក់សម្ពាធបែបនេះ។ ម្យ៉ាងវិញទៀត **អៀង សារី** នឹងមានសិទ្ធិពិនិត្យសំណុំរឿងស៊ើបសួរទាំងមូលដែលរួមមានជាពិសេសកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ក្រៅពីនេះ ប្រសិនបើប្រភេទអង្គហេតុធ្វើអោយជនសង្ស័យពិបាកក្នុងការរកអត្តសញ្ញាណ និងជះឥទ្ធិពលលើសាក្សីសំខាន់ៗនោះ ចំនុចនេះលែងចោទជាបញ្ហាដល់ជនត្រូវចោទហើយនៅពេលដែលជននេះដឹងអំពីអត្តសញ្ញាណរបស់សាក្សីដាក់បន្ទុក និង ជនរង

គ្រោះដែលពាក់ព័ន្ធដោយនីតិវិធី។ ប្រឈមមុខនឹងស្ថានភាពថ្មីនេះ មានយុត្តិកម្មបញ្ជាក់ជាពិសេសដល់ការភ័យខ្លាចក្នុងការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ ប្រសិនបើជនត្រូវចោទអាចទំនាក់ទំនងដោយគ្មានការត្រួតពិនិត្យជាមួយជនទាំងនេះ ដោយហេតុថា ជននេះមានញាតិមិត្ត និង អតីតអ្នកក្រោមបង្គាប់ច្រើននៅក្នុងតំបន់ភ្នំម៉ាឡៃ ប៉ៃលិន ឬ ភ្នំពេញ ដែលមានខ្លះបច្ចុប្បន្ននេះស្ថិតក្នុងតំណែងដែលមានឥទ្ធិពល និង មានជនប្រដាប់អាវុធនៅជុំវិញខ្លួនផង។

១៨- ម្យ៉ាងវិញទៀត មានធាតុមួយចំនួនបង្ហាញថា **អៀង សារី** (ដែលមានលំនៅដ្ឋាននៅបរទេស និងដែលធ្លាប់ធ្វើដំណើរច្រើនដងទៅក្រៅប្រទេសកម្ពុជា) មានមធ្យោបាយសម្ភារៈ ដែលអាចងាយនឹងរត់គេចខ្លួន រួមទាំការរត់ទៅកាន់ប្រទេសផ្សេងទៀត ដូចជាប្រទេសដែលមិនមានកិច្ចព្រមព្រៀងធ្វើបត្យាប័នជាមួយប្រទេសកម្ពុជា។ **អៀង សារី** ដែលត្រូវប្រឈមនឹងទោសឧក្រិដ្ឋជាប់ឃុំឃាំងមួយជីវិតបានធ្វើការប្រកាសជាសាធារណៈច្រើនដងមកហើយថា គាត់បដិសេធមិនចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញឡើយ។ ការប្រកាសទាំងនេះដាក់ច្បាស់ធ្វើអោយស្រពិចស្រពិលដល់ជំហររបស់ជននេះក្នុងការបង្ហាញខ្លួនក្នុងដំណាក់កាលជំនុំជម្រះ។ ដូចនេះមានការភ័យខ្លាចថា ជននេះអាចស្វែងរកការគេចខ្លួនពីតុលាការ។

១៩- ភាពធ្ងន់ធ្ងរជាពិសេសនៃបទល្មើសដែលចោទប្រកាន់ចំពោះ **អៀង សារី** នាំអោយឃើញហានិភ័យខាងលើកាន់តែច្បាស់ថែមទៀត និង មិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយទោះមានលក្ខណៈតឹងរ៉ឹងយ៉ាងណាដែលមានប្រសិទ្ធិភាពអាចធានាអោយមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះទេ ហើយថាការឃុំខ្លួននៅតែជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចគោលដៅខាងលើនេះ។

២០- ស្ថិតក្នុងស្ថានភាពបច្ចុប្បន្ន មិនមានសំអាងណាមួយដែលលើកឡើងដោយមេធាវីការពារក្តី ដែលអាចអោយគិតថា ស្ថានភាពសុខភាពរបស់ជនត្រូវចោទមានវិសមិតភាពនឹងការឃុំខ្លួនឡើយ។

២១- ជាផលវិបាក យល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នមានសារៈសំខាន់ដើម្បីបង្ការរាល់ការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ និង មានភាពចាំបាច់ផងដែរដើម្បីធានារក្សាទុកវត្តមានជនត្រូវចោទសម្រាប់ដំណើរការស្វែងរកយុត្តិធម៌ និង ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ និង ដើម្បីការពារសុវត្ថិភាពផ្ទាល់របស់ជននេះ។

## ហេតុដូច្នេះ សម្រេច

សម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ **អៀង** សារី ចំនួនរយៈពេលអតិបរមា ១ ឆ្នាំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**
**Co-juges d'instruction**

ដីកាសម្រេចនេះតាក់តែងឡើងជាភាសាខ្មែរ និង ភាសាបារាំង និង បកប្រែជាភាសាអង់គ្លេសជាក្រោយ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ 8
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

យើង.............................................បានប្រគល់ដីកានេះដល់ឈ្មោះខាងក្រោមនៅថ្ងៃទី........ខែ........... ឆ្នាំ...........

**ជនត្រូវចោទ មេធាវីជនត្រូវចោទ សហព្រះរាជអាជ្ញា ការិយាល័យរដ្ឋបាល អ្នកប្រគល់**

តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទ ត្រូវបានប្រាប់ថា:

- ជនត្រូវចោទអាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ននេះ ស្របតាមលក្ខណ្ឌដែលមានចែងក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។
- នៅគ្រប់ករណីទាំងអស់ ជនត្រូវចោទ មានសិទ្ធិត្រូវបាននាំខ្លួនទៅជួបសហចៅក្រមស៊ើបអង្កេត យ៉ាងហោចណាស់រៀងរាល់ ១២០ ថ្ងៃម្ដង ហើយ ត្រូវផ្ដល់ឱកាសដើម្បីពិភាក្សាអំពីប្រព្រឹត្តិកម្ម និង លក្ខខ័ណ្ឌនៃការឃុំខ្លួន ។
- នៅពេលជួបសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទ អាចធ្វើការស្នើសុំផ្សេងៗ ហើយ សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីសំណើរនេះ។
- ជនត្រូវចោទ អាចធ្វើការកត់សម្គាល់ មុនពេលដែលសហចៅក្រមស៊ើបអង្កេត សម្រេចអំពីការបន្តការឃុំខ្លួនជនត្រូវចោទនេះ។ ជនត្រូវចោទ អាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចនេះ។
- ក្នុងពេលឃុំខ្លួនបណ្ដោះអាសន្ន ជនត្រូវចោទ ឬមេធាវីរបស់គេ អាចធ្វើសំណើសុំដោះលែងទៅសហចៅក្រមស៊ើបអង្កេតបានគ្រប់ពេលវេលា ។
- បើស្ថានភាពផ្លាស់ប្ដូរក្រោយពេលដាក់ពាក្យសុំចុងក្រោយ ជនត្រូវចោទ អាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្ដងទៀត ក្នុងរយៈពេលមិនឱ្យតិចជាង ៩០ថ្ងៃ បន្ទាប់ពីសេចក្ដីសម្រេចចុងក្រោយលើពាក្យសុំដោះលែងនៅក្រៅឃុំពីពេលមុន។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Chambres Extraordinaires au sein
des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**

**លេខ/No: 002/19-09-2007 ECCC/OCIJ**

# ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន
# Provisional detention Order
# Ordonnance de placement en détention provisoire

យើង **យូ ប៊ុនឡេង** និង **Marcel Lemonde** សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៦៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើ

ឈ្មោះ **អៀង ធីរិទ្ធ** ហៅ **ភា**

កើតនៅថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៣២

ត្រូវដាក់អោយស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សមនុស្សជាតិ ដែលមានចែងនិងផ្តន្ទាទោសតាម មាត្រា៥ មាត្រា ២៩ ថ្មី និងមាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញថ្ងៃទី២៧ តុលា ២០០៤។

បានឃើញការជជែកដេញដោលដែលបានធ្វើនៅថ្ងៃនេះ

## ១- ស្ថានភាពអង្គហេតុ និង អង្គច្បាប់

១- នៅក្នុងករណីបច្ចុប្បន្ន (ដោយមិនប៉ះពាល់ដល់លទ្ធផលនៃការស៊ើបសួរដែលកំពុងដំណើរការ ដែលអាចអោយកំណត់ជាបទល្មើសផ្សេងទៀតដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរ និង ដែលអាចដាក់បន្ទុកលើជនត្រូវចោទ) ឈ្មោះ **អៀង ធីរិទ្ធ** ត្រូវបានដាក់អោយស្ថិតក្រោមការពិនិត្យអំពី ៖

- **បទល្មើសប្រឆាំងនឹងមនុស្សជាតិ** (មនុស្សឃាត ការដាក់ឃុំឃាំង ការធ្វើទុកបុកម្នេញ ការសំលាប់បំផុតពូជ និង អំពើអមនុស្សធម៌ដទៃទៀត) និង

២- ជននេះត្រូវបានដាក់បន្ទុកថាបានប្រព្រឹត្ត នៅលើទឹកដីនៃប្រទេសកម្ពុជាចន្លោះថ្ងៃទី ១៧ មេសា ១៩៧៥ និង ថ្ងៃទី ៦ ខែ មករា ១៩៧៩ ៖

- ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចដែលមានអំណាច និងការត្រួតពិនិត្យជាក់ស្តែងលើក្រសួងនេះ និងស្ថាប័នក្រោមចំណុះក្រសួង

- បានញុះញង់ បញ្ជា ខកខានមិនបានទប់ស្កាត់ និងផ្តន្ទាទោស ឬម្យ៉ាងទៀតបានសមគំនិតក្នុងការប្រព្រឹត្តបទល្មើសខាងលើ

- ដោយដឹកនាំ ជំរុញ ដាក់អោយដំណើរការ ឬ ផ្តល់ជំនួយក្រោមរូបភាពផ្សេងទៀតដល់នយោបាយ និង ការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជាដែលចារឹកលក្ខណៈជា មនុស្សឃាត ការដាក់ឃុំឃាំង ការសំលាប់បំផុតពូជ ការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ ឬ អំពើអមនុស្សធម៌ដទៃទៀតដូចជាការជម្លៀសដោយបង្ខំ ការដាក់ជាទាសករ ឬការធ្វើការដោយបង្ខំ

- នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាទូទៅ និង ជាប្រព័ន្ធ សំដៅលើជនស៊ីវិល

៣- សហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញដែលបានបង្ហាញទឡ្ហីករណ៍ខាងអង្គហេតុ និង អង្គច្បាប់របស់ខ្លួននៅក្នុងសេចក្តីសន្និដ្ឋានដែលបានដាក់នៅក្នុងសំណុំរឿងចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៧ និង ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ បានស្នើសុំការឃុំខ្លួនបណ្តោះអាសន្នចំពោះ **អៀង ធិរិទ្ធ** ដោយសំអាងថា ដោយមានលិខិតឆ្លងដែន ជននេះអាចរត់គេចខ្លួនយ៉ាងងាយស្រួល ប្រសិនបើគ្មានការដាក់ឃុំទេ និង ថាជននេះត្រូវប្រឈមមុខនឹងការជាប់ឃុំឃាំងមួយជីវិត ។ ម៉្យាងវិញទៀត ជនរងគ្រោះអាចនឹងទាមទារចង់បានការសងសឹក ដែលនាំអោយចាំបាច់ត្រូវតែមានការឃុំខ្លួនបណ្តោះអាសន្នដើម្បីបង្ការភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ និង ដើម្បីធានាសន្តិសុខដល់ជនត្រូវចោទផ្ទាល់ ។ ជាចុងក្រោយ មានហានិភ័យដែលអាចមានការដាក់សម្ពាធលើសាក្សី។

៤- **អៀង ធីរិទ្ធ** ជំទាស់នឹងអង្គហេតុដែលដាក់បន្ទុកលើខ្លួន ដោយគូសបញ្ជាក់ថា “*ការអះអាងរបស់សហព្រះរាជអាជ្ញាគឺខុស ១០០%* ”។ ជនត្រូវចោទបញ្ជាក់បន្ថែមថា ខ្លួនមិនដែលមានទំនាក់ទំនងអ្វីជាមួយឈ្មោះ **នួន ជា** ទេ ហើយ “

ខ្លួនស្អប់ជននេះណាស់ដោយខ្លួនដឹងថាទួន ជា នេះជាមនុស្សមិនល្អ"។ជនត្រូវចោទទាមទារអោយមានការបង្ហាញភស្តុតាង អំពីពិរុទ្ធភាពរបស់ខ្លួន ដោយគូសបញ្ជាក់ថា នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់គាត់នៅក្រសួងសង្គមកិច្ច និង នៅក្នុងវិស័យសុខាភិបាល គាត់បានត្រឹមតែជួយប្រជាជន និងអ្នកជម្ងឺ ដូចជាទទួលបន្ទុកស្តារឡើងវិញនូវមន្ទីរពេទ្យដែលត្រូវបានខូចខាត និង ការផលិតថ្នាំពេទ្យជាដើម។ ជនត្រូវចោទលើកឡើងថាគ្មានហានិភ័យនៃការរត់គេចខ្លួនទេ ដោយហេតុថា លិខិតឆ្លងដែនរបស់ខ្លួនត្រូវរឹបអូសយកហើយ និង មិនដែលមានប្រទេសជាសមាជិកអង្គការសហប្រជាជាតិណានឹងទទួលយកខ្លួនឡើយ។ ជនត្រូវចោទបញ្ជាក់ថា ខ្លួនមានលំនៅដ្ឋាន និង ប្រកាសត្រៀមខ្លួនរួចជាស្រេចក្នុងការបង្ហាញខ្លួនតាមការកោះហៅ។ ជនត្រូវចោទគូសបញ្ជាក់ បន្ថែមទៀតថា ខ្លួនមានអាយុ ៧៥ ឆ្នាំហើយ និង មានជំងឺរ៉ាំរ៉ៃផ្នែកផ្លូវកាយ និងផ្លូវចិត្តទៀត។ ជាផលវិបាក ជនត្រូវចោទ ស្នើសុំអនុញ្ញាត្តិអោយនៅក្រៅឃុំ ប្រសិនបើមានគឺស្ថិតនៅក្រោមការត្រួតពិនិត្យរបស់នគរបាល។

## ២- សំអាងហេតុសេចក្តីសម្រេច

៥- តាមរយៈឯកសារ និង ចម្លើយសាក្សីជាច្រើនដែលមាននៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរដែលដាក់បន្ទុកលើ **អៀង ធីរិទ្ធ** បង្កើតបានជាហេតុផលដែលអាចអោយជឿជាក់ថា **អៀង ធីរិទ្ធ** បានប្រព្រឹត្តនូវបទល្មើសដូចដែលបានដាក់បន្ទុកមែន។

៦- អង្គហេតុទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ ទោះជាវាមានរយៈពេល ៣០ ឆ្នាំ ក្រោយពេលបទឧក្រិដ្ឋបានកើតឡើងក៏ដោយ ក៏នៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈដដែល។ ហេតុដូច្នេះវាមិនមែនការហួសហេតុពេកដែលអះអាងថានៅក្នុងបរិបទផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជនត្រូវចោទអាចនឹងបង្កឲ្យមានការសំដែងនូវការមិនពេញចិត្តដែលអាចបង្កឲ្យមានអំពើហឹង្សា ឬ អាចប៉ះពាល់ដល់សន្តិសុខរបស់ជនត្រូវចោទផ្ទាល់។ ម្យ៉ាងវិញទៀត ស្ថានភាពមិនអាចមើលឃើញជាក់ច្បាស់ដូចគ្នាទេរវាងពេលមុនការចោទប្រកាន់ និងក្រោយពេលចោទប្រកាន់ជាផ្លូវការនោះ។

៧- សម្រាប់បន្តការស៊ើបសួរ ជាការចាំបាច់ណាស់ដែលត្រូវបង្ការរាល់ការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ។ ដូចនេះ មានការភ័យខ្លាចថាប្រសិនបើអនុញ្ញាត្តិអោយនៅក្រៅឃុំ ជនត្រូវចោទព្យាយាម និង រៀបចំធ្វើការដាក់សម្ពាធបែបនេះ។ ម្យ៉ាងវិញទៀត **អៀង ធីរិទ្ធ** នឹងមានសិទ្ធិពិនិត្យសំណុំរឿងស៊ើបសួរទាំងមូលដែលរួមមានជាពិសេសកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ក្រៅពីនេះ ប្រសិនបើប្រភេទអង្គហេតុធ្វើអោយជនសង្ស័យពិបាកក្នុងការរកអត្តសញ្ញាណ និងជះឥទ្ធិពលលើសាក្សីសំខាន់ៗនោះ ចំនុចនេះលែងចោទជាបញ្ហាដល់ជនត្រូវចោទហើយនៅពេលដែលជននេះដឹងអំពីអត្តសញ្ញាណរបស់សាក្សីដាក់បន្ទុក និង ជនរងគ្រោះដែលពាក់ព័ន្ធដោយនីតិវិធី។ ប្រឈមមុខនឹងស្ថានភាពថ្មីនេះ មានយុត្តិកម្មបញ្ជាក់ជាពិសេសដល់ការភ័យខ្លាច

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ក្នុងការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ ប្រសិនបើជនត្រូវចោទអាចទំនាក់ទំនងដោយគ្មានការត្រួតពិនិត្យជាមួយជនទាំងនេះ ដោយហេតុថា ជននេះមានញាតិមិត្ត និង ជនស្លាប់បង្គាប់ច្រើននៅក្នុងតំបន់ភ្នំម៉ាឡៃ ប៉ៃលិន ឬ ភ្នំពេញ ដែលមានខ្លះបច្ចុប្បន្ននេះស្ថិតក្នុងតំណែងដែលមានឥទ្ធិពល និង មានជនប្រដាប់អាវុធនៅជុំវិញខ្លួនផង។

៨- ម្យ៉ាងវិញទៀត មានធាតុមួយចំនួនបង្ហាញថា **អៀង ធីរិទ្ធ** (ដែលមានលំនៅដ្ឋាននៅបរទេស និងដែលធ្លាប់ធ្វើដំណើរច្រើនដងទៅក្រៅប្រទេសកម្ពុជា) មានមធ្យោបាយសម្ភារៈ ដែលអាចងាយនឹងរត់គេចខ្លួន រួមទាំការរត់ទៅកាន់ប្រទេសផ្សេងទៀត ដូចជាប្រទេសដែលមិនមានកិច្ចព្រមព្រៀងធ្វើបត្យាប័នជាមួយប្រទេសកម្ពុជា។ ដូចនេះអាចនាំឱ្យមានការភ័យខ្លាចថា **អៀង ធីរិទ្ធ** ដែលត្រូវប្រឈមនឹងទោសឧក្រិដ្ឋជាប់ឃុំឃាំងមួយជីវិត អាចស្វែងរកការគេចខ្លួនពីតុលាការ។

៩- ភាពធ្ងន់ធ្ងរជាពិសេសនៃបទល្មើសដែលចោទប្រកាន់នាំអោយឃើញហានិភ័យខាងលើកាន់តែច្បាស់ថែមទៀត និង មិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយទោះមានលក្ខណៈតឹងរ៉ឹងយ៉ាងណា ដែលមានប្រសិទ្ធិភាពអាចធានាអោយមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះទេ ហើយថាការឃុំខ្លួននៅតែជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចគោលដៅខាងលើនេះ។

១០- ស្ថិតក្នុងស្ថានភាពបច្ចុប្បន្ន មិនមានសំអាងណាមួយដែលលើកឡើងដោយមេធាវីការពារក្តី ដែលអាចអោយគិតថា ស្ថានភាពសុខភាពរបស់ជនត្រូវចោទមានវិសមិតភាពនឹងការឃុំខ្លួនឡើយ។

១១- ជាផលវិបាក យល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នមានសារៈសំខាន់ដើម្បីបង្ការរាល់ការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ និង មានភាពចាំបាច់ផងដែរដើម្បីធានារក្សាទុកវត្តមានជនត្រូវចោទសម្រាប់ដំណើរការស្វែងរកយុត្តិធម៌ និង ដើម្បីរក្សាសណ្តាប់ធ្នាប់សារធារណៈ និង ដើម្បីការពារការពារសុវត្ថិភាពផ្ទាល់របស់ជននេះ។

## ហេតុដូច្នេះ សម្រេច

សម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ **អៀង ធីរិទ្ធ** ចំនួនរយៈពេលអតិបរមា ១ ឆ្នាំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d’instruction**

ដីកាសម្រេចនេះតាក់តែងឡើងជាភាសាខ្មែរ និង ភាសាបារាំង និង បកប្រែជាភាសាអង់គ្លេសជាក្រោយ។

យើង.............................................បានប្រគល់ដីកានេះដល់ឈ្មោះខាងក្រោមនៅថ្ងៃទី........ខែ........... ឆ្នាំ...........

**ជនត្រូវចោទ មេធាវីជនត្រូវចោទ សហព្រះរាជអាជ្ញា ការិយាល័យរដ្ឋបាល អ្នកប្រគល់**

តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទ ត្រូវបានប្រាប់ថា:

- ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ននេះ ស្របតាមលក្ខណ្ឌដែលមានចែងក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។
- នៅគ្រប់ករណីទាំងអស់ ជនត្រូវចោទ មានសិទ្ធិត្រូវបាននាំខ្លួនទៅជួបសហចៅក្រមស៊ើបអង្កេត យ៉ាងហោចណាស់ រៀងរាល់ ១២០ ថ្ងៃម្តង ហើយ ត្រូវផ្តល់ឱកាសដើម្បីពិភាក្សាអំពីប្រព្រឹត្តិកម្ម និង លក្ខខ័ណ្ឌនៃការឃុំខ្លួន ។
- នៅពេលជួបសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទ អាចធ្វើការស្នើសុំផ្សេងៗ ហើយ សហចៅក្រមស៊ើបអង្កេត ត្រូវសម្រេចអំពីសំណើរនេះ។
- ជនត្រូវចោទ អាចធ្វើការកត់សម្គាល់ មុនពេលដែលសហចៅក្រមស៊ើបអង្កេត សម្រេចអំពីការបន្ត ការឃុំខ្លួនជនត្រូវចោទនេះ។ ជនត្រូវចោទ អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ។
- ក្នុងពេលឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ ឬមេធាវីរបស់គេ អាចធ្វើសំណើសុំដោះលែងទៅ សហចៅក្រមស៊ើបអង្កេតបានគ្រប់ពេលវេលា ។
- បើស្ថានភាពផ្លាស់ប្តូរក្រោយពេលដាក់ពាក្យសុំចុងក្រោយ ជនត្រូវចោទ អាចដាក់ពាក្យសុំនៅក្រៅឃុំ សាជាថ្មីម្តងទៀត ក្នុងរយៈពេលមិនឱ្យតិចជាង ៩០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយលើពាក្យសុំដោះលែងនៅក្រៅឃុំពីពេលមុន។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

00152910

C21

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ
លេខ:០០១/១៨-០៧-០៧-អវតក/អបជ០១

ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ORIGINAL DOCUMENT RECEIVED ON 19/11/2007 AT. 15:45' BY NUP SOTHUNVICHET ACTING CASE FILE OFFICER

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម
Certified Copy/Copie Conforme
ថ្ងៃទី(On/Le) 19 ខែ(Month/Mois) NOV.
ឆ្នាំ (Year/Année) 2007
ក្រឡាបញ្ជី/ Greffier NUP SOTHUN VICHET

## របាយការណ៍ស្តីពីការពិនិត្យ

ក) នីតិវិធី
ខ) អង្គច្បាប់
គ) អង្គហេតុ

### ក) សេចក្តីផ្តើម

#### I- នីតិវិធី

អនុលោមតាមវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") ប្រធានអង្គបុរេជំនុំជម្រះបានចេញដីកាចាត់តាំងលេខ ០៧-០៨-០០៦ អវតក/អបជ ចុះថ្ងៃទី ២៤-០៨-០៧ ចាត់តាំងលោកចៅក្រម **ហួត វុទ្ធី** និង លោកចៅក្រម **Rowan Downing** ឱ្យធ្វើរបាយការណ៍អំពីសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីដីកាឃុំខ្លួនដែលត្រូវបានប្តឹងឧទ្ធរណ៍ និងអង្គហេតុដែលពាក់ព័ន្ធនឹងសំណុំរឿង លេខ ០០១/១៤-១៨-០៧-០៧ អវតក/អបជ០១ ។

### ដែលក្នុងនោះជនត្រូវចោទ÷

**កាំង ហ្កេកអ៊ាវ** ហៅ " **ឌុច** " ភេទប្រុស កើតថ្ងៃ ១៧ វិច្ឆិកា ១៩៤២ នៅភូមិ ពៅវើយ ឃុំពាមបាវ ស្រុកស្ទោង ខេត្តកំពង់ធំ សញ្ជាតិ កម្ពុជា ទីលំនៅមុនពេលចាប់ខ្លួន នៅភូមិ អូរទន្ទឹម ឃុំ តាសាញ់ ស្រុកសំឡូត ខេត្តបាត់ដំបង មុខរបរ គ្រូបង្រៀន ឪពុកឈ្មោះ **កាំង គី** (ស្លាប់) ម្តាយឈ្មោះ **មាស គឹមសឿវ** (រស់) ។ តំណាងដោយមេធាវីការពារ លោក **ការ សាវុត្ថ** និង លោក **Francois ROUX** ។ **ឌុច** ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទល្មើសដែលមាន ចែង និង ផ្តន្ទាទោសតាមមាត្រា ៥, ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ (ច្បាប់

00152911

E21

អ.វ.ត.ក) ។ នៅថ្ងៃទី ២ ខែតុលា ឆ្នាំ ២០០៧ មានបទចោទបន្ថែមដែលទាក់ទងនឹងការរំលោភបំពានលើអនុសញ្ញាហ្សឺណែវ ១៩៤៩ ( Geneva Convention 1949 ) ដែលរំលោភបំពានលើមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ។

**គោលបំណងនៃរបាយការណ៍**

របាយការណ៍របស់សហចៅក្រមរបាយការណ៍នេះ សរសេរជាពិស្តារអំពីសេចក្តីសម្រេច ដែលត្រូវបានប្តឹងឧទ្ធរណ៍ និងអង្គហេតុដែលជាបញ្ហាចំពោះមុខតុលាការ ។ របាយការណ៍នេះ អាចជួយដល់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីឲ្យយល់អំពីបញ្ហាបំពោះមុខតុលាការ ។

II. **អង្គហេតុ**

សហព្រះរាជអាជ្ញា បានចោទប្រកាន់ **ឌុច** ក្នុងចំណោមបញ្ហាផ្សេងទៀតថាបានធ្វើការគ្រប់គ្រងមន្ទីរឃុំឃាំងសន្តិសុខ ស-២១ ចន្លោះឆ្នាំ ១៩៧៥ និង១៩៧៩ ហើយក្រោមការគ្រប់គ្រងរបស់គាត់មានអំពើរំលោភបំពានឥតគណនាត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនស៊ីវិល ក្នុងន័យទូលាយ រួមមានការសម្លាប់ ការឃុំខ្លួន ការធ្វើទារុណកម្ម ដែលកើតឡើងក្នុងបរិបទនយោបាយនៃការរំលោភបំពានជាប្រព័ន្ធ និងប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ក្នុងន័យចង្អៀត ការចោទប្រកាន់រួមមានការទុកអ្នកទោសនៅក្នុងរណ្តៅឲ្យលង់ទឹកពេលភ្លៀងមក និងធ្វើទារុណកម្មដោយវាយធ្វើបាប ព្យួរនឹងខ្សែរព្យួរ ចាក់សម្លាប់ ចោះទម្លុះ ឬដកក្រចក ហើយទុកឲ្យហូរឈាមរហូតទាល់ស្លាប់។

មានការអះអាងថា មានប្រជាជនស៊ីវិលរាប់ពាន់នាក់បានស្លាប់ក្នុងមន្ទីរឃុំឃាំង ស-២១ ចន្លោះឆ្នាំ ១៩៧៥ និង ១៩៧៩ ។

ខាងក្រោមនេះគឺជាលំដាប់លំដោយព្រឹត្តិការណ៍ ដែលទាក់ទងនឹងការឃុំខ្លួន **ឌុច** ចាប់តាំងពីឆ្នាំ១៩៩៩ ។ ហើយព្រឹត្តិការណ៍ទាំងនេះមិនស្ថិតក្នុងជម្លោះឡើយ។

- **១០ ឧសភា ១៩៩៩ - ឌុច** ត្រូវបានចាប់ខ្លួនដោយអាជ្ញាធរនៃព្រះរាជាណាចក្រកម្ពុជា និងនាំទៅកាន់តុលាការយោធាក្រុងភ្នំពេញ ។ ចៅក្រមស៊ើបអង្កេតតុលាការយោធាបានចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរដែលទាក់ទងនឹងរឿងរបស់ **ឌុច** ហើយការិយាល័យព្រះរាជអាជ្ញាបានចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ២ លេខ ០២៩/៩៩ ដែលក្នុងនោះព្រះរាជអាជ្ញាបានចោទប្រកាន់ **ឌុច** ជាមួយជនដទៃទៀតពីបទឧក្រិដ្ឋប្រឆាំងនឹងសន្តិសុខក្នុងប្រទេស ។

- **៦ កញ្ញា ១៩៩៩ -** ព្រះរាជអាជ្ញា **សាវ សុខ** ចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរ លេខ ០៤៤/៩៩ ដែលក្នុងនោះគាត់បានចោទប្រកាន់ ឌុច និង តាម៉ុក ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលរំលោភលើមាត្រា ២ នៃក្រឹត្យច្បាប់លេខ ១ ។

00152912

C21

- **២២ កុម្ភៈ ២០០២ - ២២ កុម្ភៈ ២០០៣ - ២២ កុម្ភៈ ២០០៤** " ដើម្បីធានានូវភាពល្អប្រសើរនៃការស៊ើបសង្កេត" ចៅក្រមស៊ើបអង្កេតតុលាការយោធា បានចេញដីកាឃុំខ្លួន **ឌុច** ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ យោងតាមមាត្រា ៥ និង ៣៩ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆ្នាំ ២០០១ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ។
- **២៨ កុម្ភៈ ២០០៥ - ២៨ កុម្ភៈ ២០០៦ - ២៨ កុម្ភៈ ២០០៧** "ដើម្បីអនុវត្តនូវភាពល្អប្រសើរនៃការស៊ើបសង្កេត" ចៅក្រមស៊ើបអង្កេតតុលាការយោធាបានចេញដីកាឃុំខ្លួនចំនួន៣ ចោទពីបទល្មើសឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សដែលត្រូវការពារជាអន្តរជាតិ យោងតាមមាត្រា ៦ និង ៨ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ២០០៤ ។

### III. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា

នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា នៃ អ.វ.ត.ក បានចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលក្នុងនោះស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបអង្កេតប្រឆាំងនឹងជនសង្ស័យ ៥រូប រួមមាន ទាំង **ឌុច** ផងដែរ និងស្នើសុំឲ្យធ្វើការចាប់ខ្លួន និងឃុំខ្លួនជនសង្ស័យទាំង ៥រូប នោះ ។

សហព្រះរាជអាជ្ញាបានស្នើឲ្យមានការឃុំខ្លួន **ឌុច** ជាបណ្ដោះអាសន្ន ដោយផ្អែកលើសំអាងថាមានមូលហេតុគ្រប់គ្រាន់ដោយជឿជាក់ថា **ឌុច** បានចូលរួមក្នុងបទល្មើសដូចដែលបានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ហើយការឃុំខ្លួនជាការចាំបាច់ក្នុងការការពារការគាបសង្កត់លើសាក្សី ការធានាពីវត្តមានរបស់ **ឌុច** ក្នុងពេលសវនាការ ការការពារសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ ក៏ដូចជាធានានូវសណ្ដាប់ធ្នាប់សាធារណៈ ។

### IV. ក) ដីកាឃុំខ្លួនចេញដោយសហចៅក្រមស៊ើបអង្កេត

នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេត អ.វ.ត.ក បានចេញដីកានាំខ្លួន **ឌុច** មកចំពោះមុខ ។ **ឌុច** ត្រូវបានផ្ទេរពីមន្ទីរឃុំឃាំងតុលាការយោធាមក អ.វ.ត.ក ។ នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧ បន្ទាប់ពីការធ្វើសវនាការតទល់គ្នា សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នដែលមានរយៈពេលកំណត់មិនលើសពី ១ឆ្នាំ ។

### ខ) មូលហេតុនាំឲ្យមានដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត អង្គហេតុ និងអង្គច្បាប់ដែលបានលើកឡើងដីកាសម្រេច

នៅក្នុងដំណើរការនីតិវិធីតុលាការយោធា **ឌុច** ត្រូវបានដាក់អោយស្ថិតក្រោមការឃុំខ្លួនបណ្ដោះអាសន្ន ចាប់ពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ ហើយស្ថិតក្រោមការឃុំខ្លួនចាប់ពីពេលនោះមក។ " ការបន្តការឃុំខ្លួន

00152913

៤២

បណ្តោះអាសន្នរបស់គាត់ចោទជាបញ្ហាក្នុងបទដ្ឋានយុត្តិធម៌អន្តរជាតិ និង..... និងមាត្រា ៩(៣) និង ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" ។

បញ្ហាគឺ " តើការឃុំខ្លួនបែបនេះមានលក្ខណៈហួសហេតុ និង បំពានដល់សិទ្ធិការពារខ្លួន ដែលប៉ះពាល់ដល់ការប្តឹងមកយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ នឹងមិនអនុញ្ញាតតទៅទៀតអោយមានការឃុំខ្លួនជាថ្មីចំពោះជនត្រូវចោទនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ឬរហូតដល់តម្រូវអោយសហចៅក្រមស៊ើបអង្កេតបញ្ឈប់ការប្តឹងចោទប្រឆាំងនឹងជននេះ ឬយ៉ាងណា ? ។

ជម្រើសគឺ: តើត្រូវអនុវត្តសុភាសិតបុរាណ *Male captus, bene detentus* ឬត្រូវអនុវត្តតាមទ្រឹស្តីរំលោភបំពាននីតិវិធី ឬយ៉ាងណា ? និយាយអោយងាយយល់ តើកាលៈទេសៈដែលត្រូវធ្វើការកាត់សេចក្តីលើជនជាប់ចោទ ពុំផ្តល់ផលប៉ះពាល់ដល់ការវិនិច្ឆ័យរបស់តុលាការទៅលើជនជាប់ចោទ ឬ អ្វីដែលបានកើតឡើងពីមុនមកទៅលើជនជាប់ចោទ ត្រូវបានចាត់ទុកជាការរំលោភបំពានទៅលើសិទ្ធិជនជាប់ចោទ ដែលការបន្តដំណើរការនីតិវិធីគឺជា "ការល្មើសលើគោលគំនិតនៃការផ្តល់យុត្តិធម៌របស់តុលាការ" ?

**សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត**

(១) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា *ខ្លួនមិនមានសមត្ថកិច្ចក្នុងការវាយតម្លៃអំពីភាពត្រឹមត្រូវតាមច្បាប់ នៃការឃុំខ្លួនកន្លងមកដែលធ្វើទៅលើ* ***ឌុច*** *នោះទេ* ។ ហេតុដែលថាអង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតក្នុងប្រព័ន្ធតុលាការកម្ពុជានោះ មិនអាចនាំអោយមានការលើកឡើងថា តុលាការពិសេសនេះធ្វើការត្រូវរ៉ូវគ្នាជាមួយតុលាការយោធានោះទេ ។ អង្គជំនុំជម្រះវិសាមញ្ញទើបតែបានចាប់ផ្តើមដំណើរការពីថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៧ ប៉ុណ្ណោះ ពេលដែលវិធានផ្ទៃក្នុងបានចូលជាធរមាន ។

(២) ទ្រឹស្តីនៃការរំលោភបំពានមិនអាចអនុវត្តបានទេក្នុងករណីនេះ ។ យុត្តាធិការដែលប្រើប្រាស់ទ្រឹស្តីនេះតែងតែគិតទៅដល់សមាមាត្ររវាងការរំលោភបំពានដែលត្រូវធ្វើការចោទប្រកាន់ និងដំណោះស្រាយដែលស្នើឡើង ។ *ក្នុងរឿងក្តីប្រឆាំងនឹងមនុស្សជាតិ ការបញ្ចប់នៃការចោទប្រកាន់អាចកើតឡើងបានតែក្នុងករណីប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនជាប់ចោទ* ។ សហចៅក្រមស៊ើបអង្កេតបន្ទាប់ពីបានពិចារណាទៅលើយុត្តសាស្ត្រ ដែលទាក់ទងនឹងបញ្ហានេះយល់ឃើញថា:

" នៅពេលដែលមិនទាន់មានរឿងបែបនេះទាល់តែសោះ ឬក៏រឿងដែលចោទប្រកាន់ថា **ឌុច** បានទទួលរងនូវអំពើធ្វើទារុណកម្ម ឬ ការធ្វើបាបធ្ងន់ធ្ងរមុនពេលការបញ្ជូនខ្លួនមកកាន់អង្គជំនុំជម្រះវិសាមញ្ញ បើប្រៀបធៀបជាមួយនឹងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលដាក់បន្ទុកលើជនជាប់ចោទ ការបន្តការឃុំខ្លួនក្រោមយុត្តាធិការរបស់តុលាការយោធា មិនអាចចាត់ទុកថាជាការរំលោភបំពានធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ជនជាប់ចោទឡើយ" ។

00152914

០៨១

ការផ្តួសផុសសំណាងចំពោះព្យសនកម្មដែលបង្កឡើងដោយការឃុំខ្លួនពីមុន នឹងមិនចោទជាបញ្ហាទេនៅក្នុងដំណាក់កាលស៊ើបសួរ ។

**មូលហេតុដែលនាំអោយមានការចេញដីកាឃុំខ្លួនបណ្តោះអាសន្នគឺ**

(១) កំរិតធ្ងន់ធ្ងរនៃបទចោទ បង្កបញ្ហាធ្ងន់ធ្ងរចំពោះសណ្តាប់ធ្នាប់សាធារណៈ ហើយការដោះលែង អាចបង្កឲ្យមានអំពើហឹង្សាកើតមានឡើង

(២) ព្រោះថា **ឌុច** ប្រហែលជានិងអាចត្រូវផ្តន្ទាទោសអោយជាប់ពន្ធនាគារមួយជីវិត ដែលនាំអោយមានការព្រួយបារម្ភចំពោះការស្វែងរកការគេចខ្លួន និង

(៣) ការឃុំខ្លួនជាមធ្យោបាយដើម្បីការពារសន្តិសុខផ្ទាល់ខ្លួនរបស់ **ឌុច**

**V. ក) បណ្តឹងឧទ្ធរណ៍ដោយ ឌុច ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន**

នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៧ មេធាវីរបស់ **ឌុច** បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាម្រេចឃុំខ្លួនបណ្តោះអាសន្ន និងដាក់សារណាចូលមកនៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៧ ។

**ខ) សារណារបស់ ឌុច**

មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដូចមានលើកឡើងនៅក្នុងសារណាររបស់មេធាវី:

(១) **ឌុច** គួរតែត្រូវបានគេដោះលែងអោយមានសេរីភាព ដោយឈរលើមូលដ្ឋានដែលថា ការឃុំខ្លួនបណ្តោះអាសន្នរបស់គាត់គឺជាការរំលោភបំពានទៅលើច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិស្តីពីការការពារ សិទ្ធិពលរដ្ឋ និងការពិចារណាលើភាពចាំបាច់តាមច្បាប់លើការរំលោភបំពាននេះមិនត្រូវបានគេធ្វើ ។

(២) រយៈពេលនៃការឃុំខ្លួនកន្លងមកគួរតែត្រូវបានគេយកមកពិចារណា ដើម្បីកំណត់ថា គួរតែបន្តការឃុំខ្លួន **ឌុច** មួយឆ្នាំទៀតឬក៏យ៉ាងណា ហើយលក្ខខ័ណ្ឌសំរាប់ឲ្យមានការឃុំខ្លួន **ឌុច** ក្នុងដីការឃុំចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ពុំគ្រប់គ្រាន់ ។

(៣) **ឌុច** គួរតែទទួលបាននូវសំណងជម្ងឺចិត្ត ចំពោះការខូចខាតដែលបានទទួលរង ដែលបណ្តាលមកពីការឃុំខ្លួនលើសរយៈពេលកំណត់តាមច្បាប់ ។

**ការអះអាងផ្ទាល់ខ្លួនរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍គាំទ្រមូលដ្ឋានបណ្តឹងឧទ្ធរណ៍នេះ**

**<u>១. ភាពមិនត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួន</u>**

មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិពលរដ្ឋ ( ស្រដៀងនឹង មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ) ត្រូវបានរំលោភបំពាន ។ មាត្រាទាំងនេះចែងគោលការណ៍ជាមូលដ្ឋានថា ជនជាប់ចោទមានសិទ្ធិ

00152915

C៧

ទទួលបាននូវការកាត់សេចក្តីក្នុងរយៈពេលសមស្របមួយ ឬមិនដូច្នោះទេត្រូវដោះលែងអោយមានសេរីភាព ដែលត្រូវយកមកអនុវត្ត ។

សិទ្ធិនេះត្រូវបានការពារដោយច្បាប់កម្ពុជា: រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣, ច្បាប់ UNTAC ឆ្នាំ ១៩៩២, ច្បាប់ស្តីអំពី រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៩ ។

ការឃុំខ្លួនបណ្តោះអាសន្នដែលមានរយៈពេលច្រើនជាង **៨ ឆ្នាំ** គឺខុសនិងច្បាប់កម្ពុជា ។ បទចោទថ្មីត្រូវបានគេធ្វើឡើងជាច្រើនដងប្រឆាំងនឹង **ឌុច** ដើម្បីបន្តការឃុំខ្លួនគាត់ ។

រដ្ឋធម្មនុញ្ញចែងថា ព្រះរាជាណាចក្រកម្ពុជាត្រូវគោរពសិទ្ធិពលរដ្ឋ ដូចមានចែងក្នុងលិខិតតុបករណ៍ផ្សេងៗស្តីពីសិទ្ធិពលរដ្ឋ ។

មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា "ជនជាប់ចោទមានសិទ្ធិទទួលបាននូវការកាត់សេចក្តីក្នុងរយៈពេលសមស្របមួយ ឬមិនដូច្នោះទេត្រូវដោះលែងអោយមានសេរីភាព ។ មិនមានវិធានទូទៅណាមួយដែលថា ជនគ្រប់រូបដែលរងចាំការវិនិច្ឆ័យទោសពីតុលាការ ត្រូវតែស្ថិតនៅក្រោមការឃុំខ្លួននោះទេ" ។

យោងទៅតាមយុត្តិសាស្ត្រអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិពលរដ្ឋ គឺវាចាំបាច់ណាស់ក្នុងការធានាថា អាជ្ញាធរតុលាការ ធ្វើដោយយកចិត្តទុកដាក់ក្នុងការអនុវត្តដំណើរការនីតិវិធី ដើម្បីចៀសវាងនូវភាពអយុត្តិធម៌ ដែលផ្ទុយពីមាត្រា ៥(៣) នៃអនុសញ្ញានេះ ។

**ឌុច** មិនបានទទួលនូវការវិនិច្ឆ័យទោសតាមរយៈពេលកំណត់ដែលអាចធ្វើទៅបាន ហើយការទាមទារឲ្យដោះលែង តាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋមិនត្រូវបានគេអនុវត្ត។

គាត់ត្រូវបានគេឃុំខ្លួនដោយមិនមានបញ្ជាក់នូវមូលហេតុ ។ រយៈពេលនៃការឃុំខ្លួនមិនបណ្តាលមកពី **ឌុច** ឬ មេធាវីរបស់គាត់ឡើយ ។

**២.សមត្ថកិច្ច**

សហចៅក្រមស៊ើបអង្កេត មានសមត្ថកិច្ចក្នុងការវាយតម្លៃលើភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួនកន្លងមកដែលធ្វើឡើងទៅលើ **ឌុច** ។ អង្គបុរេជំនុំជម្រះត្រូវបានគេសុំឲ្យប្រកាសថាខ្លួនមានសមត្ថកិច្ច ហើយត្រូវធ្វើការពិចារណាលើភាពចាំបាច់ស្របច្បាប់ទាំងអស់អំពីការរំលោភបំពានលើ សិទ្ធិរបស់ **ឌុច** ។

ក្នុងការបង្គាប់ឲមានការឃុំខ្លួន **ឌុច** សំរាប់ឆ្នាំទី ៩ នេះ សហចៅក្រមស៊ើបអង្កេតបានរួមចំណែកក្នុងរយៈពេលនៃការឃុំខ្លួនដែលមានលក្ខណៈហួសហេតុ ហើយបានផ្តល់សុពលភាពដល់ដំណើរការនីតិវិធីពីមុនទាក់ទងនឹងការឃុំខ្លួននេះ ។

00152916

C21

**ឌុច** ត្រូវបានឃុំខ្លួនក្នុងខណៈពេលនៃការរងចាំការបង្កើតឡើងនូវអង្គជំនុំជម្រះវិសាមញ្ញ ហើយដំណើរការនីតិវិធីរបស់តុលាការយោធា និងអង្គជំនុំជម្រះវិសាមញ្ញពាក់ព័ន្ធគ្នាយ៉ាងស្អិត ។

**មាត្រា១២** នៃកិច្ចព្រមព្រៀង និងមាត្រា ៣៣ នៃច្បាប់ អ.វ.ត.ក ចែងថា អ.វ.ត.ក នឹងអនុវត្តសមត្ថកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ។

សេចក្តីសម្រេចរបស់តុលាការអន្តរជាតិ គឺផ្តោតការពាក់ព័ន្ធលើសិទ្ធិនៃការទទួលបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬ ត្រូវដោះលែង ។ ទាំងនេះបញ្ជាក់ថា រយៈពេលគិតចាប់តាំងពីការចាប់ខ្លួន ឬ ការឃុំខ្លួនលើកដំបូង និង រយៈពេលមុនថ្ងៃកាលបរិច្ឆេទដែលតុលាការទទួលបាននូវសមត្ថកិច្ចដើម្បីពិនិត្យពីការរំលោភបំពានត្រូវយកមកធ្វើការពិចារណា។

សាលាក្តីព្រហ្មទណ្ឌអន្តរជាតិ បានអនុញ្ញាតឲ្យមានការដាក់ពាក្យសុំដោះលែងជនដែលត្រូវចោទពីបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរដូចគ្នានឹងបទល្មើសដែល **ឌុច** ត្រូវបានចោទប្រកាន់។

**<u>៣. លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន</u>**

ទោះបីជាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលទាក់ទងនឹងសមត្ថកិច្ចនោះ ត្រឹមត្រូវក៏ដោយក៏សហចៅក្រមស៊ើបអង្កេតនៅតែមានកាតព្វកិច្ចធ្វើការពិចារណាលើរយៈពេលឃុំខ្លួនពីមុនផងដែរ ក្នុងករណីសម្រេចធ្វើការឃុំខ្លួនបន្តទៀត។

លក្ខខណ្ឌក្នុងវិធាន ៦៣-៣ នៃវិធានផ្ទៃក្នុងដែលចែងពីបុរេលក្ខខណ្ឌសម្រាប់ចេញដីកាឃុំខ្លួនមិនបានបំពេញឡើយ ។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា **ឌុច** ត្រូវជាប់ឃុំបន្តទៀត (ទី១) ដើម្បីរក្សាសណ្តាប់ធ្នាប់ សាធារណៈ (ទី២) ដើម្បីធានាបានពីការចូលបង្ហាញខ្លួនរបស់ជនត្រូវចោទនៅពេលសវនាការ (ទី៣) ដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួនរបស់ជនត្រូវចោទ ។ ហេតុផលទាំងនេះមិនសមស្របហើយក៏មិនមានលក្ខណៈគ្រប់គ្រាន់ដែរ។

**<u>សណ្តាប់ធ្នាប់សាធារណៈ</u>**

យោងតាមយុត្តិសាស្ត្រ មុននឹងចេញដីកាឃុំខ្លួនត្រូវបំពេញលក្ខខណ្ឌដូចជាៈ អង្គហេតុបង្ហាញថា ការដោះលែងជនជាប់ឃុំនឹងបង្កផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ហើយការឃុំខ្លួននេះស្របច្បាប់បានតែក្នុងករណីដែលមានការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈប៉ុណ្ណោះ ។ វាមិនមិនត្រូវបានគេប្រើប្រាស់ក្នុងការរំពឹងទុកជាមុនសម្រាប់ទោសជាប់ឃុំឡើយ។ ភាពពាក់ព័ន្ធនឹងកត្តាទាំងនេះតាមកាលៈទេសៈ។

**<u>សុវត្ថិភាពផ្ទាល់ខ្លួន</u>**

សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញថា មានការគំរាមកំហែងពិតប្រាកដណាមួយឡើយ ។ លើសពីនេះ **ឌុច** អាចទទួលការការពារតាមវិធីផ្សេង ដូចជាការឃុំខ្លួននៅក្នុងផ្ទះជាដើម។

00152917

**<u>ហានិភ័យក្នុងការគេចខ្លួន</u>**

មានតែយុត្តិកម្មទេដែលសំអាងថា **ឌុច** អាចត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ យោងតាមយុត្តិសាស្ត្រអន្តរជាតិ ហានិភ័យដែលថាជនត្រូវចោទនឹងគេចខ្លួនត្រូវតែបង្ហាញឲ្យឃើញ ហើយហានិភ័យនៃការគេចខ្លួននេះមិនអាចវាយតម្លៃបានដោយងាយ ដោយគ្រាន់តែផ្អែកលើមូលដ្ឋាននៃស្ថានទម្ងន់ទោសបានឡើយ។

**ឌុច** គួរតែអនុញ្ញាតឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ បើគាត់អាចបំពេញល័ក្ខខ័ណ្ឌនៃការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយនិងវិធានការផ្សេងទៀតនៃការឃុំខ្លួនអាចត្រូវអនុវត្តដូចជាការឃុំខ្លួននៅក្នុងផ្ទះជាដើម។

**<u>៤.ការផ្តួសផុលសំណង</u>**

**អ.ប.ជ** ត្រូវបានស្នើឲ្យបញ្ជាក់ថា ក្នុងករណីមានការដោះលែងឲ្យចខ្លួន សំណងផ្នែកខាងហិរញ្ញវត្ថុគួរតែសងទៅ **ឌុច** ហើយក្នុងករណីមានផ្តន្ទាទោស រយៈពេល៨ឆ្នាំដែលគាត់ជាប់ឃុំគួរតែកាត់ដកចេញពីរយៈពេលនៃការផ្តន្ទាទោស។

**<u>VI- ក) សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា</u>**

ចំពោះបញ្ហាប្រភេទនេះ សហព្រះរាជអាជ្ញាការពារសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនៅចំពោះមុខតុលាការនេះ ។ សេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍ ត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញាកាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧។

**<u>ខ) សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា</u>**

**ការិយាល័យសហព្រះរាជអាជ្ញាលើកសំអាងហេតុថា គួរតែលើកបណ្តឹងឧទ្ធរណ៍ចោលពីព្រោះថា**

**១**-ការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតត្រឹមត្រូវ ហើយមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នអាចទទួលយកបាន និង

**២**-ការរំលោភបំពានណាមួយលើសិទ្ធិដែលត្រូវទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្រប មិនមែនបណ្តាលមកពី អ.វ.ត.ក ទេ ហើយការរំលោភបំពាននេះមិនមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់តម្រូវឲ្យ អ.វ.ត.ក ផ្តល់នូវសំណងណាមួយដល់ **ឌុច** ក្នុងដំណាក់កាលស៊ើបសួរបានដែរ។

ការិយាល័យសហព្រះរាជអាជ្ញា ក៏ស្វែងរកផងដែរនូវមូលដ្ឋានច្បាប់សម្រាប់ធ្វើការបកស្រាយអំពី រយៈពេលកំណត់ ក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុង ដែលអះអាងបញ្ជាក់ថាមេធាវីការពារមិនបានអនុវត្តតាមរយៈពេលកំណត់ដែលបានផ្តល់ឲ្យ។

00152918

0៦/

**១) មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន**

ការិយាល័យសហព្រះរាជអាជ្ញាលើកសំអាងឡើងថា មានមូលហេតុគ្រប់គ្រាន់ដោយជឿជាក់ថា **ឌុច** បានប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ព្រមទាំងមូលដ្ឋានភស្តុតាងរឹងមាំដែលនាំឱ្យយល់ឃើញថា ចាំបាច់ត្រូវមានការឃុំខ្លួនបណ្តោះអាសន្ន ។

**អ.ប.ជ** ត្រូវបានស្នើឱ្យអនុវត្តនូវបទដ្ឋានអន្តរជាតិទាក់ទងនឹងនីតិវិធី និងស្វែងរកការណែនាំជាចំបងអំពីយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិផ្សេងទៀត ជាជាងសេចក្តីសេចក្តីសម្រេចរបស់អង្គការសិទ្ធិមនុស្ស។

សូមបញ្ជាក់ថាមូលហេតុក្នុងវិធាន ៦៣-៣ មិនស្របគ្នាឡើយ។ បទដ្ឋានទាក់ទងនឹងមូលហេតុត្រូវបានចាត់ទុកជាបទដ្ឋានមួយ **"ជាការយល់ឃើញ"** ដែលមូលហេតុទាំងនេះត្រូវបានគេបង្កើតឡើងដែលមានលក្ខណៈខុសប្លែកគ្នាពីភាពជាក់ស្តែង។

***បទដ្ឋាននៃការពិនិត្យឡើងវិញ និងបន្ទុកនៃការបង្ហាញភស្តុតាង***

សហព្រះរាជអាជ្ញាលើកឡើងថា តើបទដ្ឋាននៃការពិនិត្យឡើងវិញអាចបង្ហាញថាសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្ត "កំហុសដែលអាចវិនិច្ឆ័យបាន" ក្នុងការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិរបស់ខ្លួនដែរ ឬយ៉ាងណា។ ហើយមេធាវីការពារក្តីត្រូវទទួលបន្ទុកក្នុងការបង្ហាញភស្តុតាង ដើម្បីបញ្ជាក់ថាសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសមែនដែរឬអត់។

ជាជំរើស **អ.ប.ជ** គួរយល់ឃើញថាសំអាងសម្រាប់ការឃុំខ្លួនត្រូវបានគេធ្វើឡើង ហើយគួរយល់ថាបន្ទុកដែលបង្ហាញថាពុំមានភាពចាំបាច់ទៀតទេក្នុងការឃុំបណ្តោះអាសន្ននោះ គឺជាកាតព្វកិច្ចរបស់មេធាវីការពារក្តី។

***មូលហេតុទី១***

សហព្រះរាជអាជ្ញាយោងទៅតាមភស្តុតាងបង្ហាញថា **ឌុច** ជាជនដែលមានហានិភ័យក្នុងការគេចខ្លួន ។ សហព្រះរាជអាជ្ញាលើកសំអាងឡើងថា មិនមានកំហុសដែលអាចវិនិច្ឆ័យបានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ ឬជាជំរើស មេធាវីការពារក្តីមិនបានបង្ហាញពីការធានាពីការបង្ហាញខ្លួនរបស់ជនត្រូវចោទឡើយ ប្រសិនបើជននេះត្រូវបានដោះលែងនោះ។

***មូលហេតុទី២***

សហព្រះរាជអាជ្ញាយោងទៅភស្តុតាងបង្ហាញថាសុវត្ថិភាពរបស់ **ឌុច** នឹងមានគ្រោះថ្នាក់ប្រសិនបើមានការដោះលែង និងបង្ហាញថាពេលវេលាកន្លងផុតទៅមិនបានកាត់បន្ថយនូវការគំរាមកំហែងទាំងនេះឡើយ ។ សហព្រះរាជអាជ្ញាបានលើកសំអាងឡើងថា មិនមានកំហុសដែលអាចវិនិច្ឆ័យបានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ ឬជាជំរើស មេធាវីការពារក្តីមិនបានបង្ហាញថានឹងគ្មានគ្រោះថ្នាក់ណាមួយកើតឡើងចំពោះសន្តិសុខរបស់ជនត្រូវចោទឡើយ ប្រសិនបើជននេះត្រូវបានដោះលែងនោះ។

00152919

C21

***មូលហេតុទី៣***

សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការចាប់ផ្តើមសកម្មភាពរបស់តុលាការអាចមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ នៅពេលដែលមានការបង្កើតឱ្យមានការចងចាំ និងការឈឺចាប់ឡើងវិញ និង សន្និដ្ឋានថា មិនមានកំហុស ដែលអាចវិនិច្ឆ័យបានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ ឬជាជំរើស មេធាវីការពារក្តីមិនបានបង្ហាញថានឹងគ្មានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈឡើយ ប្រសិនបើជនត្រូវចោទត្រូវបានដោះលែងនោះ។

***មូលហេតុទី៤***

សហព្រះរាជអាជ្ញាសន្និដ្ឋានថា នៅពេលសហចៅក្រមស៊ើបអង្កេតមិនបានលើកឡើងពីបញ្ហា ការគាបសង្កត់លើសាក្សីឡើយ ។ អ.ប.ជ មានសិទ្ធិប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនជំនួស ដើម្បីធ្វើសេចក្តីសន្និដ្ឋានលើចំណុចនេះ ។

សហព្រះរាជអាជ្ញាបញ្ជាក់ថា មិនមានដីកាសម្រេចឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដែលមាន លក្ខណៈរឹងមាំគ្រប់គ្រាន់ដើម្បីធានាបាននូវវត្តមានរបស់ **ឌុច** ហើយមិនធ្លាប់មានយុត្តិសាស្ត្រទាក់ទងនឹងដីកាបែបនេះនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ ពីព្រោះទស្សនៈនេះទើបតែបញ្ចូលកាលពីពេលថ្មីៗនេះប៉ុណ្ណោះ។

**__២) ការមិនបានដោះលែង ឌុច ឱ្យនៅក្រៅឃុំ គ្មានកំហុសឡើយ__**

សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដីការបស់សហចៅក្រមស៊ើបអង្កេតមិនមែនជាដីកាធ្វើឱ្យការឃុំខ្លួនរបស់តុលាការយោធាពីមុនមានសុពលភាពនោះទេ តែផ្ទុយទៅវិញ វាជាសេចក្តីសម្រេចឯករាជ្យមួយដែលធ្វើឡើងក្នុងការប្រើប្រាស់សមត្ថកិច្ចដោយឡែករបស់ខ្លួន ត្រង់ថា (ទី១) អ.វ.ត.ក ជាស្ថាប័នតុលាការឯករាជ្យដាច់ពីតុលាការយោធា និង(ទី២) អ.វ.ត.ក មិនដែលមានកិច្ចសហការជាមួយ ឬ អនុវត្តតាមកិច្ចណាមួយរបស់តុលាការយោធាឡើយ។

***__ឯករាជ្យភាពរបស់ អ.វ.ត.ក__***

អ.វ.ត.ក គឺជា "សាលាក្តីអន្តរជាតិពិសេស" មួយដែល:

១- បង្កើតឡើងដោយសន្ធិសញ្ញាអន្តរជាតិ

២- បង្កើតបានជាផ្នែកមួយនៃ "យន្តការយុត្តិធម៌អន្តរជាតិ"

៣- មានយុត្តាធិការខុសប្លែកពីតុលាការជាតិកម្ពុជា ដោយសារតុលាការនេះមានកម្រិតខាងសម្ភារៈ ពេលវេលា និងជនដែលត្រូវនាំមកជំនុំជម្រះ

៤- មិនអាចប្តឹងឧទ្ធរណ៍ទៅតុលាការដទៃទៀតក្នុងប្រទេសកម្ពុជាបានឡើយ

៥- មានរយៈពេលកំណត់

៦- មានរចនាសម្ព័ន្ធពិសេសដោយឡែកពីតុលាការជាតិ

00152920

C21

***<u>ការគ្មានកិច្ចសហការគ្នារវាង អ.វ.ត.ក និង តុលាការយោធា</u>***

សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការដែលតុលាការយោធាសំអាងលើច្បាប់ អ.វ.ត.ក ដើម្បីឃុំខ្លួន **ឌុច** វាមិនមានការពាក់ព័ន្ធគ្នាទេ ពីព្រោះគ្មានការបន្តកិច្ចគ្នាទាំងផ្នែកអង្គហេតុ ឬអង្គច្បាប់ រវាងនីតិវិធីរបស់តុលាការយោធា និង នីតិវិធីរបស់ អ.វ.ត.ក ។ ជាពិសេស អ.វ.ត.ក មិនបានស្នើឱ្យតុលាការយោធា ឃុំខ្លួន **ឌុច** ទេ។ ការិយាល័យសហព្រះរាជអាជ្ញាធ្វើការស៊ើបអង្កេតជាបឋមដោយខ្លួនឯង ហើយ **ឌុច** ត្រូវបាននាំខ្លួនតាមដីកាបង្គាប់ឱ្យនាំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ដោយមិនបានផ្ទេរមកពីតុលាការយោធាទេ ហើយសំណុំរឿងទាំងមូលរបស់តុលាការយោធាមិនបានដាក់ចូលមកសហចៅក្រមស៊ើបអង្កេតឡើយ។

សហព្រះរាជអាជ្ញាសន្និដ្ឋានថា អ.ប.ជ គួរតែពិនិត្យលើរយៈពេលដែល **ឌុច** ខិតខំស្វែងរកអស់លទ្ធភាពនូវការជួសជុលសំណងនៅតុលាការយោធា ក៏ដូចជាធ្វើការពិចារណាថាតើ អ.វ.ត.ក គួរផ្តល់ ឬ មិនគួរផ្តល់នូវការជួសជុលសំណងនេះ។

**<u>៣.មូលដ្ឋានសំណល់សម្រាប់ការជួសជុលសំណង</u>**

សហព្រះរាជអាជ្ញាសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមានភាពត្រឹមត្រូវក្នុងការកំណត់ថាការពន្យាពេលការឃុំខ្លួនមិនមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីតម្រូវឱ្យមានការជួសជុលសំណងជាបន្ទាន់ណាមួយឡើយ ហើយការជួសជុលសំណងចុងក្រោយណាមួយមិនមែនជាបញ្ហាដែលស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេតទេ។ មានការលើកឡើងថា ការដែលពឹងផ្អែកលើយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិជាសេចក្តីណែនាំសមស្របជាងយុត្តិសាស្ត្រខាងសិទ្ធិមនុស្សនោះ គឺពេលដែលមានភស្តុតាងថាមានការធ្វើទារុណកម្ម ឬការធ្វើបាបធ្ងន់ធ្ងរទើបតុលាការកាត់ទោសបទឧក្រិដ្ឋអន្តរជាតិផ្តល់នូវសំណង។

VII- **សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី** (ជាភាគីដែលមិនមានការពាក់ព័ន្ធក្នុងរឿងក្តី ប៉ុន្តែជាអ្នកដែលបានដាក់សារណាដើម្បីជាជំនួយដល់តុលាការ)

នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៧ តុលាការនេះបានអញ្ជើញអង្គការ និងសាធារណជនឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរ ដែលពាក់ព័ន្ធនឹងបញ្ហាណាមួយក្នុងករណីខាងលើដោយកំណត់ពេលត្រឹមថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៧ ។ តុលាការសូមថ្លែងអំណរអរគុណដល់អ្នកដែលបានដាក់សារណាចូលមកតុលាការ ដូចជា:

១- Stan Starygin

២- Jeffrey M. Kahan នៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

៣- គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា

៤- សាស្ត្រាចារ្យ David Scheffer

៥- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម និង គំនិតផ្តួចផ្តើមសម្រាប់យុត្តិធម៌នៅក្នុងអាស៊ី

00152921

C21

៦- Anne Heindel

សារណាទាំងនេះនិយាយពីបញ្ហាគតិយុត្តសំខាន់ៗ ហើយវាមិនមានផ្សេងពីនេះដែលយោងក្នុងរបាយការណ៍នេះឡើយ។ ចៅក្រមរបាយការណ៍បញ្ជាក់ថា សារណាទាំងនេះ រួមជាមួយសេចក្តីសន្និដ្ឋានតបរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ និង សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានឹងត្រូវតុលាការយកមកពិចារណា។

<u>**អនុសាសន៍បន្ថែម**</u>

សារណាសាធារណៈទាំងអស់របស់ភាគី រួមទាំងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ត្រូវបានផ្សាយតាមគេហទំព័ររបស់ អ.វ.ត.ក

**ខ) អង្គច្បាប់ដែលពាក់ព័ន្ធ**

**ឌុច** ប្រសិនត្រូវបានគេរកឃើញពិរុទ្ធភាពនៃបទល្មើសដែលបានចោទប្រកាន់ ត្រូវផ្តន្ទាទោសតាម មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "នឹងត្រូវផ្តន្ទាទោសឧក្រិដ្ឋដាក់ពន្ធនាគារ ពី ៥ ឆ្នាំ រហូត ដល់មួយជីវិត ។

ការឃុំខ្លួនបណ្តោះអាសន្នក្នុងសំណុំរឿងនេះ ត្រូវអនុវត្តក្រោមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មាត្រា ៦៣។ កថាខ័ណ្ឌ (៣) នៃវិធានខាងលើចែងអំពីមូលដ្ឋានដែលសហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និង កថាខ័ណ្ឌ (៤) ចែងអំពីសិទ្ធិរបស់ជនត្រូវចោទក្នុងការដាក់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ។

<u>**មាត្រា ៦៣ នៃវិធានផ្ទៃក្នុង**</u>

៣. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ ដោយគោរពតាមលក្ខខ័ណ្ឌ ដូចខាងក្រោម៖

ក) មានមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់ច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្ត បទល្មើសមួយ ឬ ច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការណ៍ចាំបាច់ដើម្បី៖

(១) រារាំងកុំឲ្យជននោះគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឲ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

(២) ថែរក្សាភស្តុតាង និងការពារមិនឲ្យបំផ្លាញភស្តុតាង ។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅពេលដំណើរការនីតិវិធី ។

(៤) ការការពារសុវត្ថិភាពជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។

00152922

០៥១

៤. ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទៅអង្គបុរេជំនុំជម្រះ ។

**ក) អង្គហេតុ**

មានមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់ច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្ត បទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម (វិធានផ្ទៃក្នុង វិធាន ៦៣(៣) ក)។

សហព្រះរាជអាជ្ញា បានចោទប្រកាន់ថា **ឌុច** បានសារភាពថាគាត់ជាអនុប្រធាន និងបន្ទាប់មកជាប្រធានមន្ទីឃុំឃាំង ស-២១ ពីឆ្នាំ១៩៧៥ មក ហើយរឿងនេះមិនត្រូវបានតវ៉ាដោយមេធាវីការពារក្តីនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគេឡើយ ។ នេះក៏ជាជំហររបស់គាត់ផងដែរ ពេលដែលសម្ភាសន៏ជាមួយអ្នកកាសែត បើយោងតាម ឯកសារដែលដាក់មកដោយសហព្រះរាជអាជ្ញា ។

**ឌុច** បានអះអាងថា អំណាចរបស់គាត់នៅ ស-២១ ជាអំណាចខាងទ្រឹស្តី ហើយគាត់ធ្វើតាមថ្នាក់លើរបស់គាត់ប៉ុណ្ណោះ ។ តាមកាបង្ហាញ ក្នុងអត្ថបទពីរតាមរយៈបទសម្ភាសន៏ឆ្នាំ១៩៩៩ ដែលមានចំណងជើង **"បរិវត្តអ្នកធ្វើទារុណកម្ម ខ្មែរក្រហម មានអារម្មណ៍ថា ជីវិតរបស់គាត់ដូច St Paul"** និង **"ម្តាយ ឌុចៈ គ្រួសារភ័យខ្លាចអំពីសមាសភាពជាប្រធានគុក ទួលស្លែង (ស-២១)"** ។

តាមរយៈដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន **ឌុច** ត្រូវបានសួរសម្តើយជាច្រើនដងដោយសហចៅក្រមស៊ើបអង្កេត និងបានប្តេជ្ញាថានិងបង្ហាញភស្តុតាងតាមការត្រូវការរបស់តុលាការ ប៉ុន្តែមិនអាចបង្ហាញទេក្នុងដំណាក់កាលជាសាធារណៈ ខណៈដែលសំណុំរឿងនៅជាការសម្ងាត់នៅឡើយ ។

***វិធានការណ៍ចាំបាច់ដើម្បីធានានូវការបង្ហាញខ្លួនរបស់ជនត្រូវចោទពេលសវនាការ (វិធានផ្ទៃក្នុង វិធាន ៦៣(៣) ខ(៣) )***

**ឌុច** រស់នៅដោយមានសេរីភាពពីឆ្នាំ១៩៧៩ ដល់ ១៩៩៩ មុនពេលត្រូវបានចាប់ខ្លួន និងឃុំខ្លួនដោយតុលាការយោធា ។

**ឌុច** បានប្រើឈ្មោះជាច្រើន ( ឧ. យឹម គាវ, ហ្គេច អ៊ាវ, ឌុច និង ហង្ស ពិន និង កាំង ជាវ ។ ទាំងនេះត្រូវបានជំទាស់ ដែលថាវាជាការអនុវត្តទូទៅប៉ុណ្ណោះក្នុងការប្តូរឈ្មោះក្នុងកំឡុងពេលបដិវត្ត ។

ក្នុងអត្ថបទដែលមានចំណងជើង **"បរិវត្តអ្នកធ្វើទារុណកម្ម ខ្មែរក្រហម មានអារម្មណ៍ថាជីវិតរបស់គាត់ដូច St Paul"** អ្នកការសែតឈ្មោះ សិត មីដាន ( Seth Mydans ) និយាយថា **ឌុច** បានប្រាប់ថា គាត់បានចាកចេញពីចលនារបស់គាត់នៅឆ្នាំ ១៩៨២ ហើយធ្វើជាគ្រូបង្រៀន បន្ទាប់មកប្រើឈ្មោះផ្សេងមួយទៀត ហើយធ្វើការជាមួយអង្គការសហប្រជាជាតិ និងអង្គការជួយសង្គ្រោះឯកជន ( private relief organization ) ។

00152923

ក្នុងអត្ថបទ "The lost Executioner" កំរងរឿងអំពី ខ្មែរក្រហម" អ្នកកាសែតឈ្មោះ និក ដុនលប Nic Dunlop រាយការណ៍ថា បន្ទាប់ពី **ឌុច** ត្រូវបានស្គាល់ដោយមន្ត្រីរដ្ឋ ដែលសុំមិនបញ្ចេញឈ្មោះ គាត់បានបញ្ជាក់ប្រាប់មន្ត្រីនោះថា គាត់ស្គាល់ប្រជាជននៅសំឡូតច្រើន ដែលអាចផ្តល់ការការពារដល់គាត់បាន ( រឿងក្នុងពេលនោះមិនបានបង្ហាញក្នុងសម្រង់ឯកសាររបស់សហព្រះរាជអាជ្ញាឡើយ ) **ឌុច** បន្ទាប់មកត្រូវទទួលបានការងារជានាយកសាលា ។

អ្នកកាសែតឈ្មោះ និក ដុនលប Nic Dunlop រាយការណ៍ថា គាត់បានឃើញជីវប្រវត្តិ និង ប្រវត្តិរូបសង្ខេបរបស់ **ឌុច** ដែលបានប្រគល់ឲ្យនិយោជកនៅមន្ទីរអប់រំនៅ ស៊ីសុផុន ។

**ឌុច** រស់នៅសំឡូតពេលដែល និក ដុនលប រកឃើញគាត់នៅឆ្នាំ ១៩៩៩ ។

យោងតាមលោក និក ដុនលប នៅពេលដែលរឿងដែលការរកឃើញ **ឌុច** និង ការសារភាពរបស់គាត់ត្រូវបានដឹងជាសាធារណៈ **ឌុច** ក៏បានបាត់ខ្លួន។

ក្នុងអត្ថបទ **"ម្តាយ ឌុចៈ គ្រួសារភ័យខ្លាចអំពីសមាសភាពជាប្រធានគុកទួលស្លែង (ស-២១)"** អ្នកសារព័ត៌មាន John Ciorciari និង Kok-Thay Eng រាយការណ៍អំពីបទសម្ភាសន៍ជាមួយម្តាយ **ឌុច** ខណៈដែលគាត់និយាយថា **ឌុច** បាត់ខ្លួននៅឆ្នាំ ១៩៧៩ ហើយគ្រួសារមិនបានទទួលដំណឹងពី **ឌុច** ឡើយរយៈពេលជាងពីរទស្សវត្ស ដូច្នេះគេគិតថា **ឌុច** បានស្លាប់បាត់ទៅហើយ ។ អ្នកសារព័ត៌មាន ក៏បានរាយការណ៍ថា ម្តាយ **ឌុច** បាននិយាយថា **ឌុច** បានមកលេងគាត់ខ្លះដែរ និងបន្តមកលេងជាញឹកញាប់នៅចន្លោះឆ្នាំ ១៩៨៦ និង ១៩៩៩ ។ បើតាមសំដីអ្នក សារព័ត៌មាន **ឌុច** រស់នៅក្នុងជីវិតស្ងប់ស្ងាត់ក្នុងតំបន់ដែលកាន់កាប់ដោយខ្មែរក្រហម នៅភាគខាងជើងឈាង ខាង លិចប្រទេសកម្ពុជា រហូតដល់ឆ្នាំ ១៩៩៥ ។ ពេលដែល **ឌុច** ចូលជាគ្រីស្តបរិស័ទក្នុងឆ្នាំ ១៩៩៥ គាត់បាន ប្រើឈ្មោះហៅក្រៅថា **តា ពិន** និងធ្វើការជាជំនួយការផ្នែកសុខភាពនៅជំរុំជនភៀសខ្លួន ។

ក្នុងអត្ថបទដែលមានចំណងជើងថា "Death in Detail" ដែលអ្នកសារព័ត៌មាន ណេត ថាយើ Nate Thayer បានធ្វើកិច្ចសម្ភាសន៍ ៤០ ម៉ោង ជាមួយ **ឌុច** មុនពេលដែលគាត់ត្រូវបាននាំខ្លួនមកមន្ទីឃុំឃាំង ដកស្រង់សំដីគាត់ "ខ្ញុំទាយទុកថា ខ្ញុំនិងត្រូវចូលពន្ធនាគារឥឡូវនេះ ប៉ុន្តែវាមិនអីទេ" ការសម្លាប់ត្រូវតែមានគេដឹង ការពិតគួរតែត្រូវ គេដឹង" ។ និក ដុនលប សរសេរក្នុងអត្ថបទគាត់ថា **ឌុច** បានប្រគល់ខ្លួនទៅឲ្យអាជ្ញាធរ បន្ទាប់មកគាត់ត្រូវ បានដឹកដោយឧទ្ធម្ភាគចក្រមកភ្នំពេញមកដាក់នៅមន្ទីឃុំឃាំងដែលមានការការពារខ្ពស់ ហើយត្រូវបានចោទប្រកាន់ជាផ្លូវការ ។

00152924

C21

មេធាវីការពារក្ដីបានធានាថា **ឌុច** និងបង្ហាញខ្លួននៅពេលសវនាការ ប៉ុន្តែមិនបានដាក់ភស្តុតាងបញ្ជាក់ឡើយទាក់ទងនឹងបញ្ហានេះ។

***វិធានការណ៍ចាំបាច់ដើម្បីការការពារសន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទ (វិធានផ្ទៃក្នុងវិធាន ៦៣(៣) ខ ៤ )***

បន្ទាប់ពីមានកិច្ចសម្ភាសន៍ជាមួយ និក ឌុនលប អំពីរបបខ្មែរក្រហម និង **ឌុច** ត្រូវបានស្គាល់ថាជាអ្នកដឹកនាំមួយរូប ឌុច សួរ ឌុនលបថា "តើអ្នករាល់គ្នា បានដឹងថាគាត់នៅឯណា និង ដឹងពីអត្តសញ្ញាណរបស់គាត់ឬអត់ ?" គាត់បានបន្ថែមទៀតថា "ពួកគេនិងមានកំហឹង ប្រសិនបើបានដឹង" ច្បាស់ណាស់ក្នុងរឿងដែលទាក់ទងនឹង ខ្មែរក្រហម ទោះជាអ្នកដែលបានចូលសារភាពរស់នៅជាមួយរដ្ឋាភិបាលក៏ដោយ" ។ ឌុនលប រាយការណ៍ថាគាត់មិនបានដឹងថានេះជាការប្រុងប្រយ័ត្ន ឬ ការគំរាមកំហែងឡើយ ។ គាត់បានបន្ថែមថា បើតាមគាត់ដឹងកងការពាររបស់ **ឌុច** នៅតែស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ក្នុងតំបន់នោះ ហើយ **ឌុច** នៅតែអាចបញ្ជាអ្នកទាំងនោះឲ្យជួយលាក់ខ្លួនគាត់ ពេលដែលគាត់ទទួលការគំរាមកំហែង។

**ឌុច** បានផ្ដល់បទសម្ភាសន៍ជាមួយនឹងតំណាងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស UNHCR និងអ្នកសារព័ត៌មានផ្សេងៗទៀត ដែលគាត់បានអះអាងបញ្ជាក់អំពីតំណែងជាប្រធាន ស-២១ ពីមុនរបស់គាត់ និងអះអាងបង្ហាញពីសមាជិកផ្សេងទៀតនៃរបបខ្មែរក្រហម ។ ក្នុងអត្ថបទបីរបស់សារព័ត៌មានបង្ហាញថា មុនពេលដែលគាត់ត្រូវបានចាប់ខ្លួននៅ ខែ ឧសភា ឆ្នាំ១៩៩៩ **ឌុច** បានបង្ហាញពីការភ័យខ្លាចដល់អាយុជីវិតរបស់គាត់ដល់អ្នកសារព័ត៌មាន ។ អង្គការសហប្រជាជាតិ និង អង្គការលើកលែងទោសអន្តរជាតិ ក៏បានបង្ហាញអំពីការព្រួយបារម្ភផងដែរ នាពេលនោះ អំពីសុវត្ថិភាពរបស់ **ឌុច**ព្រោះតាមរយៈបទសម្ភាសន៍ **ឌុច** បានបង្ហាញនូវឧក្រិដ្ឋកម្មជាច្រើន ដែលបានប្រព្រឹត្តដោយមេដឹកនាំខ្មែរក្រហម ។

សហព្រះរាជអាជ្ញា ក៏បានលើកផងដែរថា ពេលនេះអត្តសញ្ញាណរបស់ **ឌុច** ត្រូវបានគេដឹងជាទូទៅ ហើយរូបថត គាត់ត្រូវបានបង្ហាញនៅគ្រប់ទំព័រកាសែត និង ស្ថានីយទូរទស្សន៍ក្នុងប្រទេសកម្ពុជា ។

មេធាវីការពារក្ដី បានលើកឡើងថា រយៈពេលដែល **ឌុច** រស់នៅដោយមានសេរីភាពនោះ ពុំមានការប៉ុនប៉ង ណាមួយត្រូវបានធ្វើមកលើសុវត្ថិភាពគាត់ឡើយ ។

***វិធានការណ៍ចាំបាច់ដើម្បីរក្សាបាននូវសណ្ដាប់ធ្នាប់សាធារណៈ (វិធានផ្ទៃក្នុងវិធាន ៦៣(៣) ខ ៥ )***

ដើម្បីគាំទ្រការអះអាងដែលថា ការអនុវត្តនីតិវិធីរបស់ អ.វ.ត.ក អាចនិងបង្កគ្រោះថ្នាក់ដល់សង្គមកម្ពុជា សហព្រះរាជអាជ្ញាបានធ្វើសេចក្ដីសន្និដ្ឋានវាយតម្លៃអំពីការភ័យខ្លាចរបស់សាក្សី ដែលនឹងត្រូវផ្ដល់សាក្សីកម្ម ចំពោះមុខ អ.វ.ត.ក ដែលមិនអាចត្រូវបានបង្ហាញជាសាធារណៈ ។

មេធាវីការពារក្ដី បានលើកឡើងថា រយៈពេលដែល **ឌុច** រស់នៅដោយមានសេរីភាពនៅចន្លោះ ឆ្នាំ១៩៧៩ ដល់ ១៩៩៩ ពុំមានការធ្វើឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈឡើយ ។( កថាខណ្ឌ ១០៥ បណ្ដឹងឧទ្ធរណ៍) ។

00152925

C21

***វិធានការណ៍ចាំបាច់ដើម្បីការពារជនត្រូវចោទក្នុងការដាក់ការគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ ការពារការឃុបឃិតគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត នៃបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក (វិធានផ្ទៃក្នុងវិធាន ៦៣(៣) ខ ១ )***

**ឌុច** បញ្ជាក់ថាអះអាងថា គាត់ពុំស្គាល់ឈ្មោះសាក្សីទេ ហើយទោះបី ប្រសិនបើជាគាត់បានដឹងក៏ដោយ ក៏គាត់គ្មានហេតុផលណាមួយទៅរំខានដល់សាក្សីឡើយ ។

សហព្រះរាជអាជ្ញា ដើម្បីគាំទ្រការចោទប្រកាន់របស់គាត់ ធ្វើការយោងសំអាងលើអត្ថបទដែលមានចំណងជើងថា **"ជនរងគ្រោះ និង ជនល្មើស-សាក្ខីកម្មរបស់យុទ្ធមិត្តខ្មែរក្រហម"** "Victims and Perpetrators-Testimony of Young Khmer Rouge Comrades" ដែលថាឆ្មាំគុកដែលបានធ្វើការឱ្យ **ឌុច** នៅមន្ទីរឃុំឃាំង ស-២១ បានបង្ហាញអំពី "អារម្មណ៍ភ័យខ្លាចដែលមាននៅគ្រប់កន្លែង" ដែលខ្លួនបានជួបនៅពេលដែលពួកគេ ធ្វើការនៅ ស-២១ ។

របាយការណ៍សាធារណៈដែលមានចំណងជើងថា "ការប្រមូលអាវុធ ២០០៥-២០០៧ បង្ហាញថាអាវុធចំនួន ១៦ ៩៤០ ត្រូវបានប្រមូលពីក្នុងស្រុកចំនួនពីរ ពីខែ កញ្ញា ឆ្នាំ២០០៥ ដល់ ថ្ងៃទី **៣១ ខែសីហា ឆ្នាំ២០០៧** ( ធ្វើឡើងបន្ទាប់ពីមានដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ) និងរបាយការណ៍ផ្សេងទៀត ដែលមានចំណងជើងថា **"តើមានអាវុធចំនួនប៉ុន្មាននៅកម្ពុជា ?"** តាមស្មាន បើប្រហែលជាមានអាវុធចំនួន ២២ ០០០ ទៅ ៨៥ ០០០ កំពុងចរាចរខុសច្បាប់នៅកម្ពុជាក្នុងឆ្នាំ ២០០៥ ។

ភ្នំពេញ ថ្ងៃទី១៩ វិច្ឆិកា ឆ្នាំ ២០០៧

**ចៅក្រម** Rowan Downing **ចៅក្រម ហួត វុទ្ធី**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**Extraordinary Chamber in the Court of Cambodia**
**Chambres Extraordinaires au sein des Tribunaux Cambodgiens**

# លិខិតជូនព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត

*កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានដាក់លោក ខៀវ សំផន ឲ្យនៅក្រោមការពិនិត្យពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាម ។ បន្ទាប់ពីបញ្ចប់កិច្ចពិភាក្សាដេញដោលដែលបានធ្វើឡើងនៅថ្ងៃតែមួយនោះ សហចៅក្រមស៊ើបអង្កេតបានធ្វើការសម្រេចឃុំខ្លួនគាត់ជាបណ្តោះអាសន្ន ។ ដីការសម្រេចឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវដាក់និងអាចពិគ្រោះបាននៅក្នុងគេហទំព័រនៃអង្គជំនុំជម្រះក្នុងពេលឆាប់ៗនេះ ។*

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**Extraordinary Chamber in the Court of Cambodia**
**Chambres Extraordinaires au sein des Tribunaux Cambodgiens**

# សេចក្តីប្រកាសព័ត៌មាន

*លោក ខៀវ សំផន ត្រូវបាននាំខ្លួនមកមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ។ អង្គភាពគាំពារការការពារក្តីបានចាត់តាំងមេធាវីពីររូប ដែលជ្រើសរើសដោយលោក ខៀវ សំផន ចេញពីបញ្ជីមេធាវីរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ មេធាវីទាំងពីររូបនេះ មានលោកបណ្ឌិត សាយ បូរី សមាជិកគណៈមេធាវីកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា និង លោក* Jackques VERGÈS *មកពីគណៈមេធាវីទីក្រុងប៉ារីស ។*

*លោកបណ្ឌិត សាយ បូរី ជាសមាជិកជាន់ខ្ពស់*

*លោក* Jacques VERGÈS *ជាសមាជិកនៃគណៈមេធាវីទីក្រុងប៉ារីស ចាប់តាំងពីឆ្នាំ១៩៥៥ ។ នៅទសវត្សរ៍ឆ្នាំ១៩៦០ គាត់បានការពាររឿងក្តីជាច្រើននៅតុលាការយោធាបារាំង ដែលកើតឡើងដោយសារជម្លោះនៅអាល់ហ្សេរី ។ នៅឆ្នាំ១៩៨៧ គាត់ការពាររឿងក្តី* Klaus Barbie *នៅតុលាការព្រហ្មទណ្ឌលីយ៉ុង* [Lyon cour d'assises] *ដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រព្រឹត្តកាលពីអំឡុងសង្គ្រាមលោកលើកទី២ ។ លោក* VERGÈS *បានការពារកូនក្តីសំខាន់ៗជាច្រើននៅតុលាការជាតិ និងតុលាការអន្តរជាតិ ។*

*សហមេធាវីទាំងពីរត្រូវចាត់តាំងជាបណ្តោះអាសន្ន ស្របពេលដែលអង្គភាពគាំពារការការពារក្តី វាយតម្លៃថាតើលោក ខៀវ សំផន មានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីបង់ថ្លៃសេវាក្រុមការពារក្តីរបស់គាត់សម្រាប់រយៈពេលពីរឆ្នាំខាងមុខ ។*

# ការកែប្រែរចនាសម្ព័ន្ធតុលាការក្នុងកាត់ៈ កំណែទម្រង់គតិយុត្តិផ្នែកព្រហ្មទណ្ឌជាតិ និងការផ្តល់អំណាចក្នុងតំបន់

***(តពីលេខមុន)***

*អ្នកទិតៀនជាច្រើនរបស់អង្គជំនុំជម្រះវិសាមញ្ញនេះបាននិយាយសំដៅទៅលើការភ័យខ្លាចថា អាចមានការការពារមិនបានហ្មត់ចត់សម្រាប់ខ្មែរក្រហមដូចជាកង្វះខាតចៅក្រមដែលមានសមត្ថភាព និងហេដ្ឋារចនាសម្ព័ន្ធយុត្តាធិការដែលមានស្រាប់ ដែលនេះជាលទ្ធភាពមួយដែលអាចឲ្យចៅក្រមកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលនិងការភ័យខ្លាចថា ចុងចោទមួយចំនួនដែលមានខ្សែរយៈធំនឹងអាចរួចផុតពីសំណាញ់នៃការកាត់ទោស ។ អ្នកឃ្លាំមើលដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញមួយចំនួនកំពុងតែខ្វល់ខ្វាយថា រដ្ឋាភិបាលកំពុងទទួលរងសម្ពាធពីប្រទេសចិនឲ្យប្រើឥទ្ធិពលរបស់ខ្លួនទៅលើបុគ្គលិករបស់តុលាការ ការផ្តល់ឥទ្ធិពលសេដ្ឋកិច្ចយ៉ាងសម្បើមរបស់ប្រទេសចិនមកលើប្រទេសកម្ពុជា និងបំណងរបស់ប្រទេសចិនក្នុងការបំបាត់ភ័ស្តុតាងនៃការចូលរួមយ៉ាងសកម្មខ្លួនក្នុងការគាំទ្ររបបខ្មែរក្រហមនៅមុនឆ្នាំ១៩៧៥ នៅក្នុងអំឡុងពេលស្ថិតនៅក្រោមការគ្រប់គ្រងដ៏គួរឲ្យភ័យខ្លាចរបស់ ប៉ុល ពត និងក្រោយខែមករា ឆ្នាំ១៩៧៩ ។ លោក អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិបានថ្លែងថា នៅតែមានមន្ទិលសង្ស័យ...ទៅលើភាពគួរឲ្យជឿទុកចិត្តរបស់អង្គជំនុំជម្រះវិសាមញ្ញ បើពិនិត្យមើលទៅលើស្ថានភាពប្រែប្រួលនៃប្រព័ន្ធយុត្តាធិការនៅកម្ពុជា ។ គាត់បានលើកឡើងពីទស្សនៈរបស់ក្រុមមន្ត្រីជំនាញនិងអ្នកផ្សេងទៀតដែលបង្ហាញការព្រួយបារម្ភទៅលើកង្វះប្រព័ន្ធយុត្តាធិការដែលមិនប្រែប្រួល និងប្រព័ន្ធតុលាការដែលមានស្រាប់ ហើយដែលបានអំពាវនាវឲ្យមានវត្តមានតុលាការបណ្តោះអាសន្នមួយសុទ្ធសាធ ដូចជាតុលាការឧក្រិដ្ឋកម្មសង្គ្រាមនៅប្រទេសយូហ្គោស្លាវីដែរ ។ អ្នករិះគន់ដទៃទៀតផ្តោតទៅលើកង្វះវប្បធម៌គោរពចំពោះប្រព័ន្ធយុត្តាធិការនិងនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា ឬទៅលើការព្រួយបារម្ភដែលថាច្បាប់របស់កម្ពុជាមានលក្ខណៈច្របូកច្របល់មិនស៊ីសង្វាក់គ្នាបញ្ហាសទិសគ្នា និងពោរពេញទៅដោយការចែងមិនច្បាស់លាស់លើបញ្ហាសំខាន់ៗ ។*

*ការថ្កោលទោសស៊ីជម្រៅជាងនេះបានធ្វើការកត់សម្គាល់ថាតុលាការនេះនឹងមិនមានយុត្តាធិការទៅលើលោក ឃីសស៊ីងហ្គ័រ លោក និចសុន និងអ្នកដទៃទៀតដែលទទួលខុសត្រូវចំពោះការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា និងការបាត់បង់ជីវិតរបស់ប្រជាជនកម្ពុជាចំនួនប្រមាណ៧សែននាក់ក្នុងការទម្លាក់គ្រាប់បែកនេះ និងការវាយប្រយុទ្ធដែលបានកើតឡើងមុនការឡើងកាន់អំណាចរបស់របបខ្មែរក្រហមនៅឆ្នាំ១៩៧៥ ។ អ្នកបន្ទុះបន្ទាប់ដទៃទៀតមានអារម្មណ៍ថា បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តក្រោយការដួលរលំទៅនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ក៏គួរតែត្រូវបានយកមកកាត់ទោសផងដែរ ។*

*អ្នកប្រឆាំងដទៃទៀតចំពោះតុលាកានេះបានតវ៉ាថា ការកាត់ទោសខ្មែរក្រហមនឹងនាំឲ្យមានអស្ថិរភាពជាតិ ដោយបង្កើតភាពវឹកវរប្រកបដោយសក្តានុពលផ្នែកនយោបាយនិងយោធាទន្ទឹមពេលជាមួយគ្នាដែរ តុលាការនេះនឹងធ្វើឲ្យមានផលប៉ះពាល់ផ្លូវចិត្តនិងផ្លូវកាយដល់សហគមន៍នានាដែលងាយបែកបាក់ដែលបានព្យាយាមស្វែងរកសុខសន្តិភាពរវាងអតីតជនរងគ្រោះនិងអតីតជនដៃដល់ដែលរួមរស់នៅជាមួយគ្នា ។ ប្រជាជនកម្ពុជាជាច្រើនភ័យខ្លាចការដឹកឆ្កៀលស្នាមដំបៅចាស់របស់ខ្លួន ដោយបានដឹងថាមានតែជនដៃដល់កំពូលមួយភាគតូចប៉ុណ្ណោះដែលនឹងត្រូវនាំទៅកាត់ទោស និងថាឃាតករខ្មែរក្រហមភាគច្រើនគ្មានថ្ងៃនឹងប្រឈមមុខទៅនឹងយន្តការទាមទារឲ្យមានការទទួលខុសត្រូវណាមួយនោះទេ ។*

*អ្នកខ្លះនៅតែមិនទាន់យល់ច្បាស់និងសង្ស័យទៅលើការសន្យាក្នុងការធ្វើឲ្យមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវនៅពេលដែលឃើញថា មានមេដឹកនាំខ្មែរក្រហមភាគច្រើនជាអ្នកមានទ្រព្យសម្បត្តិគួរសម មានកម្មសិទ្ធិដីធ្លីធំល្វឹងល្វើយនៅប៉ៃលិនពាយព្យនៃ*

ប្រទេសត្រួតត្រាការរត់ពន្ធត្បូងថ្មមានតម្លៃ និងទទួលបានផលប្រយោជន៍ពីសម្បទានរបស់រដ្ឋាភិបាល នៅក្នុងដំណើរការស្វែងរកសន្តិភាព ។ អ្នកបន្ទុះបង្អាប់ទាំងនេះសំដៅទៅភាពស្ទាក់ស្ទើររបស់រដ្ឋាភិបាលបច្ចុប្បន្នដែលមិនចង់ឲ្យបុគ្គលមួយចំនួនដែលកំពុងប្លាប់មានឋានៈតួនាទីខ្ពស់នៅក្រោយរបបខ្មែរក្រហមមានការជាប់ពាក់ព័ន្ធ ។

ទោះបីមានការរិះគន់ដូចបានរៀបរាប់ខាងលើនេះក្តី ក៏អ្នកអត្ថាធិប្បាយខ្លះនៅតែមានសុទិដ្ឋិនិយមថា អង្គជំនុំជម្រះវិសាមញ្ញនឹងផ្តល់ឲ្យមានយុត្តិធម៌ឥតលម្អៀង ហើយជួយជំរុញនិងកែទម្រង់យុត្តាធិការក្នុងស្រុករបស់កម្ពុជាឲ្យសម្រេចបានគោលដៅនេះ ។ មានបញ្ញត្តិការពារជាច្រើននៅក្នុងច្បាប់ដែលធានាថាបុគ្គលិកអន្តរជាតិនឹងមិនត្រូវបានពង្វាងឲ្យខុសទិសដៅដោយសមភាគីកម្ពុជាឡើយ ដោយរួមបញ្ចូលទាំងរូបមន្តមតិភាគច្រើនដែលការពារសេចក្តីសម្រេចរបស់ចៅក្រមអន្តរជាតិនិងយន្តការដោះស្រាយការខ្វែងគំនិតគ្នារវាងសហរដ្ឋអាជ្ញានិងសហចៅក្រមស៊ើបអង្កេតផង ។

ក្រៅពីវង្វង់នៃការអះអាងពីលទ្ធភាពទទួលបានយុត្តិធម៌នៅក្នុងដំណើរការកាត់ក្តី អ្នកគាំទ្រអង្គជំនុំជម្រះវិសាមញ្ញផ្តោតទៅលើសារសំខាន់នៃការរួមចំណែក និងការចូលរួមរបស់ប្រជាជនក្នុងស្រុកនៅក្នុងដំណើរការកាត់ក្តី ហើយក្នុងពេលជាមួយគ្នានោះធានាឲ្យមានស្តង់ដារ និងការចូលរួមពីអន្តរជាតិ និងការផ្តោតទៅលើតម្លៃនៃការកាត់ទោសនៅកម្ពុជាជាភាសាខ្មែរ ដែលរាយការណ៍ដោយសារព័ត៌មាននៅក្នុងស្រុក និងដែលបង្កលក្ខណៈងាយស្រួលសម្រាប់ការចូលរួមរបស់ប្រជាជនកម្ពុជា ។ ដូចតំណាងម្នាក់របស់អង្គជំនុំជម្រះវិសាមញ្ញបានលើកឡើងថាៈ

សញ្ញាណនៃការកាត់ទោសនៅក្នុងប្រទេសកម្ពុជាមានសារសំខាន់ណាស់ ។ យើងមានមូលហេតុជាច្រើនដើម្បីនឹងជឿថា ការកាត់ទោសនៅក្នុងទីក្រុងភ្នំពេញ គឺជាដំណើរការមួយប្រកបដោយអត្ថន័យ ពីព្រោះថា ការកាត់ក្តីទាំងនេះមានវត្តមាននៅក្នុងប្រទេសដែលឧក្រិដ្ឋកម្មបានកើតឡើង ជាជាងនៅខ្វែងមួយឆ្ងាយដែលគេបានតម្រូវឲ្យធ្វើ ។ ក្នុងការចរចាជាមួយអង្គការសហប្រជាជាតិ រដ្ឋាភិបាលចង់ធ្វើជាដៃគូ និងចង់បានលើសពីឋានៈជាដៃគូទៅទៀត ដោយមិនចង់បោះបង់ចោលទាល់តែសោះនូវភាពជាម្ចាស់លើដំណើរការនេះ ។ អនុសាសន៍របស់ក្រុមមន្ត្រីជំនាញដែលចង់ឲ្យតុលាការនេះជាតុលាការអន្តរជាតិសុទ្ធសាធដែលមិនមែនជាតុលាការក្នុងស្រុកនិងមិនមែនជាតុលាការកូនកាត់នោះគឺមិនអាចទទួលយកបានទេ ។

ភាពជាម្ចាស់នេះត្រូវបានចាត់ទុកថាមានសារសំខាន់ មិនមែនដោយសារហេតុផលនិមិត្តរូបនិងវប្បធម៌ប៉ុណ្ណោះទេ ប៉ុន្តែជាវិធីសាស្ត្រមួយជាក់ស្តែងផងដែរ ដែលផ្តោតទៅលើគំនិតដែលថា «មានសក្តានុពលធំធេងក្នុងការផាកចេញពីតុលាការកូនកាត់ ហើយផាកទៅរកតុលាការក្នុងស្រុកវិញ ដោយប្រើបច្ចេកទេសបច្ចេកវិទ្យា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុបុគ្គលិក និងទិន្នន័យដែលប្រសើរជាងមុន» ។ មន្ត្រីកម្ពុជាដែលតែងតាំងឲ្យធ្វើការនៅក្នុងតុលាការនេះ «សង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញនឹងអាចដើរតួនាទីជាគំរូមួយដ៏ល្អនៃតុលាការកូនកាត់» ។

នៅពេលយុត្តាធិការក្នុងស្រុកមានភាពខ្វះចន្លោះមានហេតុផលជាច្រើនដើម្បីនឹងជឿជាក់ថា ការការពារខ្លួននឹងមានជាច្រើនករណីដែលថាចៅក្រមមានសមត្ថភាពនឹងត្រូវបានជ្រើសរើសចេញពីអ្នកដែលមានឯករាជ្យភាពនៅក្នុងជួររដ្ឋាភិបាលនិងថាបុគ្គលិករដ្ឋាភិបាលនឹងទទួលបានចំណេះដឹងជំនាញសំខាន់ៗជាច្រើន នៅពេលដែលអ្នកទាំងនោះវិលត្រឡប់ទៅបំពេញការងាររបស់ខ្លួននៅក្នុងប្រព័ន្ធយុត្តាធិការក្នុងស្រុកវិញ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញមិនទទួលរងនូវការបរាជ័យដែលមិនរំពឹងទុកនិងធ្ងន់ធ្ងរទេនោះ អង្គជំនុំជម្រះនេះនឹងផ្តល់នូវឱកាសពិតប្រាកដមួយក្នុងការធ្វើឲ្យប្រសើរឡើងនូវវប្បធម៌នៃការគោរពចំពោះប្រព័ន្ធតុលាការនិងនីតិរដ្ឋនៅកម្ពុជា ហើយជាពិសេសទៅទៀតនោះថែមទាំងអាចជំរុញឲ្យមានការកែទម្រង់ទៅលើច្បាប់ព្រហ្មទណ្ឌក្នុងស្រុករបស់កម្ពុជា ។

លើសពីនេះទៅទៀត ភាពខ្វាយខ្វល់អំពីការជ្រើសរើសចុងចោទក៏ត្រូវតែលើកយកមកពិភាក្សានៅទីនោះដែរ ។ វាហាក់បីដូចជាបង្ហាញថាមេដឹកនាំខ្មែរក្រហមចំនួន១០រូបដែលនៅមានជីវិតនៅឡើយ នឹងត្រូវនាំយកមកកាត់ទោស បើទោះបីជាអ្នកទាំងនោះមានឋានៈនិងស្ថានភាពរស់នៅបច្ចុប្បន្នយ៉ាងដូចម្តេចក៏

ដោយ ។ ក្រៅពីនេះ ការសម្រេចចិត្តដើម្បីកំណត់ការកាត់ទោសចោទទៅលើអ្នកដែលទទួលខុសត្រូវធំបំផុតនោះ គួរតែត្រូវបានទទួលស្គាល់ថា ជាការចូលរួមប្រកបដោយគំនិតច្នៃប្រឌិតដើម្បីប្រយុទ្ធតទល់នឹងនិទ្ទណ្ឌភាពក្នុងចំណោមអ្នកមានឋានៈខ្ពស់បំផុត ហើយម្យ៉ាងវិញទៀត ត្រូវទទួលស្គាល់ពីសារសំខាន់នៃការលើកទឹកចិត្តឲ្យមានការរំងាប់ចិត្ត និងការធ្វើសមាហរណកម្មរវាងជនដែលដល់ថ្នាក់ក្រោមនិងជនរងគ្រោះ ក្រែងថា ការកាត់ទោសទាំងនេះនាំឲ្យអន្តរាយដល់សន្តិភាពដែលផុយស្រួយរបស់កម្ពុជា ។ ជារួមគួរកត់សម្គាល់ថា បើទោះបីជាយុត្តាធិការរបស់តុលាការពិតជាមានលក្ខណៈតិចតួចមែនក៏ដោយ ផ្ទុយទៅវិញវាតំណាងឲ្យកាលានុវត្តភាពមួយប្លែកពីគេក្នុងការបង្ហាញឲ្យឃើញឧក្រិដ្ឋកម្មរបស់លោក ឃីស ស៊ីងហ័រ, និចសុន, ម៉ៅ និងអ្នកដទៃទៀតដែលសកម្មភាពរបស់អ្នកទាំងនេះបានរួមវិភាគទានឲ្យមានអំពើឃោរឃៅនៅកម្ពុជា ។

## ៥) សាលាក្តីព្រហ្មទណ្ឌជាន់ខ្ពស់របស់អ៊ីរ៉ាក់អតីតសាលាក្តីពិសេសរបស់អ៊ីរ៉ាក់

ស្ថិតក្រោមរបបគ្រប់គ្រងផ្តាច់ការរបស់ខ្លួននៅក្នុងប្រទេសអ៊ីរ៉ាក់ លោកប្រធានាធិបតី សាដាម ហ៊ូសេន បានសម្លាប់ជនជាតិឃឺតអស់ប្រមាណ១៨ម៉ឺននាក់ ព្រមទាំងបានបំផ្លិចបំផ្លាញភូមិឋាន និងទីប្រជុំជនរបស់ជនជាតិឃឺតអស់ជាង៤៥០កន្លែង បានសម្លាប់ពួកនិកាយស៊ីអ៊ីតប្រហែលជា២០ម៉ឺននាក់ ក្រៅពីនេះបានសម្លាប់ប្រជាជនប្រមាណ២០ម៉ឺននាក់បន្ថែមទៀត បានធ្វើឲ្យប្រជាជនប្រមាណ៩០ម៉ឺននាក់បាត់បង់លំនៅស្ថាន ឬបានបង្ខំទៅរស់ក្នុងជំរំផ្សេងៗ ហើយរុញច្រានប្រទេសរបស់ខ្លួនឲ្យជាប់ពាក់ព័ន្ធទៅក្នុងសង្គ្រាមរវាងអ៊ីរ៉ាក់ និងអ៊ីរ៉ង់ ដែលបានឆក់យកជីវិតមនុស្សអស់ប្រមាណពី៥០ទៅ៧០ម៉ឺននាក់ ហើយបានបន្សល់នូវផ្នូរខ្មោចជាច្រើនមិនតិចជាង៣០០កន្លែងទេ ។ ដោយទទួលរងនូវការបំផ្លិចបំផ្លាញអស់ជាច្រើនទសវត្សរ៍ ក្រោមរបបគ្រប់គ្រងផ្តាច់ការ និងការរំលោភលើសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ប្រទេសអ៊ីរ៉ាក់បានស្ថិតក្នុងស្ថានភាពជ្រួលច្របល់ចាប់តាំងពីឆ្នាំ២០០៣នៃការចូលកាន់កាប់របស់សហរដ្ឋអាមេរិកនិងចក្រភពអង់គ្លេស ដែលញាំញីដោយសារអំពើហិង្សានិងចលាចលខាងផ្នែកនយោបាយ ។ កិច្ចប្រឹងប្រែងនានាក្នុងការរៀបចំបង្កើតនូវយន្តការមួយដែលដាក់ឲ្យមានការទទួលខុសត្រូវចំពោះការរំលោភបំពាននានាដែលប្រព្រឹត្តនៅក្នុងរបបគ្រប់គ្រងរបស់លោក សាដាម ហ៊ូសេន បានស្តែងឲ្យឃើញពីអំពើទុច្ចរិតដែលនាំទៅដល់គ្រោះថ្នាក់និងភាពសាំញាំ ដែលជាហេតុនាំទៅដល់ការបង្កើតឡើងនូវតុលាការក្នុងស្រុកលាំដាប់អន្តរជាតិមួយ ដែលហៅថា «តុលាការកូនកាត់» ។

បើទោះជារដ្ឋបាលរបស់លោក ប៊ូស ប៉ុនប៉ងបង្កើតឲ្យមានតុលាការកូនកាត់ជំនួសឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិ យ៉ាងណាក៏ដោយ ក្រុមមន្ត្រីនៃរដ្ឋបាលនេះបានបដិសេធចំពោះការចូលរួមរបស់អន្តរជាតិនៅក្នុងកិច្ចប្រឹងប្រែងដើម្បីបង្កើតតុលាការកូនកាត់នៅក្នុងប្រទេសអាហ្វហ្គានីស្ថាន និងអ៊ីរ៉ាក់ដោយធ្វើការគាំទ្រចំពោះនីតិវិធីច្បាប់ក្នុងស្រុកវិញ ។

ការណ៍ដែលរដ្ឋបាលរបស់លោក ប៊ូស ច្រានចោលនូវការធ្វើអន្តរាគមន៍របស់អន្តរជាតិនៅក្នុងការជំនុំជម្រះក្តី សាដាម ហ៊ូសេន និងមេដឹកនាំអ៊ីរ៉ាក់ដទៃទៀត គឺអាចជាហេតុផលនយោបាយមួយក្នុងគោលបំណងធ្វើការគ្រប់គ្រងលើដំណើរការជំនុំជម្រះរបស់តុលាការដើម្បីបញ្ចៀសពីការរំពឹកដល់រឿងរ៉ាវដ៏គួរឲ្យអាម៉ាស់ចំពោះការគាំទ្ររដ្ឋាភិបាល សាដាម របស់អាមេរិកកាលពីអតីតកាល ឬវាអាចជាការបំពេញតាមបំណងប្រាថ្នារបស់ប្រទេសដែលទាមទារឲ្យមានការជំនុំជម្រះក្តីនៅក្នុងប្រទេសអ៊ីរ៉ាក់ ។ មិនថាហេតុផលអ្វីនោះទេ នៅក្នុងការបង្កើតឋានៈមួយនៅក្នុងដំណើរការជំនុំជម្រះក្នុងប្រទេសអ៊ីរ៉ាក់ រដ្ឋបាលរបស់លោក ប៊ូស បានប្រឆាំងយ៉ាងពេញទំហឹងចំពោះការពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ ឬស្ថាប័នអន្តរជាតិដទៃទៀតស្រដៀងគ្នានេះ ។ រដ្ឋបាលរបស់លោក ប៊ូស បានច្រានចោលសំណូមពររបស់តំណាងនៃក្រសួងការបរទេសបណ្ឌិតសភា និងក្រុមអ្នកច្បាប់អន្តរជាតិដែលគាំទ្រឲ្យមានតុលាការកូនកាត់មួយសម្រាប់ប្រទេសអ៊ីរ៉ាក់ ហើយដែលបានបង្កើតគំរូព្រាងនានាសម្រាប់សាលាក្តីជម្រះនេះ ក្នុងនោះច្បាប់ជាតិនិងអន្តរជាតិនឹងត្រូវយកមកអនុវត្តដោយមានការចូលរួមពីគណៈចៅក្រមអ៊ីរ៉ាក់ជាច្រើនដែលជ្រើសរើសចេញពីបណ្តាប្រទេសមួយចំនួននៃចក្រភពអារ៉ាប់ ។ **(នៅមានត)**

**អេរតែល ហ៊ីហ្វូនេត**

# ត្រូវការតម្លាភាពនៅក្នុងសវនាការ

ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ អង្គបុរេជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងបើក «សវនាការត្រៀម» ដើម្បីបង្ហាញពីការត្រៀមខ្លួនរួចជាស្រេចដើម្បីបើកសវនាការជាសាធារណលើកដំបូងរបស់អង្គជំនុំជម្រះ ។ កាលពីដំបូងឡើយអង្គជំនុំជម្រះវិសាមញ្ញបានគ្រោងរៀបចំសវនាការជាសាធារណៈ ប៉ុន្តែបានផ្លាស់ប្តូរគម្រោងនេះដោយបើកធ្វើជាអសាធារណៈវិញ ។ អង្គបុរេជំនុំជម្រះកំណត់ការផ្លាស់ប្តូរនេះទៅតាមការស្នើរបស់សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ។ វិធានផ្ទៃក្នុងរបស់តុលាការបានចែងថា សវនាការរបស់អង្គបុរេជំនុំជម្រះធ្វើឡើងដោយអសាធារណៈ ហើយលុះណាតែមានចៅក្រម ឬក៏ភាគីណាមួយស្នើឲ្យមានការបើកជាសាធារណៈ អង្គបុរេជំនុំជម្រះអាចយល់ព្រម ។ ប្រសិនបើមានការស្នើឡើងបែបនេះ នោះអង្គបុរេជំនុំជម្រះអាចសម្រេចថាត្រូវធ្វើឡើងជាសាធារណៈឬដោយអសាធារណៈ ។

អង្គបុរេជំនុំជម្រះមិនបានថ្លែងពីហេតុផលណាមួយដែលសវនាការគួរតែធ្វើឡើងជាអសាធារណៈនោះទេ លើកលែងតែស្នើឡើងដោយមិនច្បាស់លាស់ដែលថា «សវនាការត្រៀម» គឺសមស្របដែលត្រូវធ្វើឡើងដោយអសាធារណៈ ។ វាជាការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗនៅតុលាការដើម្បីធ្វើឲ្យដំណើរការប្រកបដោយតម្លាភាពតាមដែលអាចធ្វើទៅបាន ហើយចៅក្រមរបស់អង្គបុរេជំនុំជម្រះគួរតែរក្សា «សវនាការត្រៀម» បើកឲ្យសាធារណជនចូលរួមដើម្បីជំរុញឲ្យមានតម្លាភាពនិងការយល់ដឹងបន្ថែមពីអង្គជំនុំជម្រះវិសាមញ្ញនេះដល់ប្រជាជនកម្ពុជា ។

អង្គបុរេជំនុំជម្រះ ព្រះរាជអាជ្ញា និងអង្គភាពគាំពារក្តីគួរតែធ្វើការដើម្បីធ្វើឲ្យដំណើរការរបស់អង្គជំនុំជម្រះអាចដឹងឮជាសាធារណៈ ។ ជាពិសេសបើយករឿងដែលទទួលការរិះគន់មកលើតុលាការក្នុងពេលថ្មីៗនេះរបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិដែលផ្តល់អនុសាសន៍ដល់ការប្រើប្រាស់ថវិកា និងការជួលបុគ្គលិកមិនត្រឹមត្រូវ អង្គជំនុំជម្រះនេះគួរតែឆ្លៀតយកគ្រប់ឱកាសទាំងអស់ ដើម្បីធានាបាននូវដំណើរការយុត្តិធម៌ប្រកបដោយភាពត្រឹមត្រូវនិងមិនលម្អៀង ដើម្បីធ្វើឲ្យដំណើររឿងរបស់តុលាការដឹងឮជាសាធារណៈ ។

វាក៏មានការរិះគន់ផងដែរពីក្រុមសង្គមស៊ីវិលមួយចំនួនលើការគិតដោយប្រុងប្រយ័ត្ននោះថា តុលាការអាចប្រើតួនាទីរបស់ខ្លួនដើម្បីធ្វើឲ្យដំណើរការរបស់ខ្លួនប្រព្រឹត្តទៅជាអសាធារណៈ ។ ឧទាហរណ៍ ច្បាប់បានចែងថា ដំណើរការស៊ើបអង្កេតនឹងមិនធ្វើឡើងជាសាធារណៈឡើយ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអាចចេញព័ត៌មានអំពីករណីណាមួយជាសាធារណៈ ។ ច្បាប់បានចែងស្រដៀងគ្នានេះដែរថាសហព្រះរាជអាជ្ញាអាចជម្រាបដល់សាធារណជនពីការសង្ខេបពីគោលបំណងរបស់ព័ត៌មាន ប៉ុន្តែវាមិនតម្រូវចាំបាច់ថាត្រូវតែមាននោះទេ ។ ហេតុផលសម្រាប់ភាពទូលំទូលាយបែបនេះគឺថាតុលាការ «មានសារសំខាន់ណាស់ចំពោះតម្រូវការដើម្បីធានាថាសាធារណជនទទួលបានព័ត៌មានត្រឹមត្រូវពីដំណើរការរបស់អង្គជំនុំជម្រះ» ។ ច្បាប់ទាំងពីរនេះបង្កប់នូវការសន្មតជាមុនមួយពីការរក្សាភាពសម្ងាត់ត្រូវបញ្ចៀសឲ្យបានតាមរយៈការខិតខំប្រឹងប្រែងជាពិសេសមួយដើម្បីឲ្យដំណើរការដឹងឮជាសាធារណៈ ។ ការសម្រេចចិត្តលើការបិទ «សវនាការត្រៀម» ជាសាធារណៈបានបង្ហាញឲ្យឃើញការខ្វះខាតក្នុងការខិតខំបែបនេះ ហើយវានឹងជាគំរូគ្រោះថ្នាក់មួយដល់តម្លាភាពនៅពេលខាងមុខ ។

បញ្ញវន្តជាច្រើនធ្វើការកត់សម្គាល់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិ ជាពិសេសតុលាការ «ចម្រុះ» ដូចអង្គជំនុំជម្រះនេះ (និងតុលាការពិសេសនៅសេរ៉ាឡេអូន) ផ្តល់ឱកាសឲ្យប្រព័ន្ធច្បាប់ក្នុងស្រុកយកធ្វើជាគំរូដែលដំណើរការច្បាប់ផ្សេងទៀតរបស់ប្រទេសអាចយកតម្រាប់តាម ។ តាមរយៈការរក្សាដំណើរការពិសេសដូចជា «សវនាការត្រៀម» នេះជាអសាធារណៈ វានឹងគ្មានមេរៀនអ្វីដែលអាចរៀនសូត្របាន ហើយក៏នឹងមិនអាចធ្វើជាគំរូមួយដែលសហគមន៍ច្បាប់កម្ពុជាយកធ្វើជាគំរូបានឡើយ ។

*រឿងពិតដែរ «សវនាការត្រៀម» រិតត្បិតដល់បញ្ហាច្បាប់ដូចនេះ ដោយសារតែវាខុសពីរឿងរ៉ាវសំខាន់មួយដែលថាមានហេតុផលជាច្រើនទៀតដើម្បីធ្វើឲ្យវាក្លាយជាដំណើរការសាធារណៈ ។ ដំណើរការជាច្រើនរបស់តុលាការនេះនឹងធ្វើឡើងនៅក្រៅវត្តមានភ្នែកសាធារណជន ។ មានហេតុផលល្អខ្លះដើម្បីធ្វើរឿងបែបនេះ ដូចជាការការពារដល់សាក្សីនិងការការពារជនរងគ្រោះពីក្រសែភ្នែកសាធារណជន នៅពេលដែលមានការស្នើសុំណាមួយពីជនរងគ្រោះឲ្យមានសវនាការជាអសាធារណៈ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ដំណើរការច្បាប់ធ្វើឡើងជាដំណាក់កាល ៗ ដូចជាពីការស៊ើបអង្កេតទៅការចោទប្រកាន់ បន្ទាប់មកទៅកាន់សវនាការទៅដល់ការសម្រេចចិត្ត និងទៅដល់ការដាក់ទោសទណ្ឌ ហើយនៅក្នុងដំណាក់កាលនីមួយ ៗ ក៏មានដំណើរការជាច្រើនទៀតដែរ ។ ការប៉ុនប៉ងបង្ហាញពីដំណើរការច្បាប់ប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌មិនអាចសម្រេចទៅបានតាមរយៈការបង្ហាញនូវដំណើរការខ្លះរបស់ដំណើរការទាំងមូលនោះបានទេ ។*

*ការសិក្សាមួយធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលកម្ពុជាមួយនៅឆ្នាំ២០០៦បានរកឃើញថា នៅប្រទេសកម្ពុជាពុំមានការយល់ដឹងច្រើនពីដំណើរការច្បាប់ទេ ។ បើគិតពីភាពស្មុគស្មាញ និងប្រវត្តិនយោបាយដែលកើតឡើងដោយទម្លាប់ច្បាប់ខុសគ្នានិងរដ្ឋធម្មនុញ្ញខុសគ្នា រឿងនេះវាមិនមែនជារឿងចម្លែកទេនៅប្រទេសកម្ពុជា ។ តាមតែអាចធ្វើទៅបាន អង្គជំនុំជម្រះវិសាមញ្ញគួរតែពុះពារគ្រប់ឱកាសទាំងអស់ដើម្បីឲ្យសាធារណជនបានចូលរួមនៅក្នុងដំណើរការរបស់ខ្លួន ដើម្បីជួយដល់ប្រជាជនកម្ពុជាចាប់ផ្តើមយល់ដឹងពីដំណើរការច្បាប់ ។ អ្នកខ្លះអាចអះអាងថាមានតែដំណើរការច្បាប់សំខាន់បំផុត និងប្រកបដោយការប្តេជ្ញាខ្ពស់ទើបអាចធ្វើឡើងជាសាធារណៈដើម្បីចៀសវាងកុំឲ្យប្រជាជនកម្ពុជាមានការភ័ន្តច្រឡំពីអ្វីកំពុងកើតឡើងនៅក្នុងតុលាការនេះ ។ ទោះជាយ៉ាងនេះក្តី អំណះអំណាងនេះមិនបានគិតដល់ប្រសិទ្ធភាពដែលអាចមាន ដោយការចែកផ្សាយព័ត៌មានអំពីតុលាការនេះ ។ តាមរយៈការផ្តល់ចំណេះដឹងដល់ប្រជាជនកម្ពុជាអំពីការពិតដែលដំណើរការកំពុងកើតឡើង វានឹងអាចទំនងជាថា ពេលការកាត់ក្តីចាប់ផ្តើមប្រជាជនកម្ពុជានឹងមានចំណេះដឹងរួចជាស្រេចពីរបៀបរបបច្បាប់ដំណើរការនិងស្ថិតនៅក្នុងជំហរមួយដើម្បីវាយតម្លៃដល់ការកាត់ក្តីនិងចៅក្រមធ្វើឡើងដោយយុត្តិធម៌ ។*

*អង្គបុរេជំនុំជម្រះ សហព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេតនិងផ្នែកផ្សេងទៀតរបស់តុលាការគួរតែសម្លឹងមើលផលប្រយោជន៍លើគ្រប់ឱកាសទាំងអស់ដើម្បីធ្វើឲ្យព័ត៌មានអំពីដំណើរការរបស់អង្គជំនុំជម្រះនេះបានដឹងឮដល់សាធារណជនដែលមិនទាស់ខុសអ្វីទៅនឹងយុត្តិធម៌ត្រឹមត្រូវនិងមិនលម្អៀង ហើយវានឹងជាសវនាការប្តឹងការសម្រេចចិត្តនាំមុខពីទោសទណ្ឌព្រហ្មទណ្ឌ ។ អង្គជំនុំជម្រះនេះធ្វើឡើងដើម្បីប្រជាជនកម្ពុជា ហើយសកម្មភាពដែលខ្លួនធ្វើវានឹងឆ្លុះបញ្ចាំងពីសមត្ថភាពរបស់ខ្លួន ។* **ឆ័រមែន ហែនរី ប៉េនតេលៀវិច**

*លិខិតពីមិត្តអ្នកអាន*

*តាកែវ, ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧*

## សូមគោរពមកលោកនាយកមជ្ឈមណ្ឌលឯកសារស្វែងរកការពិត!
## បុគ្គលិកមជ្ឈមណ្ឌលទាំងអស់ជាទីរាប់អាន!

*ខ្ញុំមានកិត្តិយស និងសូមគោរពអនុញ្ញាតមកលោកនាយកមេត្តាចុះផ្សាយសំណួរនិងទស្សនៈខ្លះជុំវិញបញ្ហាមួយចំនួនទៅនឹងដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមតាមរយៈទស្សនាវដ្តីរបស់លោកដោយអនុគ្រោះ ។*

*ខ្លឹមសារនៃសំណួរនិងទស្សនៈខ្ញុំ មានរៀបរាប់ជាបន្តបន្ទាប់ដូចខាងក្រោម÷*

*១) បើបទឧក្រិដ្ឋប្រល័យពូជសាសន៍បានកើតឡើងនៅក្នុងប្រទេសមួយដែលផ្ទុយនឹងច្បាប់អន្តរជាតិ ហើយនៅពេលក្រោយមកក៏មានអ្នកក្រោយបានកាន់អំណាចម្តងបន្ទាប់ពីរបបមុននោះបានដួលរលំទៅ ។ តើអ្នកដឹកនាំក្រោយ ៗ អាចមានសិទ្ធិអំណាចអ្វីរារាំងមិនឲ្យសហគមន៍ជាតិនិងសហគមន៍អន្តរជាតិ ក្នុងការនាំមេដឹកនាំទាំងនោះមកកាត់ទោសអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនោះបានដែរឬទេ? បើបានពឹងផ្អែកលើកត្តាអ្វីដែរ? ឧទាហរណ៍ដាក់ស្តែងបញ្ហាបទឧក្រិដ្ឋប្រល័យពូជសាសន៍របស់មេ ៗ ខ្មែរក្រហមនេះជាដើម ។*

២) កត្តាអ្វីខ្លះដែលបានបណ្ដាលឲ្យការបង្កើតតុលាការខ្មែរក្រហមមានការយឺតយ៉ាវ អូសបន្លាយអស់ជិតពីរទសវត្សរ៍បន្ទាប់ពីប្រទេសកម្ពុជាមានរដ្ឋាភិបាលស្របច្បាប់ចាប់តាំងពីឆ្នាំ១៩៩៣មកម៉្លេះ? ការយឺតយ៉ាវនេះរហូតធ្វើឲ្យមានការព្រួយបារម្ភស្មើរជាសាធារណៈ មិនថាមតិជាតិនិងមតិអន្តរជាតិចំពោះភាពចាស់ជរានៃមេដឹកនាំខ្មែរក្រហម ដែលអាចនឹងស្លាប់បាត់បង់ជីវិតមុនការកាត់ទោសអ្នកទាំងនោះដើម្បីផ្ដល់យុត្តិធម៌ជូនជនរងគ្រោះ ។

៣) សាធារណជន ជាតិនិងអន្តរជាតិបានដឹងថា បទឧក្រិដ្ឋប្រល័យពូជសាសន៍ដែលរបបខ្មែរក្រហមធ្វើអំពើប្រព្រឹត្តផ្ទុយនឹងច្បាប់អន្តរជាតិ ។ ចុះហេតុដូចម្ដេចក៏ខ្មែរក្រហមមិនត្រូវបានតុលាការអន្តរជាតិយកទៅកាត់ទោសដោយផ្ទាល់តែម្ដងបែរជាយកមេៗខ្មែរក្រហមមកកាត់ទោសដោយតុលាការចម្រុះជាតិសាសន៍ខ្មែរបរទេសនៅក្នុងតុលាការខ្មែរទៅវិញ? តើបញ្ហានេះមានប្រវត្តិយ៉ាងដូចម្ដេចរវាងច្បាប់ជាតិនិងរដ្ឋមួយ?

៤) តើពាក្យមេដឹកនាំនិងអ្នកទទួលខុសត្រូវមានអត្ថន័យខុសគ្នាយ៉ាងដូចម្ដេច? បើតាមខ្ញុំយល់ពាក្យថាមេដឹកនាំគឺជាអ្នកទទួលខុសត្រូវនៃអំពើទាំងឡាយដែលខ្លួនធ្វើ និងអ្នកក្រោមបញ្ជារបស់ខ្លួនធ្វើផងដែរ ព្រោះអ្នកក្រោមបញ្ជាធ្វើទៅតាមច្បាប់ឬបទបញ្ជាដែលមេរបស់ខ្លួនដាក់ចុះនូវផែនការនយោបាយនៃរបបមួយក្នុងនាមជារដ្ឋមិនអាចខុះបានឡើយ ។ ក្នុងន័យនេះ បើអ្នកណាហ៊ានប្រឆាំងមិនអនុវត្តផែនការនយោបាយ អ្នកនោះត្រូវបានចាត់ទុកឬហៅថាប្រឆាំងនឹងច្បាប់រដ្ឋនឹងត្រូវមានទោសយ៉ាងពិតប្រាកដ ។ ដាក់ស្ដែងរឿង «ឌុច» ជាអ្នកក្រោមបញ្ជា ឋានៈប្រធានគុកក្នុងរបបខ្មែរក្រហម គាត់ត្រូវតែធ្វើតាមច្បាប់នៃរដ្ឋខ្មែរក្រហមទើបបានរួចខ្លួនរស់នៅបានសុខ ហើយបើគាត់មិនព្រមធ្វើតាមទេគាត់ច្បាស់ជាមានទោសដល់ខ្លួនជាពុំខានឡើយ ។ ចុះហេតុដូចម្ដេចបានជាតុលាការខ្មែរក្រហមចាប់ «ឌុច» យកទៅកាត់ទោសជាមួយមេៗដែរនោះព្រោះថា «ឌុច» គ្រាន់តែជាអ្នកក្រោមបញ្ជា ធ្វើតាមបញ្ជាដូចប្រធានគុកដទៃទៀតនៅក្នុងរបបខ្មែរក្រហមតែប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ប្រធានគុកជាច្រើនទៀតដូច «ឌុច» ដែរនោះ បែរជារួចខ្លួនទៅវិញ ជាការពុំសមហេតុសមផលសម្រាប់ «ឌុច» នោះឡើយ ។

៥) ប្រសិនបើតុលាការបានរកឃើញថា មេៗខ្មែរក្រហមបានប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍មែន ហើយត្រូវមានទោសជាប់គុកអស់មួយជីវិត ។ ចុះពេលអ្នកទាំងនោះឈឺហៀបស្លាប់ ឬក៏ស្លាប់នៅក្នុងមន្ទីរឃុំឃាំង តើតុលាការអាចអនុញ្ញាតឲ្យក្រុមគ្រួសារសាច់ញាតិ ឬក្លឹម្រាក់យកចេញពីគុកដើម្បីថែរក្សា ព្យាបាលជំងឺ ឬយកសាកសពទៅធ្វើបុណ្យទាន បញ្ចុះនៅទីណាដែលគេប្រាថ្នាទៅតាម ប្រពៃណីសាសនាបានដែរឬទេ?

៦) តើចៅក្រមត្រូវកាត់សេចក្ដីយ៉ាងដូចម្ដេចចំពោះទោសកំហុសរបស់មេដឹកនាំខ្មែរក្រហម? បើឧបមាថាជនរងគ្រោះនិងសាច់ញាតិជនរងគ្រោះបានដាក់បណ្ដឹងបានតិចតួចនៅតុលាការ បើប្រៀបទៅនឹងចំនួនជនរងគ្រោះដែលនៅរស់និងបានស្លាប់អស់រាប់លាននាក់ ។ តើពាក្យបណ្ដឹងដែលតិចតួចនោះអាចឲ្យតុលាការកាត់ក្ដីថា ជាបណ្ដឹងតំណាងឲ្យជនរងគ្រោះ និងអ្នកស្លាប់ទាំងជាងមួយលាននាក់នោះពិតប្រាកដមែនឬ?

នៅទីបញ្ចប់ ខ្ញុំបាទសូមខន្តីអភ័យទោសនូវរាល់កំហុសឆ្គងនៃខ្លឹមសារសំណួររបស់ខ្ញុំដោយអចេតនាដែលបានកើតមានពីសំណាក់អង្គតុលាការ អ្នកច្បាប់ទាំងអស់ សូមមេត្តាអធ្យាស្រ័យ និងអនុគ្រោះដោយហេតុថា ខ្ញុំបាទពុំមែនជាអ្នកច្បាប់ទេ ខ្ញុំគ្រាន់តែបុគ្គលម្នាក់ចង់ស្វែងយល់អំពីច្បាប់និងដំណើរតុលាការខ្មែរក្រហមតែប៉ុណ្ណោះ ។

សូមឲ្យបេសកកម្មរបស់តុលាការបានសម្រេចយុត្តិធម៌ជូនប្រទេសខ្មែរដ៏អភ័ព្វ ។

សូមឲ្យមជ្ឈមណ្ឌលសម្រេចបាននូវបេសកកម្មស្រាវជ្រាវរកការពិត ។

**គុង វ៉ា**




ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 96, December 2007 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.